00388424

D130/9/13

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**Declassified to Public**

**12 April 2013**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អជប ២៦ ~~និង ២៧~~)

ដាក់ទៅ: អង្គបុរេជំនុំជម្រះ

ថ្ងៃដាក់: ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩

ភាគីអ្នកដាក់: ការិយាល័យសហព្រះរាជអាជ្ញា

ភាសាដើម: អង់គ្លេស

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 12 / OCT / 2009
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Huy

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ**

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 12 / OCT / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Huy

## ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍ របស់ អៀង ធីរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម"

<u>អ្នកដាក់ឯកសារ:</u>

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក William SMITH

លោក យ៉េត ចរិយា

លោក សេង ប៊ុនឃាង

លោក Vincent de WILDE

<u>អ្នកទទួលឯកសារ:</u>

**អង្គបុរេជំនុំជម្រះ៖**

**ការិ.សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន

ចៅក្រម Rowan DOWNING, QC

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

00388425

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**
**និងភាគីដើមបណ្ដឹងរដ្ឋប្បវេណីដែលគ្មានតំណាង៖**

**មេធាវីជនត្រូវចោទ៖**

**អៀង ធីរិទ្ធ**
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS

**ខៀវ សំផន**
លោក សរ សុវាន
លោក Jacques VERGES

## ១. សេចក្តីផ្តើម

១. បណ្តឹងឧទ្ធរណ៍ទាំងនេះ រួមបញ្ចូលនូវការព្យាយាមអនុវត្តនូវវិធាន ស្តីពីការបដិសេធភស្តុតាង អំពីការធ្វើទារុណកម្ម នៅក្នុងករណីរឿងមួយប្រឆាំងនឹងជនជាប់ចោទចំនួនប្រាំនាក់ អំពីការអនុវត្តន៍ប្រព័ន្ធសួរចម្លើយ និងការធ្វើទារុណកម្មមួយនៅទូទាំងប្រទេស ដើម្បីបដិសេធចោលនូវឯកសារសួរចម្លើយចំនួនរាប់ពាន់ ដោយមិនមានការព្រាងទុកជាមុនដែលបានបន្សល់ទុកដោយអ្នកធ្វើទារុណកម្មដែលបង្កើតជាឯកសារស្តីពីការធ្វើទារុណកម្មជាប្រព័ន្ធ និងការប្រព្រឹត្តឧក្រិដ្ឋកម្មដទៃទៀត ដែលកំពុងត្រូវបានចោទប្រកាន់ ។

២. ក្នុងចន្លោះពេលពីខែមេសា ១៩៧៥ និងខែមករា ១៩៧៩ មានមនុស្សជាងមួយម៉ឺនពីរពាន់នាក់ត្រូវបានចាប់ខ្លួន ឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ចោលនៅមន្ទីរសន្តិសុខ ស-២១ នៅក្នុងទីក្រុងភ្នំពេញ ។ មនុស្សរាប់សែននាក់បន្ថែមទៀត ត្រូវបានសួរចម្លើយ និង ធ្វើទារុណកម្ម នៅមន្ទីរសន្តិសុខផ្សេងៗទៀតក្នុងទូទាំងកម្ពុជាប្រជាធិបតេយ្យ ។ នៅមុនពេលរត់គេចចេញទីកន្លែងនៃឧក្រិដ្ឋកម្មរបស់ខ្លួន នៅដើមខែមករា ១៩៧៩ ខ្មែរក្រហមបានបំផ្លាញចោលនូវភស្តុតាងជាឯកសារភាគច្រើនដែលកត់ត្រាអំពីសកម្មភាពរបស់ពួកគេ ។ សំណាងល្អកម្មាភិបាលជាច្រើននៃមន្ទីរស-២១ បានចាកចេញយ៉ាងប្រញាប់ប្រញ៉ាល់ ហើយបានបន្សល់ឯកសារសួរចម្លើយចំនួនរាប់ពាន់ ។ ឯកសារទាំងនេះបង្កើតបានជាឯកសារស្លាកស្នាមពិតប្រាកដនៃការសួរចម្លើយ និងការធ្វើទារុណកម្មជាប្រព័ន្ធ ដែលបានអនុវត្តនៅ មន្ទីរស-២១ នៅក្នុងអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមពិត កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាប្រធាននៃមន្ទីរស-២១ ត្រូវបានស្តីបន្ទោសយ៉ាងខ្លាំងដោយ នួន ជា អនុលេខានៃបក្សកុម្មុយនីស្តកម្ពុជា អំពីការខកខានមិនបានកំទេចចោលនូវភស្តុតាងទាំងនោះ ។ បច្ចុប្បន្ននេះ អៀង ធីរិទ្ធ និង ខៀវ សំផន បានខិតខំដើម្បីបំពេញភារកិច្ចដែល ឌុច ខកខានមិនបានបំពេញ កាលពីសាមសិប (៣០) ឆ្នាំកន្លងទៅ ដោយដកចេញពីសំណុំរឿងនូវឯកសារ ដាក់បន្ទុកចំនួនរាប់ពាន់ទំព័រ ដែលត្រូវបានរកឃើញនៅមន្ទីរស-២១ ដែលផ្តល់ភស្តុតាង នៃ ឧក្រិដ្ឋកម្មរបស់ពួកគេ ។

៣. សហព្រះរាជអាជ្ញា ស្នើឲ្យបដិសេធចោលនូវបណ្តឹងឧទ្ធរណ៍ទាំងនេះ ដោយសារ៖

ក. ឯកសារទាំងនេះ មិនអាចទទួលយកបានទេ ដោយសារសេចក្តីសម្រេចដែលកំពុងតវ៉ាជំទាស់នេះ មិនស្ថិតនៅក្នុងបញ្ជីនៃសេចក្តីសម្រេចលម្អិតដែលប្រឆាំងនឹងបណ្តឹង ឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះទេ ។

ខ. បើសិនជាបណ្តឹងឧទ្ធរណ៍ទាំងនោះត្រូវបានយល់ឃើញថា គឺជាសំណើសុំមោឃៈភាពនោះ ពួកគេមានវិការៈខាងនីតិវិធី និងខ្លឹមសារ ។

គ. បណ្តឹងឧទ្ធរណ៍មិនមានភាពច្បាស់លាស់ ហើយឈឿនមុនកំណត់ពេក និងស្វែងរកការចេញសេចក្តីសម្រេចដែលមានលក្ខណៈសេចក្តីប្រកាសមួយ ដែលមិនទាន់មានសមត្ថកិច្ចតុលាការណាមួយនៃតុលាការនេះ បានទុកចិត្ត និងបានសម្រេចនៅឡើយ លើភាពអាចទទួលយកបាននៃឯកសារណាមួយដែលចោទប្រកាន់ថាទទួលបានមកដោយការធ្វើទារុណកម្មនោះ។

ឃ. ទោះបីជាបណ្តឹងឧទ្ធរណ៍អាចទទួលយកបានក៏ដោយ ការបដិសេធលើការប្រើប្រាស់តាមលក្ខណៈកោសលវិច័យវិជ្ជសាស្ត្រ ចំពោះភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម មិនត្រូវបានប្រើប្រាស់ដោយតឹងរ៉ឹងនៅទីនេះឡើយ ដោយសារភស្តុតាងនោះមិនត្រូវបានប្រើប្រាស់សម្រាប់ធ្វើការចោទប្រកាន់ទៅលើអ្នកត្រូវគេធ្វើទារុណកម្មទេ ប៉ុន្តែ ទៅលើអ្នកធ្វើទារុណកម្មគេទៅវិញ ។

ង. ទោះបីជាមានការរកឃើញថា ឯកសារមួយចំនួនត្រូវបានបង្កើតឡើងដោយសារការធ្វើទារុណកម្មក្តី ក៏ឯកសារទាំងនោះមានព័ត៌មានដែលអាចអនុញ្ញាតឲ្យគេប្រើប្រាស់ បានដោយសារតែលក្ខណៈជាក់លាក់របស់ “ចម្លើយសារភាពទាំងនោះ” ដែលបានមកពីមន្ទីរស-២១ ហើយនិងលក្ខខណ្ឌផ្សេងៗនៃការទទួលបានឯកសារទាំងនោះ ។ ការបកស្រាយណាមួយផ្សេងទៀតនៃវិធាន ស្តីពីការបដិសេធភស្តុតាងនៅក្នុងអនុសញ្ញា ស្តីពីការប្រឆាំង នឹង ការធ្វើទារុណកម្ម (“CAT”) មុខជាជួយប្រយុទ្ធប្រឆាំងទៅនឹងចេតនា និងគោលបំណងនៃ អនុសញ្ញានេះ ហើយមុខជាចូលរួមចំណែកនៅក្នុងនិទណ្ឌភាពនៃការធ្វើទារុណកម្ម ដែលជាគោលបំណងពិតប្រាកដដែលអនុសញ្ញានេះ ត្រូវបានគេបង្កើតឡើង ។

## ២. ប្រវត្តិនីតិវិធីដែលពាក់ព័ន្ធ

៤. មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ បានដាក់សំណើសុំមួយដែលមានចំណងជើងថា*សំណើរបស់មេធាវីការពារក្តី ស្នើសុំច្រានចោលភស្តុតាង ដែលបានមកដោយការធ្វើទារុណកម្ម* "សំណើសុំរបស់មេធាវីការពារក្តី") ជាមួយ សចស នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩[1] អនុលោមតាមវិធាន៥៥.១០ នៃវិធានផ្ទៃក្នុង ("វិធាន") ។ សហព្រះរាជអាជ្ញា បានឆ្លើយតបនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩[2] ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") ហើយមេធាវីការពារក្តីបាន ឆ្លើយតបនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩[3] មុនពេល សចស ចេញ*ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម* របស់ខ្លួននៅ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩[4] ។ មេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ បានដាក់សេចក្តីជូនដំណឹងមួយអំពីការប្តឹងឧទ្ធរណ៍ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩[5] ខណៈដែលមេធាវីការពារក្តីរបស់ ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍របស់ខ្លួន នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩[6] ។ មេធាវីការពារក្តីរបស់ ខៀវ សំផន បានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាសម្រេចរបស់ សចស នៅថ្ងៃ ទី ២៧ ខែ សីហា ឆ្នាំ

---

[1] សំណើរបស់មេធាវីការពារក្តីសុំច្រានចោលភស្តុតាង ដែលបានមកដោយការធ្វើទារុណកម្ម, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩, D130, ERN 00281011-25 (ភាសាអង់គ្លេស) និង 00280991-1010 (ភាសាខ្មែរ) (ចាប់ពីនេះតទៅហៅថា "សំណើរបស់មេធាវីការពារក្តី") ។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវី អៀង ធីរិទ្ធ ដែលស្នើសុំឱ្យបដិសេធភស្តុតាង ដែលបានមកដោយការធ្វើទារុណកម្ម ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៩, ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩, D130/5, ERN 00324547-72 (ភាសាខ្មែរ) ERN 00324573-88 (ភាសាអង់គ្លេស) (ចាប់ពីនេះតទៅហៅថា "ចម្លើយតបរបស់សហព្រះរាជអាជ្ញា") ។

[3] ចម្លើយតបរបស់មេធាវីការពារក្តីលើ "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំច្រានចោលភស្តុតាង ដែលបានមកដោយការធ្វើទារុណកម្ម", ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩, D130/6, ERN 00327264-83 (ភាសាខ្មែរ), ERN 00327284-98 (ភាសាអង់គ្លេស), ("ចម្លើយតបរបស់មេធាវីការពារក្តី") ។

[4] ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការប្រើប្រាស់ភស្តុតាងដែលបានមកឬដែលអាចបានមកដោយការធ្វើទារុណកម្ម", ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩, D130/8, 00355904-00355917(ភាសាខ្មែរ), ERN 00355926-33 (ភាសាអង់គ្លេស), 00355918-25 (ភាសាបារាំង) ,ERN ("ដីកាសម្រេចលើភស្តុតាងនៃអំពើទារុណកម្ម") ។

[5] សេចក្តីជូនដំណឹងរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ អំពីការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម", ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩, D130/9 ។

[6] សេចក្តីជូនដំណឹងរបស់ ខៀវ សំផន អំពីការដាក់បណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩, D130/10 ។

២០០៩[7] ("បណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន") ហើយមេធាវីការពារក្ដីរបស់ អៀង ធីរិទ្ធ ("ដើមបណ្ដឹងឧទ្ធរណ៍") បានដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួន ("បណ្ដឹងឧទ្ធរណ៍") នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩[8] ។

៥. ក្រៅពីការបង្ហាញអំណះអំណាងយ៉ាងខ្លីបំផុត នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន មេធាវីការពារក្ដីរបស់ ខៀវ សំផន គ្រាន់តែបានគាំទ្រ "ជាមុន លើរាល់យោបល់ទាំងអស់ដោយគ្មានលក្ខខណ្ឌនៃសារណាបណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេត"[9] ។ សហព្រះរាជអាជ្ញា ពិចារណាឃើញថាការឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និងអំណះអំណាងរបស់ ខៀវ សំផន ក្នុងពេលតែមួយនៅក្នុងចម្លើយតបរួមមួយ ជាការគាំទ្រចំពោះសេដ្ឋកិច្ចរបស់តុលាការផង និងរដ្ឋបាលយុត្តិធម៌ល្អផង ។ សហព្រះរាជអាជ្ញា ស្នើឱ្យ អបជ ចេញដីកាសម្រេចអនុញ្ញាតឱ្យធ្វើចម្លើយតបរួមមួយទៅនឹងបណ្ដឹងឧទ្ធរណ៍ទាំងនេះ ។ អបជ បានសម្រេច នៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៩[10] ដើម្បីផ្ដល់ការពន្យារពេលតាមពាក្យសុំរបស់សហព្រះរាជអាជ្ញា ក្នុងការដាក់ចម្លើយតបរបស់ខ្លួន ទៅនឹងបណ្ដឹងឧទ្ធរណ៍ដែលបានដាក់ដោយជនត្រូវចោទ អៀង ធីរិទ្ធ

---

[7] បណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ជាភាសាបារាំង ក្រោមចំណងជើងថា *Appel de M. Khieu Samphan contre l'ordonnance sur l'utilisation des éléments obtenus ou susceptibles d'avoir été obtenus sous la torture,* ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩, D130/10/1, ERN 00367321-24 (ភាសាបារាំង) ។ បណ្ដឹងឧទ្ធរណ៍ត្រូវបានបកប្រែ និងបានជូនដំណឹងដល់ កសព ជាភាសាអង់គ្លេស នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩, ERN 00374825-28 (ភាសាអង់គ្លេស), ERN 00367763-00367767 (ភាសាខ្មែរ) (ចាប់ពីនេះតទៅហៅថា "បណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន") ។

[8] បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម" របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩, ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៩, D130/9/6, ERN 00374841-72 (ភាសាអង់គ្លេស), ERN 00374873-00374917(ភាសាខ្មែរ) ដែលបានជូនដំណឹងដល់សហព្រះរាជអាជ្ញា នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ (ចាប់ពីនេះតទៅហៅថា "បណ្ដឹងឧទ្ធរណ៍") ។

[9] បណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន, កថាខណ្ឌទី៦ ។

[10] *ករណីរបស់ អៀង ធីរិទ្ធ,* សេចក្ដីសម្រេចរបស់ អបជ លើពាក្យសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម, ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩, D130/9/8 (អបជ២៦) និង *ករណីរបស់ ខៀវ សំផន,* សេចក្ដីសម្រេចរបស់ អបជ លើពាក្យសុំពន្យារពេលរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់ចម្លើយតបរបស់ខ្លួន ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម, ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩, D130/10/4 (អបជ២៧) ។

00388430



និង ខៀវ សំផន[11], អបជ បានបង្គាប់ឱ្យ សហព្រះរាជអាជ្ញា ដាក់ចម្លើយតប របស់ខ្លួនត្រឹមថ្ងៃទី១២ ខែ តុលា ឆ្នាំ២០០៩ ។

៦. មេធាវីការពារក្តី ស្នើឱ្យ អបជ បដិសេធចោលដីកាសម្រេចរបស់ សចស ស្តីពីភស្តុតាងនៃអំពើទារុណកម្ម ហើយជាជំនួសមកវិញ បង្គាប់បញ្ជា សចស ៖ ក) មិនឱ្យទទួលយកភស្តុតាងឬចម្លើយសារភាពទាំងឡាយណាដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម ក្រៅតែពីការបង្ហាញឱ្យឃើញថា ចម្លើយសារភាពមួយចំនួនត្រូវបានធ្វើឡើងដោយការធ្វើទារុណកម្ម និងសម្រាប់តែប្រឆាំងនឹងអ្នកប្រព្រឹត្តអំពើទារុណកម្មតែប៉ុណ្ណោះ រួមទាំងតែមិនកំណត់ត្រឹមតែឯកសារ ដូចជា ឯកសារ D3/ឧបសម្ព័ន្ធ គ (៥ - ចម្លើយសារភាព), ឯកសារ D82 (ឯកសារទួលស្លែង), ឯកសារ D43 (ឯកសាររបស់ DC-Cam) និងភស្តុតាងរបស់អ្នកជំនាញ ដែលផ្អែកទៅលើចម្លើយសារភាពនានា ដូចជា ឯកសារ D2/15 របស់លោក ក្រេក អ៊ិតឈឺសិន (Craig C. Etcheson) និង ខ) មិនប្រើប្រាស់ចម្លើយសារភាពបែបនេះទោះបីជាតាមវិធីណាក៏ដោយ ដែលមានចែងនៅក្នុងចំណុច ក ខាងលើ)[12] ។ មេធាវីការពារក្តីដាក់សេចក្តីសន្និដ្ឋាន អំពីទឡ្ហីករណ៍នៃបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នាចំនួនដប់បួន ។ ដើម្បីជៀសវាងភាពច្រំដែល សហព្រះរាជអាជ្ញា នឹងមិនឆ្លើយតបទៅគ្រប់ទឡ្ហីករណ៍នីមួយៗនៃបណ្តឹងឧទ្ធរណ៍ដែលភាគច្រើនជាងគ្នានោះទេ ប៉ុន្តែជាជំនួសមកវិញ សហព្រះរាជអាជ្ញានឹងលើកយកមកពិភាក្សាឱ្យបានទូលំទូលាយចំណុចជាបឋម អំពីការបកស្រាយអនុសញ្ញា CAT និងពីប្រភេទខុសៗគ្នានៃភស្តុតាងដែលគេពិចារណាថា គួរតែអាចទទួលយកបាននៅចំពោះមុខ សចស ។

## ៣. បញ្ហាជាបឋម

### ក. យុត្តាធិការក្នុងការធ្វើសវនាការលើបណ្តឹងឧទ្ធរណ៍

[11] ពាក្យសុំពន្យារពេលជាបន្ទាន់របស់សហព្រះរាជអាជ្ញា ក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ និង ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម, ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០៩, D130/9/7 (អបជ២៦) និង D130/10/2 (អបជ២៧), លេខ ERN ដូចគ្នាគឺ ERN 00375588-91 (ភាសាអង់គ្លេស) ។

[12] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១២៤ ។

៧. វិធាន ៧៤.៣ នៃវិធានផ្ទៃក្នុង ("វិធាន") រៀបរាប់តាមលំដាប់អំពីប្រភេទឯកសារនានា ដែលជនត្រូវចោទអាចធ្វើបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ។ បញ្ជីនេះរៀបរាប់ល្អិតល្អន់គ្មានសល់[13] ។ បន្ថែមពីលើនេះ ការអានរួមគ្នានូវ៥៥.១០ និងវិធាន៧៤.៣ ក៏បង្ហាញឱ្យឃើញជាក់ស្ដែងដែរថា មានតែដីកាសម្រេចបដិសេធលើសំណុំសុំឱ្យបំពេញកិច្ចស៊ើបសួរ តែប៉ុណ្ណោះ ដែលអាចនឹងប្ដឹងឧទ្ធរណ៍បាន មិនមែនដីកាសម្រេចណាមួយផ្សេងពីនេះ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតាមវិធាន៥៥.១០ នោះទេ ។ អង្គបុរេជំនុំជម្រះបានសម្រេចថា សេចក្ដីសម្រេចណាមួយផ្សេងពីនេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យតាមរយៈនីតិវិធីស្ដីពីការធ្វើមោឃៈភាព[14] ។ បណ្ដឹងឧទ្ធរណ៍ទាំងនេះ មិនមែនកើតចេញពីការបដិសេធលើសំណើសុំ ឱ្យបំពេញកិច្ចស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេតនោះទេ ហើយដូច្នេះ គឺមិនអាចឱ្យទទួលយកបានឡើយ ។ ជាងនេះទៀត សន្មត់ថា បណ្ដឹងឧទ្ធរណ៍ទាំងនោះគឺជាសំណើសុំធ្វើមោឃៈភាព - ដោយមិនបានធ្វើឱ្យកម្រើកឡើងតាមរយៈយន្តការមោឃៈជាក់លាក់ត្រឹមត្រូវតាមនីតិវិធី - បណ្ដឹងឧទ្ធរណ៍ទាំងនោះ គឺមានវិការៈខាងទម្រង់ និងខ្លឹមសារ អាស្រ័យហេតុនេះ គួរតែបានបដិសេធចោល ។

៨. សហព្រះរាជអាជ្ញា ក៏សង្កេតឃើញដែរថា បណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន មិនបាន បញ្ជាក់ពីមូលដ្ឋានខាងគតិយុត្តិនៃបណ្ដឹងនោះទេ ដែលខុសគ្នាពីច្បាប់ដែលពាក់ព័ន្ធ-ផ្ទុយនឹងមាត្រា៤.១ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ដែល បានពិនិត្យសារជាថ្មីឡើងវិញ[15] ។ ការយោងទៅលើកថាខណ្ឌទី១ និងទី២ នៃវិធាន៧៥ នៅក្នុងសេចក្ដីជូនដំណឹងអំពីការដាក់ប្ដឹងឧទ្ធរណ៍[16] មិនអាចចាត់ទុកថា ជាមូលដ្ឋានគតិយុត្តិគ្រប់គ្រាន់សំរាប់សិទ្ធិក្នុង

---

[13] *ករណីរបស់ ខៀវ សំផន,* សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្ដីពី សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី លើការងារបកប្រែ, A190/1/20, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩, កថាខ័ណ្ឌទី៣៣ [*ចាប់ពីនេះតទៅហៅថា* សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការបកប្រែ] ។

[14] សេចក្ដី សម្រេចលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការបកប្រែ, កថាខ័ណ្ឌទី៣៣ ។

[15] មាត្រា៤.១ ចែងថា "តាមករណីសមស្រប ឯកសារដែលដាក់ចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះណាមួយ ត្រូវមានដូចខាងក្រោមនេះ ក. សេចក្ដីផ្ដើមមួយ ដែលមានបញ្ចូលនូវមូលដ្ឋានគតិយុត្តិ និងកម្មវត្ថុនៃការស្នើសុំឱ្យចាត់វិធានការដើម្បីជួសជុលសំណងខូចខាត ។ (..) ឃ. ការធ្វើសេចក្ដីសង្ខេបអត្ថបទគតិយុត្តិ រួមទាំងសម្រង់ប្រភពច្បាប់ដែលទាក់ទងនានា ។ ង. ការអះអាងលំអិតអំពីចំណុចមូលដ្ឋានច្បាប់" ។

[16] សេចក្ដីជូនដំណឹងស្ដីពីការដាក់បណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន, ឯកសារលេខ D130/10, ERN 00360007-10 (ភាសាអង់គ្លេស) ត្រង់លេខ ERN 00360007-10 (ភាសាអង់គ្លេស), ERN 003600010, កថាខណ្ឌទី១ ។

00388432



ការប្តឹងឧទ្ធរណ៍បានទេ ។ កថាខណ្ឌទាំងនោះគឺពាក់ព័ន្ធតែទៅនឹងកាលបរិច្ឆេទកំណត់, បុគ្គលដែលត្រូវដាក់សេចក្តីជូនដំណឹងអំពីការដាក់បណ្តឹងឧទ្ធរណ៍ និងខ្លាតរបស់បណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ ។

៩. ទោះបីជា សហមេធាវីរបស់ ខៀវ សំផន បានបញ្ជាក់ថា "*ពួកគេបានអនុម័តជាមុនទាំងស្រុងនិងដោយគ្មានលក្ខខណ្ឌយកតាមសារណាលើបណ្តឹងឧទ្ធរណ៍របស់មេធាវី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដែលត្រូវធ្វើការដោះស្រាយក៏ដោយ* (ត្រឹមត្រូវតាមច្បាប់ដើម!)"[17] ក៏មិនមែនលើកលែងថា មិនចាំបាច់ឱ្យសហមេធាវីទាំងនោះបញ្ជាក់ប្រាប់ អំពីវិធានផ្ទៃក្នុងដែលបណ្តឹងឧទ្ធរណ៍នោះបានលើកយកមកធ្វើជាមូលដ្ឋាននោះដែរ ។ នេះគឺជាការចាំបាច់ខានមិនបាន ហើយការដែលខកខានមិនបានធ្វើតាមនេះនឹងធ្វើឱ្យ បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ ។ ជាងនេះទៅទៀត ប្រការដែលបញ្ជាក់ថាសហមេធាវីរបស់ ខៀវ សំផន បានគូសបញ្ជាក់ថា "(...) <u>វិធានផ្ទៃក្នុងមិនបានចែងច្បាស់អំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបែបនេះឡើយ</u> (...)"[18] គឺមានប្រយោជន៍ណាស់ ។ ក្នុងការធ្វើដូច្នេះ គឺពួកគេបានធ្វើផ្ទុយពីអំណះអំណាងដែលបានលើកបង្ហាញដោយមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ នៅត្រង់កថាខណ្ឌទី១០ ដល់២២ នៃបណ្តឹងឧទ្ធរណ៍របស់ពួកគេ[19] ហើយពួកគេបានទទួលស្គាល់ដោយខ្លួនឯងថា ខ្លួនគ្មានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដែលត្រូវធ្វើការដោះស្រាយនោះទេ ។ ហេតុដូចនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គបុរេជំនុំជម្រះ ប្រកាសថាបណ្តឹងឧទ្ធរណ៍របស់ខៀវ សំផន គឺមិនអាចឱ្យទទួលយកបានទេព្រោះដោយសារខ្វះមូលដ្ឋានខាងគតិយុត្តិ ។

## ខ. សវនាការសាធារណៈ

[17] បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន កថាខណ្ឌទី៦ ។

[18] បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន, កថាខណ្ឌទី៣ សង្កត់ន័យបន្ថែម ដោយសរសេរថា "បើសិនជាវិធានផ្ទៃក្នុងមិនបានចែងច្បាស់ស្តីពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចបែបនេះ គឺគ្រាន់តែមកពីមិនគួរចេញដីកាដូចនេះទាល់តែសោះប៉ុណ្ណោះ" ។

[19] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១០-២២, នៅពេល មេធាវីការពារក្តីលើកឡើងថា វិធាន៥៥.១០ នៃវិធានផ្ទៃក្នុងបានចែង អំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំប្រឆាំងនឹងសំណើសុំជាទូទៅមួយ ហើយវិធាន២១ ផ្តល់យុត្តាធិការក្នុងការធ្វើសវនាការលើបណ្តឹងឧទ្ធរណ៍នានា ក្នុងចំណោមបញ្ហាដទៃទៀតជាច្រើន នៅពេលដែលសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌របស់ជនត្រូវចោទត្រូវបានរំលោភបំពាន ។

00388433



១០. ដើមបណ្តឹងឧទ្ធរណ៍ ខំព្យាយាមស្នើសុំឱ្យបើកសវនាការដោយផ្ទាល់មាត់ជាសាធារណៈមួយ លើបណ្តឹងឧទ្ធរណ៍នេះ ដែលតាមយោបល់គាត់ថា វាមានលក្ខណៈស្មុគ្រស្មាញ និងជាមូលដ្ឋានគ្រឹះ ។ សហព្រះរាជអាជ្ញា យល់អំពីទំហំនៃការចាប់អារម្មណ៍របស់សាធារណជនចំពោះបណ្តឹងឧទ្ធរណ៍នេះ ដែលបានលើកឡើងនៅក្នុងសហគមន៍ជាតិនិងអន្តរជាតិ ។ សហព្រះរាជអាជ្ញាយល់ឃើញថា សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តី មិនចាំបាច់រួមបញ្ចូលទាំងការធ្វើសវនាការដោយផ្ទាល់មាត់នោះឡើយ ។ គឺសវនាការនោះ អាចរួមបញ្ចូលតែសារណាជាលាយលក្ខណ៍អក្សរមួយ ដែលមានការកំណត់សម្រេចដោយមានការបញ្ជាក់ហេតុផល និងជាសាធារណៈតែប៉ុណ្ណោះបានហើយ[20] ។ នេះគឺជាការអនុវត្តន៍ដែលអង្គបុរេជំនុំជម្រះ ធ្លាប់ធ្វើក្នុងការដាក់បញ្ចូលឯកសារទាំងអស់ដែលភាគីបានដាក់ទៅក្នុងគេហទំព័ររបស់អវតក ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ និងសេចក្តីសម្រេចនានា លើសំណើទាំងនេះ ។ អង្គបុរេជំនុំជម្រះ កម្រចាកចេញពីការអនុវត្តន៍បែបនេះណាស់ លុះត្រាតែផលប្រយោជន៍របស់ភាគីនានា (ជាពិសេសគឺរបស់ជនត្រូវចោទ) ត្រូវទទួលរងការប៉ះពាល់[21] ។ តុលាការអន្តរជាតិនានា ជាធម្មតាគឺគេតែងតែធ្វើសេចក្តីសម្រេចតែនៅលើញត្តិស្នើសុំនិងបណ្តឹងឧទ្ធរណ៍នៅលើសារណាជាលាយលក្ខណ៍អក្សរណ៍តែប៉ុណ្ណោះ ។

១១. ការអនុវត្តន៍ដ៏ច្បាស់លាស់ និងដែលស៊ីសង្វាក់គ្នាមួយបានលេចឡើងស្តីពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ក្នុងការបើកធ្វើសវនាការផ្ទាល់មាត់ ។ អង្គជំនុំជម្រះ បានបើកធ្វើសវនាការដោយផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនទាំងអស់ លើកលែងតែករណីបណ្តឹងឧទ្ធរណ៍មួយក្នុងចំណោមបណ្តឹងឧទ្ធរណ៍ស្តីពីឃុំខ្លួនចេញប៉ុណ្ណោះ[22] ហើយបណ្តឹងឧទ្ធរណ៍ដែលអាចធ្វើឱ្យដំណើរការនៃនីតិវិធីត្រូវបញ្ចប់ នឹងជាផលវិបាកគឺអាចបណ្តាលឱ្យ

---

[20] *ករណីរឿងរបស់ Jussila ទល់នឹង ប្រទេសហ្វាំងឡង់* សាលដីកា, បណ្តឹងឧទ្ធរណ៍លេខ ៧៣០៥៣/០១, អង្គជំនុំជម្រះធំនៃតុលាការសិទ្ធិមនុស្សសម្រាប់ទ្វីបអឺរ៉ុប, ថ្ងៃទី២៣ វិច្ឆិកា ២០០៦, កឋាខណ្ឌទី៤១ ។

[21] *ករណីរឿងរបស់ អៀង សារី,* ដែលសម្រេចអនុលោមតាមមាត្រា៣.១២ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារៈ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីពីការតែងតាំងអ្នកជំនាញមួយរូប, ចុះថ្ងៃទី២៤ កក្កដា ២០០៨, A189/1/6, កថាខណ្ឌទី៤ ។

[22] អង្គបុរេជំនុំជម្រះបាន ធ្វើសវនាការដោយផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ ដើមដំបូង ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ចំនួន៥ របស់ជនជាប់ឃុំឃាំងទាំង៥រូប នៃតុលាការនេះ ។ បន្ទាប់មកទៀត អង្គបុរេជំនុំជម្រះ បានធ្វើសេចក្តីសន្និដ្ឋាននៅក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង ធីរិទ្ធិ, អៀង សារី, និង ខៀវ សំផន។ តាមការយល់ព្រមរបស់ភាគីនានា បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់ នួន ជា ត្រូវបានកំណត់សម្រេចធ្វើតែនៅលើសារណាជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ ។

00388434



ត្រូវធ្វើការដោះលែងជនត្រូវចោទ[23] ។ ជាសរុបមកសេរីភាពរបស់ជនត្រូវចោទណាម្នាក់ គឺជាការដែលត្រូវបានអង្គជំនុំជម្រះយកចិត្តទុកដាក់ខ្លាំងបំផុតនៅក្នុងការកំណត់សំរេចអំពីថាតើត្រូវបើកធ្វើសវនាការជាសាធារណៈ ដែរឬក៏អត់[24]? សហព្រះរាជអាជ្ញា ទុកឱ្យអង្គបុរេជំនុំជម្រះប្រើប្រាស់ឆន្ទានុសិទ្ធិដើម្បីសម្រេចថាតើ បណ្តឹងឧទ្ធរណ៍នេះគួរតែត្រូវបានកំណត់ដោយឈរលើមូលដ្ឋាន នៃការចេញសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឬក៏សវនាការជាសាធារណៈ។

## គ. អង្គហេតុដែលពាក់ព័ន្ធនានា

១២. ដើមបណ្តឹងឧទ្ធរណ៍បានគូសបញ្ជាក់នៅត្រង់កថាខណ្ឌទី៤ នៃបណ្តឹងឧទ្ធរណ៍របស់គាត់ថា សហព្រះរាជអាជ្ញា បានលើកឡើងយោងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅលើចម្លើយសារភាព ព្រមទាំងឯកសារផ្សេងៗទៀតជាច្រើន[25] ដែលស្ថិតនៅក្នុងប្រភេទឯកសារដែលបានមកដោយសារការធ្វើទារុណកម្ម ។ មេធាវីការពារក្តីបានបកស្រាយថារាល់ចម្លើយសារភាពទាំងអស់ដែលលើកឡើងជាសំអាងនៅក្នុងទាំង៦៩នោះ ក្នុងចំណោមលេខយោងជើងទំព័រសរុបទាំងអស់ចំនួន៥៧២ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នឹងត្រូវបានសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត យកមកធ្វើជាខ្លឹមសារដ៏មានសារៈសំខាន់របស់ខ្លួន ។ ម្យ៉ាងទៀត មេធាវីការពារក្តីបានលើកឡើងថា ចម្លើយសារភាពទាំងនេះ គឺគ្រាន់តែជាការទទួលស្គាល់អំពីទោសកំហុសដោយ ជនជាប់ឃុំឃាំងនៅមន្ទីរស-២១ តែប៉ុណ្ណោះ លើសពីនេះទៀត តាមពិតគឺឯកសារទាំងនេះមានលក្ខណៈវែងអន្លាយ និងស្មុគស្មាញខ្លាំងដែលត្រូវបានប្រើប្រាស់ដើម្បីបង្ហាញនូវព័ត៌មានដោយផ្ទាល់ និងដោយប្រយោលជាច្រើនប្រភេទខុសៗគ្នា ។ មុនពេលពិភាក្សា លើបញ្ហានានាខាងអង្គច្បាប់គឺចាំបាច់ត្រូវតែបញ្ជាក់ឱ្យច្បាស់លើបញ្ហានេះ ។

---

[23] *ករណីរឿងរបស់ ខៀវ សំផន*, សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន ដែលសុំឱ្យធ្វើសវនាការជាសាធារណៈមួយ, ចុះថ្ងៃ ទី៤ វិច្ឆិកា ២០០៨, ឯកសារលេខ A190/1/8, កថាខណ្ឌទី៨ ។ នេះគឺជាការឆ្លុះបញ្ចាំងអំពីគោលបំណងនៃវិធាន៧៧.៦ នៃ វិធានផ្ទៃក្នុង ដែលចែងថា សវនាការត្រូវធ្វើឡើងជាសាធារណៈ "*ជាពិសេស នៅពេលដែលសំណុំរឿងនោះត្រូវបានបញ្ចប់ដោយ សេចក្តីសម្រេចរបស់ [អង្គបុរេជំនុំជម្រះ]*" ។

[24] *ករណីរឿងរបស់ ខៀវ សំផន*, សេចក្តីសម្រេចលើសំណើរបស់ សហព្រះរាជអាជ្ញា ដែលសុំឱ្យកំណត់សម្រេចលើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងដីកាសម្រេចស្តីពីការកំណត់ថ្ងៃសវនាការ, ចុះថ្ងៃទី៦ កុម្ភៈ ២០០៩, ឯកសារលេខ C26/5/13 ។

[25] "ឯកសារផ្សេងៗទៀតទាំងនេះ" មិនត្រូវបានដើមបណ្តឹងឧទ្ធរណ៍ផ្តល់ការរៀបរាប់ ឬផ្តល់អត្តសញ្ញាណជាបន្ថែមទៀតនៅក្នុង លេខយោងជើងទំព័រទាំងនោះឡើយ ។

១៣. នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហព្រះរាជអាជ្ញា មិនដែលពឹងផ្អែកទៅលើចម្លើយនានាដែលមាននៅក្នុងចម្លើយសារភាព ដែលរិធានស្តីពីការបដិសេធភស្តុតាងនៃអំពើទារុណកម្មមានបំណងផ្តោតជាចំបងនោះទេ - ចម្លើយសារភាពដោយបង្ខំអំពីសកម្មភាពក្បត់ដែលបានធ្វើឡើងដោយជនរងគ្រោះ ។ ផ្ទុយមកវិញ តាមការពិតមានចម្លើយសារភាពយ៉ាងតិចចំនួន៣៨ ដែលបានលើកឡើងនៅក្នុងលេខយោងជើងទំព័រលេខ ៨ នៃបណ្តឹងឧទ្ធរណ៍ ត្រូវបានសហព្រះរាជអាជ្ញាប្រើនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដើម្បីបង្ហាញឱ្យឃើញការពិតថា ចម្លើយទាំងនោះគឺត្រូវបានធ្វើឡើងដោយជនរងគ្រោះ ដែលមានបញ្ជាក់អត្តសញ្ញាណនៅក្នុងឯកសារទាំងនោះនៅក្នុងមណ្ឌលសន្តិសុខ ជាពិសេសណាមួយ ដែលជាលទ្ធផលគឺបង្ហាញសក្ខីកម្ម អំពីវត្តមានរបស់ពួកគេនៅក្នុងមណ្ឌលសន្តិសុខ មុនពេលចាប់ខ្លួននិងការឃុំខ្លួន និង/ឬ អំពីការប្រហាជីវិតរបស់ពួកគេនៅពេលជាបន្ទាប់មកទៀត[26] ។ ចម្លើយដទៃក្រៅពីនេះជាច្រើនទៀតត្រូវបានយកមកប្រើ ពីព្រោះនៅលើចម្លើយទាំងនោះ មានចំណាររបស់មន្ត្រីផ្លូវការនៃមណ្ឌលសន្តិសុខឬរបស់កម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត[27]។ ចំណារទាំងនោះ មិនមែនបានមក ដោយសារលទ្ធផលនៃការធ្វើទារុណកម្មទេ ។ មានចម្លើយសារភាពផ្សេងៗពីនេះទៀត ដែលត្រូវគេបានយកខ្លឹមសាររបស់វាតែចំណែកតូចៗមកប្រើប៉ុណ្ណោះ ដើម្បីយកបញ្ជាក់ការពិតដែលមានភាពស៊ីសង្វាក់គ្នា ស្តីពីភស្តុតាងទាក់ទងនឹងការមិនមានធ្វើទារុណកម្ម ឬជាភស្តុតាងនាំមុខ ដើម្បីសហចៅក្រមស៊ើបអង្កេតអាចទទួលបានបន្ថែម

---

[26] សូមអាន ឧទាហរណ៍ដូចជា លេខយោងជើងទំព័រនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលមានលេខ ៨២, ១១៩, ១៧៨, ១៧៩, ១៨០, ១៨២, ១៨៣, ២០៣, ២១៦, ៣៥០, ៣៥៥, ៣៥៦, ៣៩២, ៣៩៨, ៤២០, ៤២៥, ៤២៧, ៤៣២, ៤៣៣, ៤៥៧, ៤៥៩, ៤៦០, ៤៦១, ៤៦២, ៤៦៣ ,៤៦៥, ៤៦៦, ៤៦៧, ៥១៩, ៥២០, ៥៣០, ៥៣១, ៥៣២, ៥៣៣, ៥៣៧ , ៥៣៨, ៥៣៩ , និង ៥៤១ ។ ឧទាហរណ៍ដូចជា លេខយោងជើងទំព័រ លេខ៥២០ លើកឡើងពីចម្លើយសារភាពចំនួន៩ របស់បុគ្គលិកនៃ ក-២ ដើម្បីបង្ហាញឱ្យឃើញថា មានបុគ្គលិករបស់ អៀង ធីរិទ្ធ ជាច្រើនត្រូវបានគេចាប់ខ្លួន ហើយបង្ខំឱ្យឆ្លើយសារភាពនៅមន្ទីរស-២១ ។

[27] សូមអាន ឧទាហរណ៍ដូចជា លេខយោងជើងទំព័រនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលមានលេខ ១៧៧, ២០៣, ២១៦, ៣៣៧, ៣៤៥, ៣៥៦, ៣៥៧, ៣៨៤, ៣៩២, ៣៩៨, ៤០០, ៥៤១, ៥៥៥, និង ៥៥៨ ។ លេខយោងជើងទំព័រ លេខ២១៦ លើកឡើងពីចម្លើយសារភាពរបស់ឈ្មោះ ពឹង ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញឱ្យឃើញថា មានអ្នកទោសជាច្រើននាក់ដែលត្រូវគេធ្វើទារុណកម្មរហូតដល់ស្លាប់តាមរយៈចំណារមួយរបស់ ឌុច ដែលសរសេរថា អ្នកទោសបានស្លាប់ នៅមុនពេល ដែលចម្លើយសារភាពត្រូវបានចប់សព្វគ្រប់ ។

00388436



ទៀតនូវភស្តុតាងដែលទាក់ទងនឹងការមិនមានការធ្វើទារុណកម្ម[28] ។ មិនមានចម្លើយសារភាពណាក្នុង ចំណោមចម្លើយសារភាពទាំងនោះ ត្រូវបានប្រើប្រាស់ដើម្បីបង្ហាញការពិតតាមអង្គហេតុ "ថ្មីៗ" ឬអំពីការជាប់ទាក់ទងទៅនឹងខ្សែបណ្តាញក្បត់នានានោះឡើយ ។ មានចម្លើយសារភាពមួយត្រូវបានគេប្រើប្រាស់ ដើម្បីបង្ហាញឱ្យឃើញច្បាស់ពីអង្គហេតុដែលថា ចម្លើយសារភាពទាំងនោះត្រូវបានគេផ្សាយតាមវិទ្យុ និងនៅក្នុងអង្គប្រជុំជាសាធារណៈនានា[29] រីឯលេខយោងជើងទំព័រពីរផ្សេងទៀតនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលលើកមកសំអាងដោយដើមបណ្តឹងឧទ្ធរណ៍ មិនមានការយោងណាមួយទៅលើចម្លើយសារភាព ឬឯកសារផ្សេងៗដែលក្នុងនោះមានការចោទប្រកាន់ថា មានស្លាកស្នាមនៃការធ្វើទារុណកម្មទេ[30] ។ ការបញ្ជាក់បំភ្លឺ*បែបនេះ* គឺនឹងអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះ បង្រួមឱ្យកាន់តែតូចថែមទៀតនូវបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ ។

## ឃ. ចរិតលក្ខណៈលឿនមុនពេលពេកនៃបណ្តឹងឧទ្ធរណ៍

១៤. អង្គបុរេជំនុំជម្រះ គួរតែធ្វើសវនាការលើបណ្តឹងឧទ្ធរណ៍ដែលតវ៉ាជំទាស់អំពីភាពអាចទទួលយកបាននៃភស្តុតាង ជាពិសេសណាមួយក្នុងចំណោមភស្តុតាងនានា ។ វិធាន៧៤.៣.ខគ្រាន់តែអនុញ្ញាតឱ្យធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនានា "ដែលបដិសេធលើសំណើសុំបំពេញកិច្ចស៊ើបសួរតែប៉ុណ្ណោះ" ហើយមិនអនុញ្ញាឱ្យធ្វើបណ្តឹងឧទ្ធរណ៍ស្តីពីភាពមិនអាចទទួលយកបាននៃចំណែកនៃភស្តុតាងជាក់លាក់ ដែលមាននៅក្នុងសំណុំរឿងទេ ។ ហេតុដូចនេះ សហព្រះរាជអាជ្ញា សន្និដ្ឋានថា ភាពទទួលយកបាន និងការអនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងនៃចម្លើយសារភាពនៅមន្ទីរស-២១ គួរតែត្រូវបានសម្រេចដោយអង្គជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃករណីរឿងម្តងមួយៗ ដែលសេចក្តីសម្រេចនេះ នឹងត្រូវដាក់ឱ្យពិនិត្យសារឡើងវិញដោយអង្គជំនុំជម្រះតុលាការកំពូល ។ ដើម្បីសម្រេចលើបញ្ហាទាំងនេះនៅក្នុងដំណាក់កាលមុនជំនុំជម្រះក្តី

---

[28] សូមអាន ឧទាហរណ៍ដូចជា លេខយោងជើងទំព័រនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលមានលេខ៨០, ៨២, ៣៣៥, ៣៤០, ៣៤៥, ៣៥០, ៣៥៥, ៣៧៥, ៣៧៦, ៣៩១, ៣៩២, ៣៩៣, ៣៩៩, ៤០០, ៤១០, ៤១៦, ៤១៧, ៤១៩, ៤២០, ៤៩០, និង ៥៥២ ។ ឧទាហរណ៍ដូចជា វគ្គដកស្រង់នៃចម្លើយសារភាពរបស់ ហ៊ូ នឹម បានលើកឡើងនៅក្នុងលេខយោងជើងទំព័រលេខ៨០ អំពីអង្គហេតុនានា ដែលបានដឹង ដូចជាអំពីសក្តិ និងមុខតំណែងរបស់បងៗខាងលើ រីឯលេខយោងជើងទំព័រលេខ ៣៧៥វិញ ផ្តល់នូវសេចក្តីលំអិត និងដែលបញ្ជាក់ការពិតស៊ីសង្វាក់គ្នាអំពីរចនាសម្ព័ន្ធរបស់បក្ស និងរបស់ស្ថាប័ន និងផ្នែកនានាដែលជាសាខា ។

[29] លេខយោងជើងទំព័រនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, លេខ៥៦៦ ។

[30] លេខយោងជើងទំព័រនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, លេខ១៨១ និង៤៥៨ ។

គឺជាការលឿងមុនពេលពេក ជាពិសេស គឺដោយសារថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បានថែងយ៉ាងច្បាស់ថា ភាពទុកចិត្តបាននៃចម្លើយសារភាពនានា "មិនអាចត្រូវបានប៉ាន់ស្មានវាយតម្លៃបានទេ រហូតទាល់តែកិច្ចស៊ើបសួរត្រូវចប់"[31] ។ អង្គបុរេជំនុំជម្រះ មិនមានព័ត៌មានតាមលក្ខខណ្ឌតម្រូវ ដើម្បីធ្វើសេចក្ដីសម្រេចដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយនៅក្នុងដំណាក់កាលនេះបានទេ បើភស្តុតាងដែលត្រូវបានតវ៉ាជំទាស់ មិនទាន់ត្រូវបានគេជឿទុកចិត្តសម្រាប់គោលបំណងណាមួយនៅឡើយ កុំថាឡើយដល់ទៅព័ត៌មានអំពីការមិនអនុវត្តន៍តាមមាត្រា១៥ ។ មានចម្លើយសារភាពជាច្រើនប្រវែងរហូតដល់រាប់រយទំព័រដែលមានន័យថាចម្លើយទាំងនេះមានសក្ដានុពលសម្រាប់ប្រើប្រាស់ជាភស្តុតាងយ៉ាងសម្បូរណ៍បែបដែលចម្លើយសារភាព អនុសញ្ញា CAT អាចអនុញ្ញាតបាន និងមួយចំនួនទៀតមិនអាចអនុញ្ញាតបានទេ ។ បើសិនជាគេប្ដឹងមកអង្គជំនុំជម្រះសាលាដំបូង នោះមុខជានឹងក្លាយជាវេទិកាជំនុំជម្រះក្ដីលើបញ្ហានេះ បានប្រសើរជាងឆ្ងាយណាស់ ហើយមេធាវីការពារក្ដីនឹងមានជម្រើសក្នុងការតវ៉ាជំទាស់អំពីការប្រើប្រាស់ជាក់លាក់ នូវចម្លើយសារភាពមន្ទីរស-២១ ក្នុងពេលនោះ ។

១៥. ពីព្រោះតែគ្មានស្ថាប័នតុលាការណាមួយជឿទុកចិត្ត ឬធ្វើសេចក្ដីសម្រេចទៅលើភស្តុតាងណាមួយដែលមេធាវីការពារក្ដីចោទប្រកាន់ថា បានមកដោយសារការធ្វើទារុណកម្មនោះ បណ្ដឹងឧទ្ធរណ៍ កំពុងស្នើសុំឱ្យធ្វើសេចក្ដីសម្រេចមួយដែលមានលក្ខណៈជាសេចក្ដីប្រកាស ទៅលើអត្ថន័យនៃមាត្រា១៥ នៃអនុសញ្ញា[32] CAT ។ កាលពីមុននេះ អង្គបុរេជំនុំជម្រះបាន សម្រេចថាខ្លួននឹងមិនចេញនូវសេចក្ដីសម្រេចដែលមានលក្ខណៈជាសេចក្ដីប្រកាស ឬដីកាសម្រេចទេ[33] ហេតុនេះហើយ អង្គបុរេជំនុំជម្រះមិនគួរធ្វើដូច្នេះនៅទីនេះឡើយ ។

## ខ. ភាពមិនអាចអនុវត្តបាននៃច្បាប់ដែលបានពឹងផ្អែកដោយមេធាវីការពារក្ដី

[31] ដីកាសម្រេចស្ដីពីភស្តុតាងនៃការធ្វើទារុណកម្ម, កថាខ័ណ្ឌទី ២៨ ។

[32] បណ្ដឹងឧទ្ធរណ៍គឺផ្អែកតែលើការអះអាងខាងផ្នែកទ្រឹស្ដីនិងទស្សនវិជ្ជាតែប៉ុណ្ណោះដែលធ្វើ ឱ្យការត្រួតពិនិត្យរបស់ អបជ មិនអាចធ្វើទៅបានទេ។ មិនមានការផ្ដល់សេចក្ដីលំអិតអំពី ការប្រើប្រាស់ជាក់ស្ដែងនូវឯកសារនានាដែលមេធាវីស្នើសុំឱ្យចាត់ទុកថាមិនអាចទទួលយកបាននោះទេ ហើយដែលសុំឱ្យដកចេញពីសំណុំរឿងលេខ០០២។បណ្ដឹងឧទ្ធរណ៍នេះមានភាពមិនច្បាស់លាស់ និងមិនបានបញ្ជាក់ពីភស្តុតាងដោយឡែកណាមួយដែលបានមកពីការធ្វើទារុណកម្ម ទល់និង ភស្តុតាងដែលបានមកដោយមិនមានការធ្វើទារុណកម្មនោះទេ។

[33] *ករណីរឿងក្ដីរបស់ ឌុច,* សេចក្ដីសម្រេចស្ដីពីសេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីការផ្ទេរសិទ្ធិអំណាចក្នុងបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេចស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី២០វិច្ឆិកា២០០៧, សំណុំរឿងលេខ ០០១/១៨-០៨-២០០៧, ឯកសារលេខ C23, កថាខណ្ឌទី៤ ។

00388438



១៦. អបជ គួរតែបដិសេធចោលភាគច្រើនបំផុតតាមច្បាប់កម្ពុជា[34] យុត្តិសាស្ត្រអន្តរជាតិ[35] របាយការណ៍[36] និងសំណេររបស់បណ្ឌិតស្រាវជ្រាវ[37] ដែលបានលើកយោងដោយមេធាវីការពារក្តី[38]

---

[34] ច្បាប់កម្ពុជា ដែលបានលើកយោងដោយមេធាវីការពារក្តី គឺវាត្រឹមត្រូវតាមតក្កវិជ្ជាដែលគាំទ្រទៅលើពាក្យសុំដែលថា ការហាមឃាត់ការប្រើប្រាស់ភស្តុតាងនេះ គឺផ្តោតទៅលើការប្រើប្រាស់ប្រឆាំងនឹងជនរងគ្រោះដោយអំពើទារុណកម្ម (មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល (អ៊ុនតាក់) ឆ្នាំ១៩៩២ មិនពាក់ព័ន្ធទេ ។

[35] *ក និងអ្នកដទៃទៀត ទល់នឹង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ* (២០០៥), សភាជាន់ខ្ពស់នៃចក្រភពអង់គ្លេស លេខ៥៦, សាលក្រមចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០០៥, ភាពអាចទទួលយកបាននៃភស្តុតាងអំពីការធ្វើទារុណកម្ម ដែលទទួលបាននៅបរទេស ប្រឆាំងនឹងបុគ្គលដែលជាប់ចោទអំពីអំពើភេរវកម្ម នៅចំពោះមុខតុលាការអង់គ្លេស ត្រូវបានលើកយកពិភាក្សា ។ ភស្តុតាងនេះ មិនត្រូវបានគេប្រើប្រាស់ប្រឆាំងនឹងអ្នកប្រព្រឹត្តអំពើទារុណកម្មទេ ។ *ករណីរឿងក្តី អាល្លឺម៉ង់ ទល់នឹង Mounir el Motassadeq,* សេចក្តីសម្រេចរបស់តុលាការយុត្តិធម៌សហព័ន្ធអាល្លឺម៉ង់ (German Federal Court of Justice), ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥, 3 StR 218.03, ដែលពិភាក្សាទៅលើបញ្ហាតែមួយគត់ គឺភាពអាចទទួលយកបាននៃភស្តុតាង ប្រឆាំងនឹងជនជាប់ចោទ ដែលអាចទទួលបានដោយការធ្វើទារុណកម្ម (តាមការពិត ការបាត់ខ្លួនដោយបង្ខំ និងការដាក់ឲ្យជាប់ក្នុងមន្ទីរឃុំឃាំងអស់រយៈពេលយ៉ាងវែង *ដោយគ្មានមធ្យោបាយនៃការប្រាស្រ័យទំនាក់ទំនងណាមួយ* គឺស្មើនឹងការធ្វើទារុណកម្ម) ពីជនសង្ស័យបីនាក់ដែលជាសមាជិកអាល់កៃដា ដែលចាប់ដាក់ឃុំដោយសហរដ្ឋអាមេរិក ។ ការណ៍នេះជាថ្មីម្តងទៀត ភស្តុតាងត្រូវបានគេប្រើប្រាស់ប្រឆាំងនឹងជនទីបី ដែលជាប់ចោទពីបទអំពើភេរវកម្ម មិនមែនប្រឆាំងនឹងអ្នកប្រព្រឹត្តអំពើទារុណកម្មទេ ។

[36] <u>របាយការណ៍របស់គណៈកម្មាធិការប្រឆាំងអំពើទារុណកម្ម</u> ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣ គ្រាន់តែបានគិតទុកជាមុនអំពីវិសាលភាពនៃវិធានបដិសេធ មិនមែនការលើកលែងដូចក្នុងមាត្រា១៥ ទេ ។ អនុសាសន៍របស់គណៈកម្មាធិការនេះ ចំពោះកម្ពុជា ចំពោះការបដិសេធភស្តុតាងនៃអំពើទារុណកម្ម គឺដោយបានឈរលើការពិតដែលថា នគរបាល និងតុលាការកម្ពុជា បានពឹងផ្អែកខ្លាំងពេកទៅលើ *ចម្លើយសារភាព ដើម្បីធានាដល់ការដាក់ទោសប្រឆាំងនឹងជនណាម្នាក់ដែលបានធ្វើទារុណកម្ម* [សង្កត់ធ្ងន់ ត្រង់អក្សរទ្រេត] ។ អនុសញ្ញា CAT, សេចក្តីសន្និដ្ឋាន និងអនុសាសន៍នានារបស់គណៈកម្មាធិការប្រឆាំងការធ្វើទារុណកម្ម, កម្ពុជា, ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៣, ឯកសារលេខ CAT/C/CR/30/2, កថាខ័ណ្ឌទី៦.ជ, ៧.ច ដែលអនុវត្តដូចគ្នាទៅនឹងរបាយការណ៍ <u>ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (UN Human Rights Council)</u> ដែលបានលើកយោងដោយមេធាវីការពារក្តី ត្រង់កថាខ័ណ្ឌទី១០៦, កំណត់សំគាល់ចុងទំព័រលេខ ៧៥ និងរហូតដល់ចំណុច J. Barber ដែលលើកយោងនៅក្នុងបណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១០៥, កំណត់សំគាល់ចុងទំព័រលេខ ៧៣: "ជនប្រព្រឹត្តអំពើទារុណកម្ម (នៅកម្ពុជា) ដឹងថា ពួកគេមិនទំនងជាត្រូវគេផ្តន្ទាទោសនោះឡើយ" ។ ជាការច្បាស់ណាស់ថា ហេតុអ្វីបានជានិទណ្ឌភាពនៅកម្ពុជា ត្រូវតែដាក់ឲ្យដល់ទីអវសាន ចំពោះជនណាដែលទទួលការចោទប្រកាន់អំពីការធ្វើទារុណកម្មនៅក្នុងប្រទេសកម្ពុជា ដោយចាប់ផ្តើមជាមួយនឹងខ្មែរក្រហម ។ របាយការណ៍ <u>Redress</u> Report ឆ្នាំ២០០៥, ក៏មានការបារម្ភជាចំបងទៅលើតែការប្រើប្រាស់ចម្លើយសារភាពនៃការធ្វើទារុណកម្ម ប្រឆាំងនឹងអ្នកដែលទទួលរងអំពើទារុណកម្ម និងថា ហេតុដូច្នេះបានកត់សំគាល់ថា ការប្រើប្រាស់ចម្លើយសារភាព "គ្រាន់តែលើកទឹកចិត្តលើបច្ចេកទេសនៃការសួរចម្លើយដែលជាលទ្ធផលបង្កើតបានជាអំពើទារុណកម្ម" និងថា *អ្នកជាប់ឃុំឃាំង* គួរតែត្រូវបានគេជូនដំណឹងអំពីសិទ្ធិមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង: Redress, *ការនាំយកបំរាមអន្តរជាតិនៃការធ្វើទារុណកម្ម ត្រឡប់មកផ្ទះវិញ: គោល*

ថាមិនអាចអនុវត្តបាន សម្រាប់ធ្វើការកំណត់សម្រេចលើបញ្ហានានាដែលបាន លើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ។ បញ្ហាច្បាស់លាស់នៅចំពោះមុខតុលាការនេះ -- អំពីវិសាលភាពដែលកំណត់ហេតុសួរចម្លើយ ដែលរួមមានចម្លើយសារភាពបានមកដោយ ការធ្វើទារុណកម្មអាចត្រូវបានប្រើប្រាស់ ដើម្បីចោទប្រកាន់ភាគីទាំងឡាយដែលទទួលខុស ត្រូវចំពោះការធ្វើទារុណកម្ម ដែលកន្លងមិនធ្លាប់បានលើកយកមកដោះស្រាយនៅចំពោះតុលាការអន្តរជាតិ ឬ

---

*ការណែនាំនៃអង្គការសហប្រជាជាតិ សម្រាប់ការអនុវត្តន៍ថ្នាក់ជាតិ សម្រាប់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងអំពើឃោរឃៅផ្សេងទៀត ការធ្វើបាបដោយអមនុស្សធម៌ ឬ អំពើបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម,* (*Bringing the International Prohibition of Torture Home: National Implementation Guide for the UN Convention Against Torture and Other Cruel, Inhuman or Degrading Treatment or Punishment,*) The Redress Truth: ទីក្រុងឡុងដ៍, (មករា ២០០៦), ទំព័រ៦២-៦៣ (ចាប់ពីនេះតទៅហៅថា "របាយការណ៍ Redress") ។

[37] T. Thienel មិនបានផ្តោតទៅលើអត្ថបទរបស់គាត់អំពីការលើកលែង ដែលមានចែងនៅក្នុងមាត្រា១៥ នោះទេ ប៉ុន្តែបានផ្តោតទៅលើតែវិធានបដិសេធភស្តុតាងតែមួយប៉ុណ្ណោះ ដែលគាត់ផ្តល់យោបល់ករណី ក និងករណីដទៃផ្សេងទៀត និងការរៀបរាប់អំពីស្ថានភាពចំនួន៤ប្រភេទ អំពីការប្រើប្រាស់ភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្មនៅក្នុង: ក) តុលាការនៃរដ្ឋមួយរបស់អ្នកប្រព្រឹត្តអំពើទារុណកម្មប្រឆាំងនឹងជនដែលទទួលរងការធ្វើទារុណកម្ម (ករណីជាគំរូយ៉ាង); ខ) តុលាការនៃរដ្ឋមួយរបស់អ្នកប្រព្រឹត្តអំពើទារុណកម្ម ប្រឆាំងនឹងជនណាម្នាក់ដែលមិនមែនជាជនរងគ្រោះនៃអំពើទារុណកម្ម (ភាគីទីបី); គ) នៅតុលាការនៃរដ្ឋមួយដែលមិនពាក់ព័ន្ធក្នុងអំពើទារុណកម្ម (ប៉ុន្តែជាថ្មីម្តងទៀត គឺវាប្រឆាំងនឹងជនរងគ្រោះនៃអំពើទារុណកម្ម ឬភាគីទីបីណាមួយ) និង ឃ) តុលាការនៃរដ្ឋមួយបានជាប់ជំពាក់ទៅក្នុងអំពើទារុណកម្ម: T. Thienel, *ភាពអាចទទួលយកបាននៃភស្តុតាងដែលបានទទួលដោយ ការធ្វើទារុណកម្មនៅក្រោមច្បាប់អន្តរជាតិ (The Admissibility of Evidence Obtained by Torture under International Law),* ទិនានុប្បវត្តិអឺរ៉ុបស្តីពីច្បាប់អន្តរជាតិ (European Journal of International Law), 17, 349 (2006) ។ ស្រដៀងគ្នានេះដែរ <u>របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីអំពើទារុណកម្ម</u> ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ (A/61/259) ធ្វើកិច្ចផ្តាច់មុខទៅលើតែវិធានបដិសេធភស្តុតាងនៃមាត្រា១៥ (និងជាចំបងអំពីបន្ទុកនៃភស្តុតាងដែលអំពើទារុណកម្មត្រូវបានអនុវត្ត) និង មិនមែនអំពីការបកស្រាយលើការលើកលែងរបស់វានោះទេ ។ ផ្ទុយមកវិញ <u>Michael Scharf</u> បានពិភាក្សា លើភាពអាចទទួលយកបាន នៃភស្តុតាងប្រឆាំងនឹងអ្នកប្រព្រឹត្តអំពើទារុណកម្ម នៅក្នុង M. Scarf, អាគតដ្ឋានដ៏សៅហ្មង *(Tainted Provenance): ប្រសិនបើមាន តើនៅពេលណាទើបភស្តុតាងនៃអំពើទារុណកម្មអាចទទួលយកបាន?* នៅក្នុង 65 Wash & Lee L. ច្បាប់វិសោធនកម្មលើកទី១២៩ (សិសិររដូវ ២០០៨) ។ អត្ថបទរបស់សាស្ត្រាចារ្យ <u>Pattenden</u> ដែលបានលើកយោងនៅក្នុងបណ្តឹងឧទ្ធរណ៍ ត្រង់កថាខ័ណ្ឌទី៦១, កំណត់សំគាល់ចុងទំព័រលេខ៤៦, ពិភាក្សាភាគច្រើនទៅលើភាពអាចទទួលយកបាននៃភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្មរបស់ភាគីទីបីណាមួយ ។

[38] បណ្តឹងឧទ្ធរណ៍ កថាខ័ណ្ឌដែលគួរឱ្យកត់សំគាល់ គឺកថាខ័ណ្ឌទី២៥, ២៦ និង៣៧ ដល់ ៤០ ។ ទោះបីវិធាន៩៥ នៃវិធាន ស្តីពីនីតិវិធី និងភស្តុតាង នៃតុលាការ ICTY និង ICTR បានលើកយោងដោយមេធាវីការពារក្តី ទាក់ទិននឹងករណីជាគំរូយ៉ាងអំពីរដ្ឋមួយឬមន្ត្រីតុលាការនានា ដែលប្រើប្រាស់អំពើទារុណកម្មប្រឆាំងនឹងជនណាម្នាក់ ដើម្បីទទួលបានភស្តុតាងដែលត្រូវយកទៅប្រើប្រាស់ប្រឆាំងនឹងជននោះ ឬភាគីទីបី ក៏ដោយ ។

00388440



តុលាការជាតិណាមួយនោះ[39] ។ គោលការណ៍ច្បាប់ជាមូលដ្ឋាន គឺថា របកគំហើញផ្នែកច្បាប់ដែលទាញចេញពីស្ថានភាពនៃអង្គហេតុ ដែលអាចឲ្យគេបែងចែកដាច់ពីគ្នាបានពីបញ្ហានៅក្នុងដៃគឺមិនអាចអនុវត្តបានទេ ដោយសារអង្គហេតុខុសៗគ្នានាំឲ្យមានលទ្ធផលផ្នែកច្បាប់ខុសៗគ្នា ។ ប្រភពច្បាប់យោងទាំងឡាយដែលមានមេធាវីការពារក្តីបានផ្អែកនៅក្នុងបណ្តឹងឧទ្ធរណ៍ គឺមានសុទ្ធតែយកចេញពីគំរូបរិបទខុសគ្នាទាំងស្រុងពីករណីនេះ។

១៧. ជាពិសេស ដើមបណ្តឹងឧទ្ធរណ៍លើកយោងច្បាប់ និងឯកសារគតិយុត្តិផ្សេងទៀតដែលមានដើមកំណើតចេញពីគំរូដូចតទៅៈ **រដ្ឋ ក** ធ្វើទារុណកម្មទៅលើជនត្រូវចោទឈ្មោះ **ខ** និងបន្ទាប់មកស្វែងរកការប្រើប្រាស់ ភស្តុតាងដែលបានមកដោយអំពើទារុណកម្មប្រឆាំងនឹងចុងចោទ **ខ** ឬ ចុងចោទណាម្នាក់ផ្សេងទៀត[40] ។ ផ្ទុយមកវិញ នៅក្នុងករណីនេះ តុលាការអន្តរជាតូបនីយកម្មមួយដែលមិនមានទំនាក់ទំនងទៅនឹង **រដ្ឋ ក** ព្យាយាមស្នើសុំប្រើប្រាស់ឯកសារទាំងនេះដើម្បីជួយក្នុងការបង្ហាញភស្តុតាង អំពីការកំណត់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់មន្ត្រីផ្លូវការនៃរដ្ឋាភិបាលរបស់**រដ្ឋ ក** ដែលត្រូវទទួលខុសត្រូវចំពោះការធ្វើទារុណកម្ម ។ ប្រភពច្បាប់យោងទាំងឡាយដែលលើកសំអាងដោយមេធាវីការពារក្តី រួមមានអង្គហេតុជាមូលដ្ឋានខុសគ្នាពីករណីរឿងបច្ចុប្បន្ន ដែលអង្គបុរេជំនុំជម្រះគួរតែផ្តល់ទម្ងន់តែបន្តិចបន្តួចតែប៉ុណ្ណោះទៅលើប្រភពច្បាប់យោងទាំងនោះ ។

## ៤. អំពីច្បាប់

### ក. វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក

១៨. វិធាន ៨៧.១ ចែងថា៖ “លើកលែងតែមានបទបញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក” ។ តាមវិធាន៨៧.៤ អង្គជំនុំជម្រះអាច “កោះហៅឬស្តាប់ចម្លើយ

[39] អង្គហេតុតែមួយប៉ុណ្ណោះ គាំទ្របានតែការសន្និដ្ឋានដែលថា ការសម្រេចលើបញ្ហានេះតម្រូវឲ្យមានការបកស្រាយ និងការវិភាគជាងតម្រូវការដែលមេធាវីការពារក្តីបានតវ៉ា ។

[40] យោងតាម Thienel, ស្ថានភាព “ជាតួរយ៉ាង” គឺនៅពេលដែលអាជ្ញាធរប្រើប្រាស់អំពើទារុណកម្ម ដើម្បីទទួលបានភស្តុតាងសម្រាប់កិច្ចដំណើរការនីតិវិធីតុលាការជាបន្តបន្ទាប់ ប្រឆាំងនឹងជនដែលទទួលរងការធ្វើទារុណកម្ម, ទំព័រទី៣៥១ និង៣៥៦ ។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង អាចអនុវត្តបានសម្រាប់ករណីនៅទីនេះ ។ ស្ថានភាពជាតួរយ៉ាងទីពីរ គឺការដាក់បញ្ចូលកំណត់ហេតុសាក្សីណាមួយ បានពីបុគ្គលណាម្នាក់ សម្រាប់ប្រើប្រាស់នៅក្នុងកិច្ចដំណើរការនីតិវិធី ប្រឆាំងនឹងបុគ្គលណាម្នាក់ផ្សេងទៀត; Thienel, ទំព័រទី៣៥៧ ។

00388441



បុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត"[41] ។

## **ខ. អនុសញ្ញាស្តីពីការប្រឆាំងអំពើទារុណកម្ម របស់អង្គការសហប្រជាជាតិ**

### ***ខ.១ - សនិទានភាព និង គោលដៅ និង គោលបំណងនៃអនុសញ្ញា CAT***

១៩. ការហាមឃាត់ប្រឆាំងនឹងអំពើទារុណកម្ម គឺមានលក្ខណៈដាច់ខាត ។ វាជានិយាមមួយ *ដែលជាប់កាតព្វកិច្ច (a jus cogens* norm*)* នៃច្បាប់អន្តរជាតិដែលមានចែងយ៉ាងច្បាស់លាស់នៅក្នុងអនុសញ្ញា CAT ដែលប្រទេសកម្ពុជាបានទទួលស្គាល់[42] ។ គោលបំណងទាំងស្រុងនៃអនុសញ្ញា CAT គឺដើម្បីលុបបំបាត់ការប្រើអំពើទារុណកម្មនៅពេលអនាគត, ដើម្បីធានាថាអំពើទារុណកម្មត្រូវបានហាមឃាត់ និងត្រូវបានបង្ការការពារដោយប្រទេសជាភាគី ហើយថាការខកខានមិនបានធ្វើការការពារ នោះអ្នកប្រព្រឹត្តនូវអំពើទារុណកម្ម ទាំងនោះត្រូវបានកាត់ទោស និងដាក់ទណ្ឌកម្ម[43] ។ ដូចដែលនឹងត្រូវបានបង្ហាញនៅក្នុងនេះ ទៀតដែរថា អនុសញ្ញា CAT គឺជាអនុសញ្ញាសម្រាប់ការលុបបំបាត់ជាគំរូ ដែលត្រូវជាប់កាតព្វកិច្ចដល់ប្រទេសជាភាគីនានាដោយមិនឲ្យប្រើនូវអំពើទារុណកម្មនៅក្នុងប្រទេសខ្លួន និងដើម្បីធ្វើការកាត់ទោសលើការប្រើប្រាស់នូវអំពើទារុណកម្ម នៅក្នុងយុត្តាធិការរបស់ខ្លួន ។

---

[41] មានតែវិធាន ២១.៣ ប៉ុណ្ណោះដែលបានលើកអំពីបញ្ហាភស្តុតាងដែលបានមកដោយការបង្ខំ ហើយវិធាននោះអនុវត្តទៅលើការបង្ខំដែលភ្នាក់ងាររបស់ អវតក ខ្លួនឯងបានធ្វើតែប៉ុណ្ណោះ ។

[42] សូមមើលផងដែរ មាត្រា៣ នៃអនុសញ្ញាទ្វីបអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR), មាត្រា៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងមាត្រា៥ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (UDHR) ។ *រដ្ឋអាជ្ញា ទល់នឹង Anto Furundzija*, អង្គជំនុំជម្រះសាលាដំបូងទី II នៃតុលាការ ICTY, សំណុំរឿងលេខ: IT-95-17/1-T, 38 ILM (ឆ្នាំ១៩៩៩), ៣១៧, ត្រង់ទំព័រទី ៣៤៩-៣៥០ (កថាខ័ណ្ឌទី ១៥៣-១៥៦) (ចាប់ពីនេះតទៅហៅថា "Furundžija"): មានយុត្តា ធិការព្រហ្មទណ្ឌសាកលមួយ ដើម្បីធ្វើការជំនុំជម្រះលើជនសង្ស័យពីអំពើទារុណកម្ម ដោយអនុវត្តតាមឋានៈ*ដែលជាប់កាតព្វកិច្ច* នៃការហាមឃាត់លើអំពើទារុណកម្ម ។ ពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាព <u>របាយការណ៍ Redress</u> ត្រង់ទំព័រទី ៧៩ បាន ពោលថា "ដោយអនុលោមតាមមាត្រា១៥ គោលការណ៍នីត្យានុកូលភាពមិនអនុវត្តជារបាំងមួយទៅលើការកាត់សេចក្តីលើអំពើ ទារុណកម្មទេ ដែលមានការទាក់ទងទៅនឹងអំពើនានាដែលបានកើតឡើងនៅពេលមុនមានការធ្វើសច្ចាប័នរបស់រដ្ឋដែលជាភាគី លើអនុសញ្ញានោះ ឬនៅពេលមុនមានការដាក់និយមន័យនៃអំពើទារុណកម្មបញ្ចូលទៅក្នុងក្រមព្រហ្មទណ្ឌ" ។

[43] អនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងអំពើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ឬដោយបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម, សេចក្តីប្រកាសរបស់មហាសន្និបាតអ.ស.ប លេខ៣៩/៤៦, U.N.GAOR, សម័យប្រជុំលើកទី ៣៩, Supp. លេខ ៥១, ឯកសារអ.ស.ប លេខ A/៣៩/៥១ (ឆ្នាំ១៩៨៤), មាត្រា៤-៩, ១៤ (ចាប់ពីនេះតទៅហៅថា "អនុសញ្ញា CAT") ។

២០. អំពើទារុណកម្ម បង្កើតបានជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សដែលជាឧក្រិដ្ឋកម្មដ៏ជាក់លាក់មួយដែលមានភាពធ្ងន់ធ្ងរជាទីបំផុត ។ ដើម្បីប្រើប្រាស់ពាក្យរបស់មេធាវីការពារក្តីអំពើទារុណកម្មគឺជា "វិធីដ៏អមនុស្សធម៌ ឃោរឃៅ និងអាក្រក់ក្រៃលែង"[44] ដែល "គួរឱ្យស្អប់ខ្ពើមជាខ្លាំង"[45] ហើយឥរិយាបថរបស់អ្នកធ្វើទារុណកម្ម គឺមានលក្ខណៈ "ដ៏គួរឱ្យខ្ពើមខាងសីលធម៌"[46] ។ ជាផលវិបាកអនុសញ្ញា CAT ត្រូវបានបង្កើតឡើងដើម្បីផ្តល់ជូននូវប្រព័ន្ធមួយសម្រាប់ធ្វើការអនុវត្តន៍ ដែលទៅតាមការអនុវត្តន៍នោះ "អ្នកធ្វើទារុណកម្មមិនអាចមានកន្លែងជ្រកសំណាក់ដ៏មានសុវត្ថិភាពបានឡើយ"[47] ហើយអ្នកធ្វើទារុណកម្មមិនបានចំណេញអ្វីពីអំពើរបស់ខ្លួនឡើយ[48] ។ និយាយម្យ៉ាងទៀត "ស្មារតីនៃអនុសញ្ញានេះ គឺថា (...) ជនណាក៏ដោយដែលសង្ស័យថាបានធ្វើទារុណកម្មត្រូវ តែខ្លបខ្លាចការកាត់ទោសជានិច្ច និងនៅគ្រប់ទីកន្លែង"[49] ។ នៅក្នុងកថាខ័ណ្ឌទី ៥៥ ដើមបណ្តឹងឧទ្ធរណ៍បានយល់ច្រឡំខុសដោយខ្លួនឯងទៅលើគោលដៅ និងគោលបំណងនៃអនុសញ្ញា CAT និងសនិទានភាពដែលមានន័យពីរយ៉ាងដែលមាននៅក្នុងមាត្រា ១៥ របស់ខ្លួនស្តីពីវិធានបដិសេធភស្តុតាង ។

### *ខ.២ - កាតព្វកិច្ចក្នុងការធ្វើការកាត់សេចក្តីដល់អ្នកប្រព្រឹត្តបទល្មើសធ្វើទារុណកម្ម*

២១. កាតព្វកិច្ចរបស់រដ្ឋដែលជាភាគីនៅក្នុងការធ្វើការកាត់សេចក្តី ដល់អ្នកប្រព្រឹត្តបទល្មើសធ្វើទារុណកម្មអនុវត្តតាម ការហាមឃាត់មិនឱ្យធ្វើទារុណកម្មដាច់ខាត ។ បញ្ញត្តិសំខាន់ៗនៃ

---

[44] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ១០៣ និង ៨ ។

[45] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ១០៩ ។

[46] សំណើរបស់មេធាវីការពារក្តី, កថាខ័ណ្ឌទី ១ ។

[47] J. H. Burgers និង H. Danelius, *អនុសញ្ញាស្តីពីការប្រឆាំងអំពើទារុណកម្ម របស់អង្គការសហប្រជាជាតិ - កូនសៀវភៅអំពីអនុសញ្ញាប្រឆាំងអំពើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ឬដោយបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម,* បោះពុម្ពផ្សាយដោយ Martinus Nijhoff, ឆ្នាំ១៩៨៨, ទំព័រទី១ (ចាប់ពីនេះតទៅហៅថា "Burgers & Danelius") ។

[48] អនុលោមតាមគោលការណ៍ច្បាប់ *"ពុំមានបុគ្គលណាម្នាក់ត្រូវបានអនុញ្ញាតឱ្យយកផលចំណេញពីអំពើខុសច្បាប់របស់ខ្លួនផ្ទាល់ឡើយ"* ។

[49] Nigel S. Rodley, *ការឃុំគ្រងលើអ្នកទោសតាមច្បាប់អន្តរជាតិ,* បោះពុម្ពលើកទី ២, Oxford, ឆ្នាំ១៩៩៩, ទំព័រទី ១០០, បានលើកឡើងនៅក្នុង Lene Wendland, *កូនសៀវភៅអំពីកាតព្វកិច្ចរបស់រដ្ឋទៅតាមអនុសញ្ញា អសប ស្តីពីការធ្វើទារុណកម្ម,* បោះពុម្ពផ្សាយដោយ សមាគមការពារអំពើទារុណកម្ម (APT), ទំព័រទី ៣៩, កំណត់សម្គាល់ជើងទំព័រទី ១៣២ (ចាប់ពីនេះតទៅហៅថា "*កូនសៀវភៅ APT*") ។

អនុសញ្ញា CAT បានដាក់ការព្រួយបារម្ភទៅលើ ការអនុវត្តន៍ និងការកាត់សេចក្តីខាងផ្នែកព្រហ្មទណ្ឌ៖ មាត្រា ៤ បានចែងថា រដ្ឋដែលជា ភាគីទាំងឡាយត្រូវតែធានាថារាល់ទម្រង់ទាំងអស់នៃអំពើទារុណកម្មគឺសុទ្ធតែជាបទល្មើស ដែលអាចដាក់ទណ្ឌកម្មបានទៅតាមច្បាប់ព្រហ្មទណ្ឌនៃប្រទេសរបស់ខ្លួន[50] ។ មាត្រា៥ ដល់ មាត្រា ៩ បានដាក់ការព្រួយបារម្ភទៅលើការកាត់សេចក្តីលើពួកបុគ្គលដែលត្រូវបានសង្ស័យអំពីអំពើទារុណកម្ម ។ មាត្រា ៥ បានដាក់កាតព្វកិច្ចឱ្យបណ្តារដ្ឋដែលជាភាគី បង្កើតយុត្តាធិការសាកលនៅក្នុងករណីនានាដែលមានអំពើទារុណកម្ម ដែលអ្នកប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់ មិនត្រូវបានធ្វើបត្យាប័ន ដើម្បីយកមកធ្វើការកាត់សេចក្តីនៅក្នុងរដ្ឋមួយផ្សេងទៀត ។ កាតព្វកិច្ចរបស់រដ្ឋដែលជាភាគីក្នុងការនាំយកអ្នកធ្វើទារុណកម្មដែលត្រូវបានចោទប្រកាន់ទៅរកយុត្តិធម៌ គឺពង្រីកទៅដល់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ។ មាត្រា៦ ដល់ មាត្រា ៨ បានគ្របដណ្តប់ទៅលើលំហាត់នៃយុត្តាធិការសាកលដូចដែលបានបង្កើតឡើងនៅក្នុងមាត្រា៥[51] ។ មាត្រា ៩ ចែងថា រដ្ឋ ដែលជាភាគីនានាត្រូវជួយគ្នាទៅវិញទៅមក នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធនឹងអំពើទារុណកម្ម ។ រីឯមាត្រា១២ បានបង្គាប់ដល់រដ្ឋដែលជាភាគីឱ្យចាត់វិធានការស៊ើបសួរជាបន្ទាន់ និងមិនលំអៀងទៅលើការចោទប្រកាន់អំពីការធ្វើទារុណកម្មទាំងនោះ ។ មាត្រា១៤ បានដាក់អាណត្តិថាជនរងគ្រោះដោយសារអំពើទារុណកម្មមានសិទ្ធិ ក្នុងការស្វែងរកយុត្តិធម៌ប្រឆាំងនឹងអ្នកដែលបានធ្វើទារុណកម្មដល់ពួកគាត់[52] ។ ជាសង្ខេប គោលបំណងដ៏លើសលប់នៃអនុសញ្ញា CAT គឺដើម្បីធ្វើការកាត់សេចក្តីលើការប្រព្រឹត្តិអំពើទារុណកម្ម ហើយការខកខានរបស់រដ្ឋដែលជា

---

[50] មើលកូនសៀវភៅ APT, ទំព័រទី ៣៥ ។

[51] *"នេះរួមទាំងករណីយកិច្ចក្នុងការយកជនសង្ស័យទៅដាក់ក្នុងពន្ធនាគារ, ចាត់ការលើសំណើចោទប្រកាន់ពីអំពើទារុណកម្ម និងបញ្ជូនជនសង្ស័យពីអំពើទារុណកម្ម ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចក្នុងការជំនុំជម្រះ",* កូនសៀវភៅ APT, ទំព័រទី ១៦ និង ៤៤ ។ លើកលែងតែជនសង្ស័យពីអំពើទារុណកម្មដែលត្រូវធ្វើបត្យាប័នចេញ រដ្ឋដែលជាភាគីត្រូវមានកាតព្វកិច្ចធ្វើការជំនុំជម្រះលើពួកជនសង្ស័យពីអំពើទារុណកម្ម ។ "នេះគេហៅថាគោលការណ៍នៃ *aut dedere aut judicare* ដែលមានន័យថា "ត្រូវធ្វើបត្យាប័ន ឬមួយត្រូវធ្វើការជំនុំជម្រះ" ។

[52] មាត្រា ៥៖ *"រដ្ឋដែលជាភាគីនីមួយៗត្រូវចាត់វិធានការបែបនេះជាការចាំបាច់ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសនានាដែលបានយោងនៅក្នុងមាត្រា ៤ (...)"* ។ មាត្រា ៦៖ ១) បើ *"កាលៈទេសៈអនុញ្ញាតឱ្យ, រដ្ឋដែលជាភាគីណាមួយក៏ដោយ ដែលជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើសណាមួយក៏ដោយដែលបានយោងនៅក្នុងមាត្រា ៤ មានវត្តមានស្នាក់នៅក្នុងទឹកដីរបស់ខ្លួន ត្រូវយកជននោះទៅកាន់កន្លែងឃុំឃាំង ឬចាត់វិធានការតាមផ្លូវច្បាប់ផ្សេងៗទៀតដើម្បីធានានូវវត្តមានរបស់ ជននោះ"* ។ ២) *"រដ្ឋនោះត្រូវធ្វើការសាកសួរបឋមមួយភ្លាមជាបន្ទាន់ ទៅលើអង្គហេតុទាំងនោះ"* ។ មាត្រា ៧៖ ១) *"រដ្ឋដែលជា ភាគី, (...) ត្រូវបញ្ជូនសំណុំរឿងនោះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីគោលបំណងនៃការជំនុំជម្រះក្តី"* ។

00388444



ភាគី ដូចជា ប្រទេសកម្ពុជាជាដើម ដែលមិនបានធ្វើការកាត់សេចក្តីដល់ពួកអ្នកធ្វើទារុណកម្ម បង្កើតបានជាអំពើបំពារបំពានមួយទៅលើច្បាប់អន្តរជាតិ ។

២២. នៅក្នុងឆ្នាំ ១៩៩០ ប៉ុន្មានឆ្នាំបន្ទាប់ពីអនុសញ្ញា CAT គោលការណ៍ណែនាំរបស់ អ.ស.ប សម្រាប់រដ្ឋអាជ្ញា ("គោលការណ៍ណែនាំរបស់ អ.ស.ប") ត្រូវបានអនុម័ត ដោយតម្រូវឱ្យពួករដ្ឋអាជ្ញា មិនត្រឹមតែ"ត្រូវតែមានការយកចិត្តទុកដាក់ក្នុងកាចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានប្រព្រឹត្តដោយពួកមន្ត្រីសាធារណៈ ជាពិសេស (...) អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស និងឧក្រិដ្ឋកម្មផ្សេងៗទៀតដែលត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ"[53] ប៉ុណ្ណោះទេ ក៏ប៉ុន្តែសំខាន់ជាងនេះទៅទៀត គឺ "ត្រូវចាត់ការនូវគ្រប់ដំណាក់កាលចាំបាច់នានា ដើម្បីធានាថា ពួកដែលត្រូវទទួលខុសត្រូវក្នុងការប្រើប្រាស់នូវវិធីសាស្ត្របែបដូច្នេះ [ដែលជាវិធីសាស្ត្រខុសច្បាប់ ដោយរួមទាំងអំពើទារុណកម្ម] ត្រូវបាននាំយកទៅដើម្បីធ្វើការកាត់ទោស"[54] ថែមទៀតផង ។

២៣. នៅក្នុងរបាយការណ៍របស់ខ្លួន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០១ លោក Nigel Rodley ដែលជា*អ្នករាយការណ៍ពិសេស*របស់គណៈកម្មាធិការសិទ្ធិមនុស្ស ស្តីពីបញ្ហាអំពើទារុណកម្ម បានពិភាក្សាពីទំនាក់ទំនងរវាង អំពើទារុណកម្ម និងនិទណ្ឌភាព[55] ។ លោកបានថ្លែងថា "កត្តាសំខាន់បំផុតតែមួយគត់នៅក្នុងការសាយភាយ និងការបន្តនៃអំពើទារុណកម្ម គឺជា <u>ការបន្តនៅមាននិទណ្ឌភាពជាប់ជានិច្ច</u> ទោះជាវាមានលក្ខណៈ*ជានីតិន័យ (តាមផ្លូវច្បាប់) ឬជាព្រឹត្តន័យ (តាមហេតុការណ៍ពិត)* ក៏ដោយ"[56] ហើយបញ្ជាក់អំពី "ករណីយកិច្ចរបស់ រដ្ឋទាំងឡាយឱ្យនាំយកចារី ដែលបានប្រព្រឹត្តអំពើទារុណកម្មទៅធ្វើការកាត់សេចក្តីដែលជា ផ្នែកដ៏សំខាន់មួយនៃ

---

[53] សន្និបាតអង្គការសហប្រជាជាតិលើកទីប្រាំបី ស្តីពីការការពារឧក្រិដ្ឋកម្ម និងការឃុំគ្រងអ្នកប្រព្រឹត្តបទល្មើស៖ គោលការណ៍ណែនាំស្តីពីតួនាទីរបស់រដ្ឋអាជ្ញា, ឯកសារអ.ស.ប លេខ A/CONF.១៤៤/២៨/វិសោធនកម្មលើកទី១, ទីក្រុងឡាហាវ៉ាន, ប្រទេស គុយបា, ថ្ងៃទី២៧ សីហា ១៩៩០ រហូតដល់ថ្ងៃទី០៧ កញ្ញា ១៩៩០, គោលការណ៍លេខ១៥ (ចាប់ពីនេះតទៅហៅថា "គោលការណ៍ណែនាំរបស់ អសប") ។

[54] គោលការណ៍ណែនាំរបស់ អសប, គោលការណ៍លេខ ១៦ ។

[55] N. Rodley, *របាយការណ៍របស់អ្នករាយការណ៍ពិសេសអំពីបញ្ហាទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ឬដោយបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម,* មហាសន្និបាតអង្គការសហប្រជាជាតិ, សម័យប្រជុំលើកទី ៥៦, ថ្ងៃទី០៣ កក្កដា ២០០១, A/៥៦/ ១៥៦, កថាខ័ណ្ឌទី ២៦-៣៣ (ចាប់ពីនេះតទៅហៅថា "របាយការណ៍របស់ Rodley") ។

[56] របាយការណ៍របស់ Rodley, កថាខ័ណ្ឌទី ២៦ ។ សង្កត់ន័យបន្ថែមដោយ <u>ការគូសបន្ទាត់ពីក្រោម</u> ។

00388445



ការជួសជុលដល់សិទ្ធិរបស់ជនរងគ្រោះ”[57] ។ លោកក៏បានយោងទៅ ដល់សេចក្តីប្រកាស និងកម្មវិធីសកម្មភាពនៅទីក្រុងវីយ៉ែនផងដែរ ដែលបានចែងថា “រដ្ឋទាំងឡាយត្រូវតែចាត់ទុកជានិរាករណ៍ នូវច្បាប់ទាំងឡាយណាដែលបណ្តាលឲ្យមាននិទណ្ឌភាព សម្រាប់ពួកដែលត្រូវទទួលខុសត្រូវចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ដូចជាអំពើទារុណកម្មជាដើម ហើយនិងធ្វើការកាត់សេចក្តីលើការបំពារបំពាន បែបដូច្នោះដែលតាមរយៈនេះ បានផ្តល់ជាមូលដ្ឋានរឹងមាំមួយសម្រាប់ធម្មាធិបតេយ្យ”[58]។ ការបកស្រាយតាមន័យត្រង់ និងដែលមានការរឹតត្បិតនូវមាត្រា ១៥ មិនគ្រាន់តែនាំឲ្យមាន លទ្ធផលគ្មានន័យ ឬមិនសមហេតុសមផលប៉ុណ្ណោះទេ (សូមអានកថាខ័ណ្ឌខាងក្រោម) ប៉ុន្តែ វានឹងនាំទៅដល់ការរំលោភកាតព្វកិច្ច ដើម្បីកាត់ទោសជនដែលត្រូវបានចោទប្រកាន់ អំពីការធ្វើទារុណកម្មទៀតផង ។

### *ខ.៣ - មាត្រា ១៥ នៃអនុសញ្ញា CAT ស្តីពីវិធានបដិសេធភស្តុតាង និងការលើកលែង*

២៤. មាត្រា ១៥ ស្តីពីវិធានបដិសេធភស្តុតាង និងការលើកលែងត្រូវតែបានយល់នៅក្នុងបរិបទទាំងមូលនៃគោលដៅ និងគោលបំណងនៃអនុសញ្ញា CAT ។ មាត្រា ១៥ ចែងថា៖ “រដ្ឋដែលជាភាគីនីមួយៗត្រូវធានាថា ចម្លើយណាមួយក៏ដោយដែលត្រូវបានធ្វើឡើងដោយសារការធ្វើទារុណកម្ម មិនត្រូវបានគេយកមកប្រើជាភស្តុតាងនៅក្នុងដំណើរការនីតិវិធីណាមួយឡើយ លើកលែងតែជាភស្តុតាងប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ពីអំពើទារុណកម្ម ដែលចម្លើយនោះត្រូវបានធ្វើឡើង” ។

២៥. កិច្ចការនានាដែលត្រៀមរៀបចំធ្វើអនុសញ្ញាCAT បង្ហាញថា ជាការផ្ទុយទៅនឹងអត្ថបទនៃសេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៧៥[59] និងសំណើដំបូងដែលបានធ្វើឡើងដោយប្រទេសស៊ុយអែត ដែលស្រដៀងគ្នាទៅនឹងសេចក្តី

---

[57] របាយការណ៍របស់ Rodley, កថាខ័ណ្ឌទី ២៨ ។

[58] របាយការណ៍របស់ Rodley, កថាខ័ណ្ឌទី ២៧ ។ ឯកសារអ.ស.ប លេខ A/CONF.១៥៧/២៣ (ថ្ងៃទី២៥ កក្កដា ១៩៩៣), កថាខ័ណ្ឌទី ៦០ ។

[59] សេចក្តីប្រកាសអំពីការការពារលើរាល់បុគ្គល កុំឲ្យឋិតនៅក្រោមអំពើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ឬដោយបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្មផ្សេងៗ ដែលត្រូវបានអនុម័តដោយសេចក្តីប្រកាសរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ ៣៤៥២ នៅថ្ងៃទី០៩ ធ្នូ ១៩៧៥ ។ មាត្រា ១២ ចែងថា *“ចម្លើយណាមួយក៏ដោយដែលត្រូវបានធ្វើឡើងដោយសារការ ធ្វើទារុណកម្ម ឬដោយសារការធ្វើបាបដោយអមនុស្សធម៌ ឬដោយបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្មផ្សេងៗ” អាចនឹងមិនត្រូវបាន គេយកមកប្រើជាភស្តុតាងប្រឆាំងនឹងជនដែលពាក់ព័ន្ធ ឬប្រឆាំងនឹងជនដទៃទៀតនៅក្នុងដំណើរការនីតិវិធីណាមួយឡើយ”* ។

ប្រកាសនោះ[60] ការលើកលែងមួយត្រូវបានបន្ថែមទៅក្នុងមាត្រា ១៥ ស្ដីពីវិធានបដិសេធភស្ដុតាង ទៅតាមគំនិតផ្ដួចផ្ដើមរបស់ប្រទេសអង់គ្លេស អូទ្រីស និងសហរដ្ឋអាមេរិក[61] ។ ការណ៍នេះបង្ហាញថា ច្បាប់អន្តរជាតិបានវិវត្តឡើងពីវិធានបដិសេធភស្ដុតាងមួយដែលមានលក្ខណៈដាច់ខាត ដោយពុំមានភាពខុសគ្នាណាមួយឡើយរវាងពួកបុគ្គលដែលត្រូវបានគេយកភស្ដុតាងអំពីអំពើទារុណកម្មមកអនុវត្តប្រឆាំងនឹងពួកគាត់ ទៅនឹងការពិចារណាមួយ ដែលថាស្ថានភាពដោយឡែករបស់បុគ្គលដែលត្រូវបានចោទប្រកាន់អំពី អំពើទារុណកម្ម ត្រូវបានធ្វើយុត្តិកម្មលើការលើកលែងនោះ[62]។ គេគួរធ្វើការកត់សម្គាល់ថា មាត្រា១៥-ដែលជាមាត្រាមួយមានការពិភាក្សាដេញដោលតិចបំផុត នៅក្នុងចំណោមមាត្រានានាដែល មានការពិភាក្សាដេញដោលតិចតួចក្នុងអនុសញ្ញាCAT-បានអនុវត្តទាំងស្រុងនៅក្នុងស្ថាន ភាពនានានៃអំពើទារុណកម្ម និងមិនចំពោះអំពើដ៏សាហាវ ការធ្វើបាបដោយអមនុស្សធម៌ ឬដោយបន្ទាបបន្ថោកទេ[63] ។

២៦. កិច្ចការដែលត្រៀមរៀបចំនានាមិនបានបញ្ជាក់ថា ក្រុមអ្នកអ្នកតាក់តែងអនុសញ្ញាCAT បានគិតទុកជាមុនអំពីថាតើមាត្រា១៥ គួរតែត្រូវបានអនុវត្តនៅក្នុងករណីរឿងមួយដែលមានមនុស្សរាប់ពាន់នាក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ និងធ្វើទារុណកម្មដោយខុសច្បាប់ហើយដែលកំណត់ហេតុលម្អិតនានាត្រូវបានរក្សាទុក ដែលអាចត្រូវបានប្រើប្រាស់ដើម្បី បង្ហាញភស្ដុតាងអំពីអត្តសញ្ញាណរបស់ជនរងគ្រោះនានា ចំពោះគោលបំណងនៃការធ្វើទារុណកម្មដោយខុសច្បាប់ ការអនុវត្តន៍ទៀងទាត់ដែលប្រើប្រាស់ដោយអ្នកធ្វើទារុណកម្មទាំងឡាយ និងអំពីអង្គ

---

[60] មាត្រា ១៣ នៃសំណៅព្រាងដើមរបស់ប្រទេសស៊ុយអែត សរសេរថា *"រដ្ឋដែលជាភាគីនីមួយៗត្រូវធានាថា ចម្លើយណាមួយក៏ដោយដែលត្រូវបានធ្វើឡើងដោយសារការធ្វើទារុណកម្ម ឬដោយសារការធ្វើបាបដោយអមនុស្សធម៌ ឬដោយបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្មផ្សេងៗមិនត្រូវបានគេយកមកប្រើជាភស្ដុតាងប្រឆាំងនឹងជនដែលពាក់ព័ន្ធ ឬប្រឆាំងនឹងជនដទៃទៀតនៅក្នុងដំណើរការនីតិវិធីណាមួយឡើយ"* ។

[61] Burgers និង Danielus, ទំព័រទី ៦៩ ។ Nowak និង McArthur, *អនុសញ្ញារបស់អសប ស្ដីពីការប្រឆាំងអំពើទារុណកម្មៈ សេចក្ដីអត្ថាធិប្បាយ,* Oxford 2008, 18 ។

[62] Burgers និង Danielus, ទំព័រទី ៦៩: ការលើកលែងនេះត្រូវបានដាក់បញ្ចូលពីព្រោះ *"គេត្រូវតែអនុញ្ញាតឲ្យតុលាការនានាបានប្រើប្រាស់នូវចម្លើយមួយដែលត្រូវបានធ្វើឡើងនៅក្រោមការធ្វើទារុណកម្ម ដើម្បីធ្វើជាភស្ដុតាងប្រឆាំងនឹងអ្នកធ្វើទារុណកម្ម"* ។

[63] Burgers និង Danielus, ទំព័រទី ៦៩ ។ Nowak និង McArthur, ៥០៧ ។ ឯកសារយោងមួយត្រូវបានគេស្នើឡើងដើម្បីឲ្យដាក់បញ្ចូលទៅក្នុងមាត្រា ១៦, ដូច្នេះគឺបានពង្រីកនូវវិធានបដិសេធន៍ភស្ដុតាង ទៅរកស្ថានភាពនានានៃអនុសញ្ញា CIDTP ក៏ប៉ុន្តែថា ឯកសារយោងនោះត្រូវបានគេទម្លាក់ចោលទៅវិញនៅក្នុងអំឡុងពេលប្រជុំរបស់ក្រុមការងារនៅឆ្នាំ១៩៨១ ។

00388447



ហេតុដទៃទៀត អាចជាសញ្ញាបង្ហាញពីគំរូនៃការប្រព្រឹត្តឧក្រិដ្ឋកម្មជាលក្ខណៈទូលំទូលាយ ឬជាប្រព័ន្ធដែរឬទេ ។

### ខ.៣.១ - គោលការណ៍នៃវិធានបដិសេធភស្តុតាង

២៧. យោងទៅតាម*អ្នករាយការណ៍ពិសេស*ស្តីពីអំពើទារុណកម្ម សទិទានភាពដែលមានន័យពីរយ៉ាងនៃមាត្រា ១៥ ស្តីពីវិធានបដិសេធភស្តុតាង គឺថា៖ ទី១) ចម្លើយសារភាព ឬព័ត៌មានផ្សេងៗដែលបានមកដោយការធ្វើទារុណកម្ម <u>ជាទូទៅមិនជាទីទុកចិត្តគ្រប់គ្រាន់ល្មម</u>ដែលអាចត្រូវយកទៅប្រើប្រាស់ធ្វើជាប្រភពភស្តុតាងមួយ នៅក្នុងដំណើរការនីតិវិធីតាមផ្លូវច្បាប់បានទេ ។ ទី២) ការហាមឃាត់មិនឱ្យប្រើប្រាស់នូវភស្តុតាងបែបដូច្នេះ បានដកហូត ការលើកទឹកចិត្តដ៏សំខាន់មួយនៅក្នុងការប្រើប្រាស់អំពើទារុណកម្ម ហេតុដូច្នេះហើយ នឹងបានទៅជាវិភាគទានមួយនៅក្នុងការទប់ស្កាត់កុំឱ្យមានការអនុវត្តន៍នេះ[64] ។ ដូចដែលបានរៀបរាប់ខាងលើ សទិទានភាពនេះ អនុវត្តតែចំពោះផ្នែកទីមួយនៃមាត្រា១៥ ប៉ុណ្ណោះ ពាក់ព័ន្ធនឹងរឿងក្តីជាតួរយ៉ាងចំនួនពីររឿង:

អ្នកដែលប្រឆាំងនឹងភស្តុតាងធ្វើទារុណកម្មត្រូវបានគេប្រើប្រាស់ គឺជាជនរងគ្រោះពីការធ្វើទារុណកម្ម ឬ រងគ្រោះដោយសារអ្នកដែលត្រូវបានជនរងគ្រោះនោះចោទប្រកាន់ - តតិយជន - ដែលជា *"អ្នកដែលរំលោភអំណាច ដែលមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មរបស់អង្គការសហប្រជាជាតិ មានគោលបំណងប្រកាសថាខុសច្បាប់តាំងពីដំបូង"*[65] ។ ស្រដៀងគ្នានេះដែរ ក្តីបារម្ភអំពីភាពអាចជឿទុកចិត្តបាន - ដែលពុំមាននរណាម្នាក់អាចដឹង

---

[64] M. Nowak, *របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីអំពើទារុណកម្ម,* មហាសន្និបាតរបស់ អសប, ចុះថ្ងៃទី១៤ សីហា ២០០៦, A/៦១/២៥៩, ត្រង់កថាខ័ណ្ឌទី ៤៥ ។ សង្កត់ន័យបន្ថែមដោយ <u>ការគូសបន្ទាត់ពីក្រោម</u>, (ចាប់ពីនេះតទៅហៅថា "របាយការណ៍របស់*អ្នករាយការណ៍ពិសេស*") ។ គេត្រូវតែកត់សម្គាល់ថា *អ្នករាយការណ៍ពិសេស* មិនបានបញ្ចេញឱ្យបានច្បាស់លាស់នូវព័ត៌មាននោះ ឬផ្នែកណាមួយនៃភស្តុតាងដែលបានមកដោយសារការធ្វើទារុណកម្មនោះ ដែលអាចនឹងទុកចិត្តបានគ្រប់គ្រាន់ល្មមនឹងយកទៅប្រើប្រាស់ធ្វើជាប្រភពមួយនៃភស្តុតាង ទេ ។ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន មេធាវីការពារក្តីបានថ្លែងថា ព័ត៌មាននេះគឺមិនអាចទុកចិត្តបាន (ដែលផ្ទុយទៅនឹង "ជាទូទៅគឺមិនអាចទុកចិត្តបានគ្រប់គ្រាន់ល្មម") ហើយនិងនៅក្នុងបណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ៥៥, ដោយជាក់ស្តែង មេធាវីការពារក្តីបានយល់ច្រឡំអំពីសទិទានភាពដែលមានន័យពីរយ៉ាងនៃវិធាន ១៥ នៃ អនុសញ្ញា CAT ដែលស្តីពីវិធានបដិសេធន៍ភស្តុតាងដោយមានគោលដៅ និងគោលបំណងនៃអនុសញ្ញា CAT ផ្ទាល់របស់វា ។

[65] Thienel ត្រង់ចំណុច ៣៥៦ [ការផ្ទុះបញ្ចាំងដែលបានបន្ថែម] ។

បានថា តើចម្លើយសារភាពដែលបានទទួលមកតាមរយៈការធ្វើទារុណកម្មឆ្លុះបញ្ចាំងពីការពិត ឬគ្រាន់តែជាភស្តុតាងធ្វើឡើងក្នុងគោលបំណងបញ្ឈប់ការធ្វើទារុណកម្ម - ត្រូវបានកាត់បន្ថយជាអប្បបរមា នៅពេលដែលចម្លើយដែលចោទជាបញ្ហា មិនត្រូវបានពឹងផ្អែកទៅលើការពិតទេ ប៉ុន្តែដើម្បីគោលបំណងដែលមិនមែនជាពាក្យចចាមអារ៉ាមទៅវិញ ដូចជាដើម្បីបង្ហាញឱ្យឃើញភស្តុតាងអំពីការដឹង ស្ថានភាពផ្លូវចិត្ត និងចេតនារបស់អ្នកដែលបានទទួល និងបានពិនិត្យឡើងវិញលើចម្លើយសារភាពទាំងនោះ ។

### ខ.៣.២ ការបកស្រាយអញ្ញត្រកម្មមាត្រា ១៥

២៨. មាត្រា ១៥ បានទទួលស្គាល់យ៉ាងច្បាស់លាស់ថា ភស្តុតាងដែលបានទទួលមកដោយសារការធ្វើទារុណកម្មអាចទទួលយកបាន នៅពេលដែលភស្តុតាងនោះត្រូវបានផ្តល់ "ប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម ដើម្បីធ្វើជាភស្តុតាងបញ្ជាក់អំពីការផ្តល់ចម្លើយ" ។ អញ្ញត្រកម្មនេះអនុញ្ញាតឱ្យ<u>ភស្តុតាងទាំងអស់ ដែលប្រមូលបានដោយសារការធ្វើទារុណកម្មអាចត្រូវបានទទួលយក</u> ដើម្បីបង្ហាញថា ចម្លើយនានាត្រូវបានធ្វើឡើងដោយសារតែការធ្វើទារុណកម្ម ។ ប្រសិនបើអាចទទួលយកបាន នេះបង្ហាញឱ្យឃើញថា បញ្ហាដែលត្រូវប្រឈមមិនមែនជាភាពអាចទទួលយកបាននៃភស្តុតាងនោះទេ ប៉ុន្តែវាជាការថ្លឹងថ្លែងភស្តុតាងនោះដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គជំនុំជម្រះទៅវិញទេ[66] ។សេចក្តីណែនាំរបស់អង្គការសហប្រជាជាតិ បានពង្រីកតាមផ្លូវច្បាប់នូវអញ្ញត្រកម្មនេះ និង បានអនុញ្ញាតឱ្យមានការប្រើប្រាស់ភស្តុតាងបែបនេះ ប្រឆាំងនឹងអ្នកទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើទារុណកម្ម ដោយមានគោលបំណងកាន់តែទូលំទូលាយជាងនេះ ជាពិសេសប្រសិនបើភស្តុតាងប្រឆាំងនោះត្រូវបានបង្កើតឡើងដោយជនជាប់ចោទ តាមការលើកឡើងនោះ ។ ទោះ

[66] ទោះបីជាក្រុមមេធាវីការពារក្តីបានលើកឡើងច្រំដែល នៅក្នុងបណ្តឹងឧទ្ធរណ៍អំពីទឡ្ហីករណ៍ពិសេសតែមួយដែលថា ពុំមានភស្តុតាងស្តីពីការធ្វើទារុណកម្មអាចទទួលយកបានដោយសារតែភាពមិនអាចទុកចិត្តបានដែលមាននោះក៏ដោយ គេត្រូវធ្វើការកត់សម្គាល់ថា កថាខណ្ឌទី ៥ សំដៅដោយបដិមតិទៅលើសក្ខីកម្មរបស់ ឌុច ពាក់ព័ន្ធនឹងភាពអាចទុកចិត្តបានដែលពាក់ព័ន្ធ ឬការថ្លឹងថ្លែងដែលត្រូវធ្វើលើចម្លើយសារភាពរបស់មន្ទីរស-២១ ដែលបានដកស្រង់តាមរយៈការធ្វើទារុណកម្ម ។ វាផ្ទុយទៅនឹងទឡ្ហីករណ៍ផ្ទាល់ខ្លួនរបស់គាត់ ។ អង្គហេតុដែលថាពួកគាត់ពិភាក្សាគ្នាពីភាគរយនៃភាពអាចជឿទុកចិត្តបានលើខ្លឹមសារនៃចម្លើយសារភាព (គោលបំណងចចាមអារ៉ាម) ដែលយោងតាមសម្តី ឌុច ប្រហែលជា២០ទៅ៤០% ពិត ដែលភាគច្រើនបង្ហាញថា *"នៅដំណាក់កាលនេះមិនអាចអះអាងថា ពុំមានធាតុផ្សំនៃការពិតដែលអាចរកឃើញនៅក្នុងចម្លើយសារភាពនានានោះទេ"* និង *"ភាពអាចជឿទុកចិត្តបាននៃចម្លើយនានាមិនអាចធ្វើការវាយតម្លៃបានទេ រហូតទាល់តែកិច្ចស៊ើបសួរបញ្ចប់សិន"* (ដីកាសម្រេចលើភស្តុតាងស្តីពីការធ្វើទារុណកម្ម កថាខណ្ឌទី២៨) ។

00388449



បើជាយ៉ាងណាក៏ដោយ កាតព្វកិច្ចក្នុងការផ្តន្ទាទោសចំពោះការទទួលខុសត្រូវ ចំពោះការប្រើប្រាស់វិធីសាស្ត្រទាំងនេះត្រូវបានរំលឹកថាៈ "នៅពេលព្រះរាជអាជ្ញា បានទទួលភស្តុតាងដែលបានមកប្រឆាំងនឹងជនជាប់សង្ស័យនានា ដែលពួកគាត់ស្គាល់ ឬជឿលើហេតុផលដែលបានទទួលមកដោយការប្រើវិធីសាស្ត្រមិនស្របច្បាប់ ដែលមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សរបស់ជនជាប់សង្ស័យ ជាពិសេសពាក់ព័ន្ធនឹងការធ្វើទារុណកម្ម ឬ អំពើឃោរឃៅដទៃទៀត ការធ្វើបាបដោយអមនុស្សធម៌ ឬដោយបន្ទាបបន្ថោក ឬការដាក់ទណ្ឌកម្ម ការរំលោភបំពានលើសិទ្ធិមនុស្សផ្សេងទៀត ពួកគាត់ត្រូវបដិសេធមិនប្រើប្រាស់ភស្តុតាងបែបនេះប្រឆាំងនឹងជនណាម្នាក់ក្រៅពីអ្នកទាំងឡាយណាដែលបានប្រើវិធីសាស្ត្រទាំងអស់នេះ ឬជូនដំណឹងទៅតុលាការតាមរឿងហេតុនោះនិងត្រូវចាត់វិធានការចាំបាច់គ្រប់យ៉ាងដើម្បីធានាថា អ្នកទាំងឡាយណាដែលទទួលខុសត្រូវចំពោះការប្រើប្រាស់វិធីសាស្ត្រនេះត្រូវបាននាំទៅកាត់ទោស"[67] ។

២៩. ដើមបណ្តឹងឧទ្ធរណ៍បានលើកឡើងស្របគ្នាថា អត្ថន័យសាមញ្ញនៃអញ្ញត្រកម្មរបស់មាត្រា ១៥ - ដែលអនុញ្ញាតចំពោះភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម នៅពេលដែលត្រូវគេប្រើប្រាស់ភស្តុតាងនោះ "ប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម ដើម្បីធ្វើជាភស្តុតាងបញ្ជាក់អំពីការផ្តល់ចម្លើយ" - គឺជាអត្ថន័យដែលមានអធិកភាព រីឯការបកស្រាយក្នុងន័យផ្សេងៗទៀតមិនមានការពាក់ព័ន្ធនោះទេ[68] ។ ទោះជាយ៉ាងណាក៏ដោយក្រុមមេធាវីការពារក្តីខកខានមិនបានបកស្រាយ អំពីប្រភពច្បាប់នានាដែលថាអត្ថន័យទូទៅរបស់បទបញ្ញត្តិទោលអាចផ្លាស់ប្តូរកម្មវត្ថុ និងគោលបំណងរបស់អនុសញ្ញាបាននោះទេ ។ លើសពីនេះទៀត មេធាវីការពារក្តីលើកឡើងមិនត្រឹមត្រូវទេដែលថា អំពីអត្ថន័យធម្មតារបស់មាត្រា១៥ គឺគ្រប់គ្រាន់ដើម្បីកំណត់អំពីរបៀបដែលអញ្ញត្រកម្ម នឹងត្រូវធ្វើដូចម្តេចចំពោះអង្គហេតុប្លែកពិសេស នៅក្នុងករណីរឿងនេះ ។ ឧទាហរណ៍ដូចជា ឃ្លាដែលថា "ប្រឆាំងនឹងជនណាម្នាក់" មិនបានផ្តល់ព័ត៌មានដល់អ្នកអាន ថាតើបើឃ្លានេះមានន័យសំដៅតែលើចារីប្រព្រឹត្តបទល្មើសផ្ទាល់ ដូចដែលបានបង្ហាញឲ្យឃើញតាមរយៈក្រុមមេធាវីការពារក្តី[69]ឬក៏នរណាម្នាក់ដែលមិនទទួលខុសត្រូវផ្ទាល់ចំពោះការធ្វើទារុណកម្មនោះទេ ។ ឃ្លាដែលសសេរថា "ជាភស្តុតាងអំពីចម្លើយដែលបានធ្វើឡើង" ក៏តម្រូវឲ្យធ្វើការបកស្រាយដែរ នៅពេលគេព្យាយាមអនុវត្តឃ្លានេះចំពោះឈុត

[67] សេចក្តីណែនាំរបស់អង្គការសហប្រជាជាតិ ចំណុច ១៦ ។

[68] បណ្តឹងឧទ្ធរណ៍ មូលដ្ឋានទីបី "ការបកស្រាយប្រឆាំងនឹងអត្ថន័យសាមញ្ញ" កថាខណ្ឌទី ៥៩ ដល់ ៦៣ ។

[69] សំណើសុំរបស់ក្រុមមេធាវីការពារក្តី កថាខណ្ឌទី៤៥/៥៥ ។

នៃកំណត់ហេតុសួរចម្លើយដែលស្មុគស្មាញ និងចាក់ស្រេះនៃឯកសារសួរចម្លើយនេះនៅក្នុងករណីរឿងនេះ[70] ។

៣០. ការលើកសំអាងផ្ទាល់ខ្លួនរបស់ក្រុមមេធាវីការពារក្តីបង្ហាញថា ត្រូវតែមានការវិភាគឱ្យបានកាន់តែស៊ីជម្រៅទៀត ។ ក្រុមមេធាវីការពារក្តី ដកស្រង់នូវគំនិតយោបល់របស់តុលាការយុត្តិធម៌អន្តរជាតិ ("ICJ") ស្តីពីបទបញ្ញត្តិសន្ធិសញ្ញាដែលបានចែងថា "ប្រសិនបើ (...) ពាក្យសម្តីដែលមានអត្ថន័យទូទៅនិងសាមញ្ញ (មិនមានន័យដែលគេអាចយល់បាន និង) មានន័យមិនច្បាស់លាស់ ឬនាំឱ្យទទួលបាននូវលទ្ធផលដែលមិនសមស្រប" នៅពេលនោះវិធីសាស្ត្របកស្រាយផ្សេងទៀតអាចត្រូវបានប្រើប្រាស់ដោយតុលាការ "ដើម្បីរកការពិតនូវអ្វីដែលភាគីនានាចង់មានន័យពិតប្រាកដនៅពេលពួកគាត់និយាយពាក្យសម្តីទាំងអស់នេះ"[71] ។

៣១. សចស ពិតជាត្រឹមត្រូវចំពោះសេចក្តីអះអាងដែលថា ឯកភាពទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតដែលថា អនុសញ្ញា CAT ជាគោលការណ៍ មិនគួរត្រូវបានប្រើប្រាស់ ដើម្បីជាខែលការពារអ្នកទាំងឡាយណាដែលទទួលខុសត្រូវ ចំពោះការធ្វើទារុណកម្មដែលបានលើកឡើងកើតចេញមកពីភស្តុតាងដែលបានជួយផ្តល់សក្ខីកម្មអំពីឧក្រិដ្ឋកម្មរបស់ពួកគេនោះទេ[72]។ វាប្រាកដជា "លទ្ធផលមួយដែលមិនសមហេតុផល" បើសិនបញ្ញត្តិណានៅក្នុងសន្ធិសញ្ញាដែលឧទ្ទិសចំពោះតែការលប់បំបាត់ការធ្វើទារុណកម្មប៉ុណ្ណោះ ត្រូវបានបកស្រាយដើម្បីអនុញ្ញាតឱ្យអ្នកធ្វើទារុណកម្មទាំងឡាយ អាចធ្វើការរាំងការទទួល យកនូវកំណត់ហេតុសួរចម្លើយដែលចងក្រងនូវឯកសារអំពីឧក្រិដ្ឋកម្មនានារបស់ពួកគេ ។ ពុំមានអ្វីដែលមិនសមហេតុផល ឬមិនសមស្របជាងការបកស្រាយបទបញ្ញត្តិ នៅក្នុងសន្ធិសញ្ញាមួយដែលបានឧទ្ទិស ដើម្បីលុបបំបាត់ការធ្វើទារុណកម្មតាមរយៈការហាមឃាត់ ការទប់ស្កាត់ និងការផ្តន្ទាទោស តាមវិធីដែល

---

[70] ឧទាហរណ៍ដូចជា សហព្រះរាជអាជ្ញាតវ៉ាជំទាស់ថាការដែលអនុញ្ញាតឱ្យប្រើចម្លើយសារភាពរបស់មន្ទីរស-២១ ណាមួយ "ជាភស្តុតាងអំពីថា ចម្លើយត្រូវបានធ្វើឡើង" គឺមុខជាត្រូវរួមបញ្ចូលនូវការបង្ហាញសក្ខីកម្មអំពីថា ចម្លើយ" ដែលបានធ្វើឡើង" ត្រូវបានបញ្ជូនទៅត្រូវបានពនិត្យឡើងវិញ និងត្រូវបានពឹងផ្អែកដោយជនត្រូវចោទនានាដើម្បីគោលបំណងដើម្បីបញ្ជាក់អំពីអត្តសញ្ញាណនិងចាប់ខ្លួនជនដទៃៗទៀតដែលមានឈ្មោះនៅក្នុងចម្លើយសារភាព ។

[71] មតិយោបល់របស់ ICJ ស្តីពីសមត្ថកិច្ចរបស់មហាសន្និបាតចំពោះការទទួលយករដ្ឋមួយចូលក្នុងអង្គការសហប្រជាជាតិ របាយការណ៍របស់ ICJ (១២៩៥០) កថាខណ្ឌទី៨ ដូចបានសំអាងនៅក្នុងរឿងក្តី រដ្ឋអាជ្ញា តទល់នឹង Akayezu សាលក្រម អង្គជំនុំជម្រះសាលាឧទ្ធរណ៍ លេខសំណុំរឿង ICTR-96-4-A ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ មតិយោបល់ជំទាស់ ដោយចៅក្រម Nieto-Navia កថាខណ្ឌទី៥ ដែលបានបកស្រាយនៅក្នុងបណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី៥៩ ។

[72] ដីកាសម្រេចលើភស្តុតាងស្តីពីការធ្វើទារុណកម្ម កថាខណ្ឌទី២៣ និង២៤ ។

00388451



ជួយដល់អ្នកធ្វើទារុណកម្មគេ ដែលបានលើកឡើងក្នុងការរារាំងដល់ការទទួលយកភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ដែលកំពុងស្ថិតក្រោមការស៊ើបសួរអំពីការប្រព្រឹត្តិនោះឡើយ ។ វាគ្រាន់តែជាគោលជំហរដែលប្រឆាំងនឹងតក្កភាព និងសុភវិនិច្ឆ័យប៉ុណ្ណោះ ។ គោលការណ៍ទូទៅដែលថា ពុំមាននរណាម្នាក់ ដែលត្រូវបានអនុញ្ញាតឱ្យទទួលបាននូវផលប្រយោជន៍ ពីអំពើមិនស្របច្បាប់ផ្ទាល់ខ្លួនរបស់គាត់នោះ ក៏បានធ្វើឱ្យទឡ្ហីករណ៍ទាំងអស់របស់ក្រុមមេធាវីការពារក្តី កាន់តែមិនអាចការពារបានទៅទៀត ។ អង្គបុរេជំនុំជម្រះ មិនគួរអនុញ្ញាតឱ្យយកអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ទៅប្រើប្រាស់ឥទ្ធិពលរបស់វាដើម្បីធានាថា អ្នកធ្វើទារុណកម្មលើគេបានចំណេញ ដោយសារតែការប្រព្រឹត្តិរបស់ខ្លួននៅពេលក្រោយមកទៀតនៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងរូបគាត់នោះទេ ។ តាមការយល់ឃើញរបស់ សហព្រះរាជអាជ្ញាគំនិតរបស់តុលាការយុត្តិធម៌អន្តរជាតិ គាំទ្រចំពោះជំហរដែលថា ការវិភាគលើអញ្ញត្រកម្ម មាត្រា ១៥ តាមការបកស្រាយបន្ថែម គឺជាការចាំបាច់ ។

៣២. នៅក្នុងករណីនៃឯកសារកម្ពុជាប្រជាធិបតេយ្យដែលបានទទួលមកតាមរយៈការធ្វើទារុណកម្មអញ្ញត្រកម្មនៅក្នុងបទដ្ឋានហាមឃាត់ ចំពោះការប្រើប្រាស់ប្រឆាំងនឹងជនជាប់ចោទពីបទធ្វើទារុណកម្មនៃមាត្រា ១៥ គួរតែត្រូវបានបកស្រាយឱ្យបានទូលំទូលាយ ដើម្បីលើកតម្កើងដល់កម្មវត្ថុ និងគោលបំណងនៃអនុសញ្ញា CAT[73] - ដែលមិនគ្រាន់តែដើម្បី អនុញ្ញាតឱ្យមានការទទួលយកភស្តុតាង ដែលបង្ហាញពីអត្ថិភាពរបស់ភស្តុតាងទាំងនោះ និងការធ្វើទារុណកម្មនោះព្រមទាំងបទឧក្រិដ្ឋនានាដែលបានកើតឡើងប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងដើម្បីទទួលយកនូវភស្តុតាងដែលកើតមកពីពាក្យចចាមអារ៉ាម ប្រឆាំងនឹងអ្នកធ្វើទារុណកម្មលើគេផងដែរ ។ ដូចដែលអតីត*អ្នករាយការណ៍ពិសេស* ស្តីពីការធ្វើទារុណកម្មរបស់អង្គការសហប្រជាជាតិ លោក P. Koojimans បានពន្យល់ថា សនិទានភាព ចំពោះ ការរួមបញ្ចូលនៃមាត្រា ១៥ គឺថា ការទទួលស្គាល់តាមផ្លូវតុលាការចំពោះភស្តុតាងនានា ដែលបានមកដោយការធ្វើទារុណកម្មគឺជា "ការទទួលខុសត្រូវចំពោះការរីកលូតលាស់ នៃការធ្វើទារុណកម្ម" និងថា ការបដិសេធចំពោះភស្តុតាងនេះនឹង "ធ្វើឱ្យការធ្វើទារុណកម្ម មិនទទួលបាននូវជោគជ័យនោះទេ ហេតុនេះធ្វើឱ្យវាមិនទទួលបាននូវការចាប់អារម្មណ៍នោះទេ"[74]។ ដូចនេះនៅពេលសនិទានភាពនៃបទដ្ឋាន

---

[73] អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ១៥៥ UNTS 331 ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ កថាខណ្ឌទី៣១(១) ។

[74] Scharf ត្រង់ចំណុច ១៣៥ ។

អញ្ញត្រកម្មនៃមាត្រា ១៥ មិន អាចអនុវត្តនោះ អញ្ញត្រកម្មលើបទដ្ឋាននោះដែលអនុញ្ញាតឱ្យមានការប្រើប្រាស់ភស្តុតាងនេះ ប្រឆាំងនឹងអ្នកធ្វើទារុណកម្មគេនោះ នឹងត្រូវបានបកស្រាយឱ្យបានទូលំទូលាយជាងនេះ ដើម្បីអនុវត្តតាមគោលបំណងរបស់អនុសញ្ញា CAT[75] ។

៣៣. តាមទម្លាប់អន្តរជាតិ ការបកស្រាយនិយមន័យនៃការធ្វើទារុណកម្ម មានលក្ខណៈទូលំទូលាយជាងពាក្យពេចន៍របស់មាត្រា ១ នៃអនុសញ្ញា CAT ការចូលរួមរបស់មន្ត្រីរដ្ឋ ការមិនមានភាពចាំបាច់នោះទេ[76] រីឯការរំលោភសេពសន្ថវៈអាចចាត់ទុកថាជា ការធ្វើទារុណកម្ម[77] ក៏ដូចជាអំពើនានាដែលមានបំណងធ្វើឱ្យជនរងគ្រោះមានភាពអាម៉ាស់ផងដែរ[78] ។ ការបកស្រាយដ៏ទូលំទូលាយដែលឆ្លុះបញ្ចាំងពីលក្ខខណ្ឌនាបច្ចុប្បន្ននេះ មានលក្ខណៈស្របគ្នាជាមួយនឹងកម្មវត្ថុ និងគោលបំណងរបស់អនុសញ្ញា CAT ។ គោលការណ៍ដដែលនេះ គួរតែបានប្រើប្រាស់ក្នុងការកំណត់ថាតើ អញ្ញត្រកម្ម ដែលបានចែងនៅក្នុងមាត្រា១៥ នៃអនុសញ្ញា CAT គួរតែអនុវត្តបែបដូម្ដេចចំពោះឈុតនៃកំណត់ហេតុសួរចម្លើយនានាដែលត្រូវបានពិនិត្យឡើងវិញ និងដែលពឹងផ្អែកដោយជនទាំងឡាយដែលបានប្រព្រឹត្ត អំពើទារុណកម្មនិងដែលចងក្រងទុកជាឯកសារអំពីទម្រង់ជាប្រព័ន្ធនៃអំពើឧក្រិដ្ឋកម្ម ដែលបានអនុវត្តអស់រយៈពេល៤ឆ្នាំ ។

៣៤. សហព្រះរាជអាជ្ញា សង្កេតឃើញថា នៅក្នុងបរិបទពិសេសរបស់មណ្ឌលសន្តិសុខរបបកម្ពុជាប្រជាធិបតេយ្យ ការទទួលយកភស្តុតាង ដែលធ្វើឡើងដោយសារការធ្វើទារុណកម្ម នៅក្នុងកិច្ចដំណើរការនីតិវិធី“ធ្វើជាភស្តុតាងអំពីចម្លើយដែលបានធ្វើឡើង”នឹងជួយក្នុងការបង្ហាញសក្ខីកម្មអំពីឧក្រិដ្ឋកម្មផ្សេងៗទៀត បន្ថែមពីលើការធ្វើទារុណកម្ម ។ នេះគឺ មិនមែនផ្អែកលើការពង្រីកណាមួយនៃអញ្ញត្រកម្មនៅក្នុងមាត្រា១៥ នោះទេ ប៉ុន្តែវាគ្រាន់តែជា ការរែកញែកដ៏សមហេតុសមផលមួយ ដោយផ្អែកទៅលើភស្តុតាងអំពីថា បុគ្គលម្នាក់ ត្រូវ បានសួរចម្លើយ និងបានធ្វើ

---

[75] សូមមើលសេចក្ដីណែនាំរបស់អង្គការសហប្រជាជាតិ ចំណុច ១៦ ។

[76] *Kunarac, Kovac និង Vokovic* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២ កថាខណ្ឌ១៤៨ ។ Brdjanin (អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤) កថាខណ្ឌទី៤៨៨, ៨៩ ។ Simic, Tadic និង Zaric អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌទី៨០ ។ Kvocka et al., អង្គបុរេជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០១ កថាខណ្ឌទី១៣៩ ។

[77] Akajesu ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៥៩៧។ Furundžija អង្គជំនុំជម្រះសាលាដំបូង លេខសំណុំរឿង IT-95-17/1 ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌទី១៦៣ ។

[78] Furundžija អង្គជំនុំជម្រះសាលាដំបូង លេខសំណុំរឿង IT-95-17/1 ចុះថ្ងៃទី១០ ធ្នូ ឆ្នាំ១៩៩៨ កថាខណ្ឌទី៦៤ កថាខណ្ឌទី១៦២ ។

ចម្លើយសារភាពនៅក្នុងមន្ទីរស-២១តែប៉ុណ្ណោះ ។ ឧទាហរណ៍ដូចជា ការពិតដែលជនម្នាក់ត្រូវបានគេសួរចម្លើយនៅក្នុងមន្ទីរស-២១ ចាំបាច់គឺត្រូវតែមានន័យថាអនុលោមទៅតាមទម្លាប់ និងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យថា បុគ្គលនោះពីមុនមកត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរស-២១ និងភវនីយភាព យ៉ាងខ្ពស់ថា ត្រូវបានគេសម្លាប់ចោល ក្រោយពេលបានបំពេញចម្លើយសារភាពចប់សព្វគ្រប់[79] ។ ហេតុដូច្នេះ សំអាងដែលបានលើកឡើងនៅក្នុងកថាខណ្ឌ១ នៃបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ដូចរៀបរាប់ដោយសង្ខេបមកនេះ គួរតែត្រូវបានបដិសេធចោល[80] ។

៣៥. ការទទួលយកភស្តុតាងដែលមានលក្ខណៈជាផ្នែកនៃប្រវត្តិសាស្ត្រ ដែលទទួលបានតាមរយៈរដ្ឋដែលពាក់ព័ន្ធនឹងបទល្មើស សូម្បីនៅមុនពេលអនុសញ្ញា CAT ត្រូវបានអនុម័ត និងមិនមែនតាមរយៈអ្នកស៊ើបអង្កេត ឬមន្ត្រីរបស់អង្គជំនុំជម្រះវិសាមញ្ញនោះក៏ដោយ ក៏នឹងមិនលើកកំពស់ការធ្វើទារុណកម្ម ឬជាការលើកទឹកចិត្តអ្នកធ្វើទារុណកម្មលើគេ ។ វាមិនត្រឹមត្រូវទេដែលជឿថា ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញ អនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងនេះ ពេលនោះវានឹងជាការលើកទឹកចិត្តដល់មន្ត្រីនគរបាលកម្ពុជា ឱ្យបន្តប្រើប្រាស់ការធ្វើទារុណកម្ម ដើម្បីទទួលបានភស្តុតាង ហើយតុលាការយល់ព្រមទៀតនោះ ។ វាមានការពិបាកយល់ណាស់ ថាតើការអនុញ្ញាតឱ្យប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្មប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត នៃរបបដែលពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរបំផុតនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប - ភស្តុតាងដែលឧក្រិដ្ឋជនបានបង្កើតឡើង-នឹងលើកទឹកចិត្តដល់ការអនុវត្តស្រដៀងគ្នានេះក្នុងចំណោមមន្ត្រីនគរបាលកម្ពុជានិងមន្ត្រីតុលាការដោយរបៀបណានោះ។ លើសពីនេះទៀត អង្គជំនុំជម្រះវិសាមញ្ញផ្តល់សារកាន់តែសំខាន់ដល់មន្ត្រីនគរបាលកម្ពុជា និងតុលាការថាការធ្វើទារុណកម្មមិនអាចគេចផុតពីការស៊ើបអង្កេតការផ្តន្ទាទោស និង

[79] កម្មាភិបាលមន្ទីរស-២១ បានផ្តល់សក្ខីកម្មអំពីការអនុវត្តជាទៀងទៀងទាត់ដែលមន្ទីរសន្តិសុខនេះបានអនុវត្តតាម ដែលរួមទាំងអង្គហេតុដែលជាក់ស្តែងថា រាល់មនុស្សទាំងអស់ដែលត្រូវបានឃុំខ្លួននៅមន្ទីរស-២១ ត្រូវបានគេសម្លាប់ចោលទាំងអស់ក្រោយពីផ្តល់ចម្លើយសារភាពរបស់ខ្លួនចប់សព្វគ្រប់។

[80] បណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន កថាខណ្ឌទី១: "តាមរយៈការបកស្រាយអញ្ញត្រកម្ម (...) មិនមានន័យថា ដើម្បីបង្កើតបាននូវអង្គហេតុជាក់លាក់នោះទេ ប៉ុន្តែដើម្បីបង្ហាញភស្តុតាងនិងផ្សាភ្ជាប់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ មនុស្សម្នាក់ទៅនឹងបទឧក្រិដ្ឋទាំងអស់ដែលគាត់ត្រូវបានចោទប្រកាន់ (...) សហចៅក្រមស៊ើបអង្កេតបានរំលោភលើច្បាប់ បានធ្វើហួសអំណាចរបស់ ខ្លួន និងបានធ្វើឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ស្មារតីនៃយុត្តិធម៌" ។

00388454



ការដាក់ទណ្ឌកម្មនោះឡើយ ។ ការបកស្រាយអញ្ញត្រកម្មមាត្រា១៥បែបនេះ កាន់តែពង្រឹងវិធានច្បាប់កម្ពុជា និងប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពទៀតផង ។

៣៦. លើសពីនេះទៀត ពុំមានការព្រួយបារម្ភអំពី"ការរីកសាយនៃការប្រព្រឹត្តិអំពើអាក្រក់" នោះទេ: ប្រសិនបើមេដឹកនាំរបបផ្សេងទៀត ធ្វើទារុណកម្មលើប្រជាពលរដ្ឋផ្ទាល់របស់ខ្លួននោះ ត្រូវប្រឈមមុខចំពោះការកាត់ទោសនាពេលអនាគត ។ វិធានដែលថា អ្នកទាំងឡាយណាដែលធ្វើទារុណកម្មលើគេ មិនអាចរួចផុតពីវិធានប្រឆាំងនឹងការធ្វើទារុណកម្មទេ នឹងជួយដល់ការផ្តន្ទាទោសមេដឹកនាំបែបនេះ ។ ដោយហេតុថា ការមានចេតនាប្រើប្រាស់ភស្តុតាងដែលគេបានជំទាស់ មិនអនុវត្តចំពោះជនរងគ្រោះដោយអំពើទារុណកម្ម ឬចំពោះតតិយជនដែលចោទប្រកាន់ដោយជនរងគ្រោះនៃអំពើទារុណកម្មនោះ វាពុំបានលើកទឹកចិត្តឲ្យមានការធ្វើទារុណកម្ម ឬការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្មទេ ។

៣៧. សចស បានយល់ឃើញត្រឹមត្រូវចំពោះសេចក្តីអះអាងដែលថា ជនត្រូវចោទអាចត្រូវបានចាត់ទុកថាជា "ជនត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម" ដោយមិនគិតពីវត្តមានជាក់ស្តែងរបស់ពួកគេនៅពេលធ្វើទារុណកម្មឬបានចូលរួមផ្ទាល់នោះទេ ពីព្រោះ"ពុំមានមូលដ្ឋានណាដើម្បីកំណត់អំពីភាសានៃអញ្ញត្រកម្មចំពោះចារីប្រព្រឹត្តបទល្មើសតែម្នាក់ឯង នោះទេ នៅពេលដែលជនណាម្នាក់ អាចត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម ដោយឈរលើមូលដ្ឋាននៃទម្រង់នៃការទទួលខុសត្រូវមួយចំនួន"[81] ។ និយមន័យនេះមានភាព ទូលំទូលាយខ្លាំងជាង ជាពិសេសស្របទៅនឹងកម្មវត្ថុ និងគោលបំណងរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និងគ្របដណ្តប់លើបុគ្គលដែលពង្រីកនូវគោលនយោបាយធ្វើទារុណកម្ម ព្រមទាំងបញ្ជាដល់អ្នកនៅ

[81] ដីកាសម្រេចលើភស្តុតាងស្តីពីការធ្វើទារុណកម្ម កថាខណ្ឌទី២២ ។ ក្រុមមេធាវីការពារក្តីបានលើកឡើងផ្ទុយនៅក្នុង កថាខណ្ឌទី៤៥ ។ ក.ស.ព ពិចារណាឃើញថា ក.ស.ព ក៏គួរតែគ្របដណ្តប់លើជន "ដែលជាប់សង្ស័យ" ពីការធ្វើទារុណកម្មមុនពេលដែល សាលក្រមសម្រេចសេចក្តីត្រូវបានអនុម័ត ។ លើសពីនេះទៀត ជនត្រូវចោទត្រូវបានចោទប្រកាន់ថាបាន រួមចំណែកក្នុងការ សម គំនិតគ្នាក្នុងបទល្មើសព្រហ្មទណ្ឌ ឬនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមជាមួយនឹងអ្នកសួរយកចម្លើយនានាដែលបានបំរើការងារនៅក្រោម បង្គាប់របស់គាត់ ។ ភាសានៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មបង្ហាញថា ការសមគំនិតប្រភេទនេះ មានចេតនាគ្របដណ្តប់ នៅក្នុងនិយមន័យនៃអ្នកធ្វើទារុណកម្មលើគេ ។ មាត្រា៤ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មបានចែងថា "រដ្ឋជាភាគីនីមួយៗ ត្រូវធានាថា រាល់អំពើធ្វើទារុណកម្មគឺជាបទល្មើសស្របតាមច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ។ ដូចគ្នានេះដែរត្រូវអនុវត្តចំពោះការប៉ុនប៉ង ប្រព្រឹត្តការធ្វើទារុណកម្ម និងចំពោះអំពើណាមួយធ្វើឡើង ដោយជនណាម្នាក់ដែលមានការសមគំនិត ឬការចូលរួមនៅក្នុងការធ្វើ ទារុណកម្ម" ។

ក្រោមបង្គាប់ឲ្យប្រព្រឹត្តអំពើទារុណកម្មផងដែរ[82] ។ "ជាពិសេសវាមានលក្ខណៈសំខាន់ដែលទម្រង់ផ្សេងទៀតនៃការសមគំនិត ឬការចូលរួមអាចដាក់ទោសបាន ពីព្រោះជាញឹកញាប់អ្នកធ្វើទារុណកម្ម គេដែលបន្សល់នូវស្លាកស្នាម ការលំបាក ឬការឈឺចាប់នោះ មិនប្រព្រឹត្តតែម្នាក់ឯងនោះទេ យ៉ាងណាមិញអំពើរបស់ គាត់អាចប្រព្រឹត្តទៅបានដោយសារមានការគាំទ្រ ឬការលើកទឹកចិត្តដែលគាត់បានទទួលមកពីអ្នកផ្សេងទៀត ។ ក្នុងករណីជាច្រើន អ្នកធ្វើទារុណកម្មគេ គឺគ្រាន់តែជាឧបករណ៍ ក្នុងដៃរបស់អ្នកណាម្នាក់ផ្សេងទៀតដែលមានសិទ្ធិអំណាចខ្ពស់តែប៉ុណ្ណោះ(...) ជនម្នាក់ ឬច្រើននាក់ដែលបានណែនាំគាត់គួរតែត្រូវបានដាក់ទោសផងដែរ"[83] ។

៣៨. ស្រដៀងគ្នានេះដែរ សេចក្ដីណែនាំរបស់អង្គការសហប្រជាជាតិ ចំណុចលេខ១៦ អនុញ្ញាតឲ្យមានការទទួលយកនូវភស្តុតាងបែបនេះប្រឆាំងនឹង "អ្នកទាំងឡាយណាដែលបានប្រើប្រាស់វិធីសាស្ត្រនេះ"។ លើសពីនេះ និយមន័យនៃការធ្វើទារុណកម្មនៅក្នុងមាត្រា ១.១ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម រួមបញ្ចូលនូវការចូលរួមរបស់មន្ត្រីរដ្ឋាភិបាលផងដែរ ដែលបានធ្វើឲ្យការកំណត់ចំពោះការទទួលខុសត្រូវរបស់អ្នកសួរយកចម្លើយ ជាលក្ខណៈបុគ្គល ឬចារីប្រព្រឹត្តបទល្មើសមានលក្ខណៈមិនសមស្រប[84] ។

៣៩. នៅក្នុងសាលក្រមរឿងក្ដីFurundžija តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានពិចារណាឃើញថា "លក្ខណៈនៃបទល្មើស និងទម្រង់ដែលបទល្មើសធ្វើឡើងក៏ដូចជាកម្រិតនៃការផ្ដន្ទា

---

[82] ទ្រឹស្ដីសមហេតុផល ស្ដីពីការទទួលខុសត្រូវតាមការបង្គាប់បញ្ជារបានលើកឡើងថា បុគ្គលនានាអាចទទួលខុសត្រូវចំពោះ ឧក្រិដ្ឋកម្មអន្តរជាតិ ទោះបីជានៅពេលដែលបុគ្គលទាំងអស់នោះមិនមានវត្តមាននៅក្នុងពេលប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះក៏ដោយ ។ សូមមើល *ច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ* ឯកសាររបស់UN A/CONF 183/9 ចុះ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ មាត្រា ២៨ និងច្បាប់អ.វ.ត.ក មាត្រា ២៩ ដែលចែងថា ជនជាប់សង្ស័យត្រូវទទួលខុសត្រូវ ចំពោះអំពើរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួន នៅពេលដែលពួកគាត់ *"បានដឹង ឬមានហេតុផលថាបានដឹងថាអ្នកនៅ ក្រោមបង្គាប់ប្រហែលជា"* ប្រព្រឹត្ត បទឧក្រិដ្ឋ ដែលពេលនោះខ្លួនមិនរារាំង ហើយក៏មិនដាក់ទណ្ឌកម្មលើអំពើនោះ ។

[83] Burgers & Danelius ទំព័រ១៣០។ សូមមើល គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់ទូទៅ លេខ ២០: *ការហាមឃាត់ មិនឲ្យធ្វើទារុណកម្ម និងការប្រព្រឹត្តឬការដាក់ទណ្ឌកម្មដែលសាហាវយង់ឃ្នង (មាត្រា៧)* ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩២ ឯកសារ របស់អង្គការសហប្រជាជាតិ HRI/GEN/1/វិសោធនកម្មទី៧ កថាខណ្ឌទី១៣ ។

[84] វាមានតម្លៃណាស់ក្នុងការលើកឡើងថា គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មក៏បានបញ្ជាក់ពីទស្សនៈយល់ឃើញថា កាតព្វកិច្ចរបស់រដ្ឋក្នុងការនាំយកអ្នកធ្វើទារុណកម្មលើគេដែលបានលើកឡើងមកកាត់សេចក្ដី គ្របដណ្ដប់លើមន្ត្រីជាន់ខ្ពស់បំផុតមិនគ្រាន់តែចារីប្រព្រឹត្តបទល្មើសប៉ុណ្ណោះទេ ។ សូមមើល C. Ingelse *គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្មរបស់អង្គការសហប្រជាជាតិ* - ការវាយតម្លៃច្បាប់អន្តរជាតិ Kluwer ឆ្នាំ២០០១ ទំព័រទី៣១៨ដែលបានបកស្រាយនៅក្នុងសៀវភៅ APT ទំព័រ៣៩, *ខាងចុងទំព័រនោះ* ។

ទោសជាអន្តរជាតិលើអំពើធ្វើទារុណកម្ម លើកឡើងថានៅក្នុងករណីនៃការធ្វើទារុណកម្ម អ្នកទាំងឡាយណាដែលបានចូលរួម ទោះក្នុងកម្រិតណាក៏ដោយក្នុងការចូលរួមប្រព្រឹត្តបទល្មើស និងជាពិសេសរួមចំណែកក្នុងការបញ្ចុះបញ្ចូលនរណាម្នាក់ តាមគោលបំណងជាមូលដ្ឋានរបស់ ខ្លួននោះ ត្រូវតែទទួលខុសត្រូវស្មើៗគ្នា" និងថា "វិធាននៃការបង្កើតដែលឆ្លុះបញ្ចាំងពីសារៈសំខាន់នៃកម្មវត្ថុនិងគោលបំណងរបស់ បទដ្ឋានអន្តរជាតិ នាំឱ្យមានការសន្និដ្ឋានថា ច្បាប់អន្តរជាតិ ធ្វើតម្រូវឱ្យមនុស្សមានការទទួលខុសត្រូវស្មើៗគ្នា"[85]។

## ៥. ការអនុញ្ញាតឲ្យប្រើប្រាស់ភស្តុតាងដែលត្រូវគេជំទាស់

៤០. គោលបំណងនៃកិច្ចស៊ើបសួរនាពេលថ្មីៗនេះ នៅក្នុងផ្នែកខ្លះគឺដើម្បីកំណត់ថាតើការធ្វើទារុណកម្មពិតជាត្រូវបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមែនឬយ៉ាងណា ។ ដូច្នេះ វានៅតែស្ថិតនៅក្រោមការសម្រេចថាតើ ភស្តុតាងដែលត្រូវគេជំទាស់ គឺជាលទ្ធផលនៃការធ្វើទារុណកម្ម ឬយ៉ាងណា ហើយថាតើវាមានជាប់ពាក់ព័ន្ធជាមួយច្បាប់ស្តីពីការធ្វើទារុណកម្មដែរឬយ៉ាងណា ។ ទោះជាយ៉ាងនេះក៏ដោយ ដោយសន្មតថាភស្តុតាងនេះជាប់ពាក់ព័ន្ធជាមួយនឹងការធ្វើទារុណកម្ម សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា មានការប្រើប្រាស់ដែលអាចទទួលយកបានសម្រាប់ភស្តុតាងដែលត្រូវគេជំទាស់នៅខាងក្រៅការពិតដែលជាចចាមអារ៉ាម ឬការពិតដែលដាក់បន្ទុកដែលមាននៅក្នុងភស្តុតាងនោះ ។

### ក. ជីវប្រវត្តិ ចំណារ និងព័ត៌មានសត្យានុម័តនៅក្នុងចម្លើយសារភាពគឺអាចទទួលយកបាន

៤១. ជីវប្រវត្តិ គឺអាចទទួលយកបាន ពីព្រោះជីវប្រវត្តិទាំងនោះបានធ្វើឡើងនៅពេលដែលអ្នកជាប់ឃុំឃាំងចូលមកដល់មន្ទីរ ស-២១ (ឬក៏នៅមន្ទីរសន្តិសុខផ្សេងៗទៀត) ហើយដូច្នេះនៅមុនពេលដែលពួកគេត្រូវបានធ្វើទារុណកម្ម ។ ជាគោលការណ៍ សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីយល់ស្របថា សហចៅក្រម ស៊ើបអង្កេតបានសម្រេចយ៉ាងត្រឹមត្រូវថា ចំណារ និងព័ត៌មាននៃប្រវត្តិរូបដែលមាននៅក្នុងចម្លើយសារភាព គឺអាចទទួលយកបាន[86] ពីព្រោះចម្លើយសារភាពទាំងនោះ មិនត្រូវបានធ្វើឡើងដោយសារតែការធ្វើទារុណកម្មឡើយ ។ ដូចដែលបានអះអាងដោយ សហចៅក្រមស៊ើបអង្កេតចំណារសរសេរដែដោយកម្មាភិបាល "ព័ត៌មានសត្យា

[85] Furundžija, អង្គជំនុំជម្រះសាលាដំបូង សំណុំរឿងរបស់តុលាការ ICTY លេខ IT-95-17/1-T, ទំព័រ៩៦, ចុះថ្ងៃទី១០ ធ្នូ ១៩៩៨, កថាខ័ណ្ឌទី២៥៤ ។

[86] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ៩៦, ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម, កថាខ័ណ្ឌ ១៩ ។

នុម័ត នៅក្នុងចម្លើយសារភាពដែលធ្វើឡើងដោយឯករាជ្យពីការសួរចម្លើយជនរងគ្រោះ" និង "ឯកសារទាក់ទិននឹងប្រវត្តិរូបបឋម"[87] គឺអាចទទួលយកបានពីព្រោះទាំងនេះស្ថិតនៅខាងក្រៅវិសាលភាពនៃ ការអនុវត្តន៍បញ្ញត្តិនៃមាត្រា១៥[88] ។ អ្នកសួរចម្លើយរបស់របបកម្ពុជាប្រជាធិបតេយ្យកម្មាភិបាល និងជនត្រូវចោទ បានធ្វើចំណារទាំងនេះ ដោយមិនមានការធ្វើទារុណកម្ម ។ សហចៅក្រមស៊ើបអង្កេតក៏ បានធ្វើសេចក្ដីសម្រេចយ៉ាងត្រឹមត្រូវផងដែរថាទោះបីជាភស្តុតាងខ្លះអាចត្រូវកត់ត្រាក្នុង ខណៈដែលជនជាប់ឃុំឃាំងត្រូវបានគេធ្វើបាបក្នុង"កម្រិត"មួយស្រាលជាងការធ្វើទារុណកម្ម យ៉ាងណាក៏ដោយ ក៏វាមិនប៉ះពាល់ដល់ភាពអាចទទួលយកបាននៃភស្តុតាងនោះដែរ ប៉ុន្តែជាទម្ងន់របស់ភស្តុតាងនោះ[89] ។

៤២. ទោះបីជាយ៉ាងណាក៏ដោយ ទឡ្ហីករណ៍របស់សហមេធាវីការពារក្ដីដែលថា ការយោងទៅលើចំណារ និងព័ត៌មានពីប្រវត្តិរូបត្រូវបានអនុញ្ញាត ប្រសិនបើ "វាមិនតម្រូវឲ្យមាន ឬយោងទៅលើអំណះអំណាងទាំងឡាយនៅក្នុងខ្លឹមសារនៃចម្លើយសារភាពនោះ គឺមិនអាចថិតថេរបានឡើយ[90] ។ ចំណារទាំងឡាយនោះតែងតែរិះគន់ ឬបញ្ចេញជាយោបល់ទៅលើចម្លើយសារភាពនោះ ហើយចំណារទាំងនោះអាចមានន័យស្ដាប់បាន ប្រសិនបើគេអានឃ្លាប្រយោគដែលមានបន្ទាត់គូសពីក្រោមផងដែរនោះ ។ ចំណារតែមួយប៉ុណ្ណោះគឺមិនអាចយល់បានឡើយ ។ ព័ត៌មានអំពីប្រវត្តិរូបជាក់លាក់ក៏អាចតម្រូវឲ្យមានបរិបទផងដែរ ដើម្បីឲ្យយល់បាន[91] ។ គោលជំហររបស់សហមេធាវីការពារក្ដី គឺចង់ដាក់បញ្ចូលតែព័ត៌មានគ្មានខ្លឹមសារ

---

[87] អ្នកជាប់ឃុំឃាំងជាច្រើនត្រូវបានគេសួរចម្លើយជាច្រើនដង ហើយចម្លើយសារភាពមុនដំបូងផ្ដោតទៅលើព័ត៌មានអំពីប្រវត្តិរូប។ *សូមអាន ឧទាហរណ៍* ចម្លើយសារភាពរបស់ កុយ ធួន ហៅ ឃួន ចុះថ្ងៃទី៥ ខែកុម្ភៈ - ថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៧៧, D83 , ERN 00026253-318 (ភាសាខ្មែរ) ។ អតីតបុគ្គលិកមន្ទីរ ស-២១ ដែលត្រូវបានស្ដាប់យកចម្លើយដោយសហចៅក្រមស៊ើបអង្កេតបានបង្ហាញសក្ខីកម្មថា នៅក្នុងករណីទាំងនេះ ការធ្វើទារុណកម្មមិនត្រូវគេអនុវត្តឡើយរហូតដល់ការសួរចម្លើយលើកក្រោយទៀត។ *សូមអាន ឧទាហរណ៍* កំណត់ហេតុស្ដាប់យកចម្លើយសាក្សី ប្រាក់ ខន ដោយកសចស ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧, D108/2/7, ERN 00161568-86 (ភាសាអង់គ្លេស) និង 00146613-34 (ភាសាខ្មែរ) ទំព័រទី ៨ ។ លើកលែងតែមានការបង្ហាញនូវភស្តុតាងដែលគួរជឿបានផ្សេងពីនេះ អង្គបុរេជំនុំជម្រះគួរយល់ថា ការផ្អែកទៅលើផ្នែកទាំងនេះនៃព័ត៌មានពីប្រវត្តិរូប អាចទទួលយកបាន ។

[88] ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម, កថាខ័ណ្ឌទី ១៩ ។

[89] ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម, កថាខ័ណ្ឌទី ១៩ ។

[90] បណ្ដឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ៩៦ ។

[91] ឧទាហរណ៍ ទីលំនៅរបស់បុគ្គលម្នាក់ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងអ្វីដែលត្រូវបាននិយាយនៅក្នុងចម្លើយសារភាព ។

00388458



ហើយដែលមិនមានតម្លៃជាភស្តុតាងចូលទៅក្នុងភស្តុតាង ។ ដូច្នេះអង្គបុរេជំនុំជម្រះ គួរតែបដិសេធសេចក្តីអះអាងនេះចោល[92] ។

៤៣. សរុបសេចក្តីមក សហព្រះរាជអាជ្ញាជឿជាក់ថា ចំណារទាំងឡាយណាដែលធ្វើឡើងដោយកម្មាភិបាលខ្មែរក្រហមគឺអាចទទួលយកបាន និងរួមទាំង ប៉ុន្តែមិនកំណត់ត្រឹមតែការផ្តល់យោបល់ និងសេចក្តីណែនាំ[93] និងព័ត៌មានផ្សេងៗទៀតនោះទេ ដូចជា "កាលបរិច្ឆេទចាប់ខ្លួនកាលបរិច្ឆេទនៃការចាប់ផ្តើមការបញ្ចប់និងផ្អាកការផ្តល់ចម្លើយសារភាពផ្សេងៗ"[94] ។ ព័ត៌មានអំពីជីវប្រវត្តិជាមូលដ្ឋានណាមួយរបស់ជនដែលត្រូវបានគេសួរចម្លើយ ក៏អាចទទួលយកបានផងដែរ និងរួមទាំងប៉ុន្តែមិនកំណត់ត្រឹម ឈ្មោះ អាយុ ទីលំនៅ តួនាទី និង កន្លែងធ្វើការមុននិងក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ព្រមទាំងម៉ោង និងទីកន្លែងចាប់ខ្លួនប៉ុណ្ណោះនោះទេ ។ ជាធម្មតាចំណារ និងព័ត៌មានអំពីប្រវត្តិរូបគឺអាចទទួលយកបាន បើចំណារ និងព័ត៌មានទាំងនោះមិនត្រូវទទួលបានតាមរយៈការធ្វើទារុណកម្មនោះទេ។ ទោះជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាមិនអើពើអំពីភស្តុតាងណាដែលព័ត៌មាន នេះត្រូវទទួលបានតាមរយៈការធ្វើទារុណកម្មឡើយ ។

## ខ. គោលបំណងមិនមែនចចាមអារ៉ាម

៤៤. មាត្រា ១៥ ពិតជារារាំងមិនឱ្យគេទទួលស្គាល់ជាភស្តុតាងនូវខ្លឹមសារសម្រាប់ដាក់បន្ទុកនៃភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម ។ ម្យ៉ាងវិញទៀត ចចាមអារ៉ាម ឬក៏ "ការពិត" ដែលត្រូវបានចោទប្រកាន់ ដែលត្រូវបានបញ្ជាក់នៅក្នុងចម្លើយសារភាពដែលទទួលបានពីការធ្វើទារុណកម្ម គឺមិនអាចទទួលយកបានទេ[95] ។ ប៉ុន្តែ មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្មដែល

[92] នៅពេលដែលចម្លើយសារភាពដែលមានគួសបន្ទាត់ពីក្រោម អាចទទួលយកបាន ដូចដែលបានលើកទឡ្ហីករណ៍នៅក្នុងនោះ ការធ្វើឱ្យតម្រូវការចំពោះចម្លើយសារភាពក្នុងការផ្តល់បរិបទមិនមានសារៈសំខាន់ សហព្រះរាជអាជ្ញាជឿថាប្រសិនបើចម្លើយសារភាពត្រូវបានពិចារណាថាមិនអាចទទួលយកបាន ចំណារ និងព័ត៌មានពីប្រវត្តិរូបទាំងនេះគួរត្រូវបាន គេអានជាមួយនឹងផ្នែកដែលពាក់ព័ន្ធនៃចម្លើយសារភាព ដើម្បីធ្វើឱ្យយល់បាន ។

[93] សេចក្តីបញ្ជាក់ទាំងនេះដែលធ្វើឡើងដោយបុគ្គលិកមន្ទីរសន្តិសុខ (ដូចជាមន្ទីរ ស-២១) ដែលអនុវត្តការធ្វើទារុណកម្មដែលតែងតែបង្ហាញឈ្មោះរបស់បុគ្គលដែលចម្លើយសារភាពត្រូវបានសំដៅទៅលើ និង/ឬថា បុគ្គលដែលមានឈ្មោះនៅក្នុងចម្លើយសារភាព មួយត្រូវបានគេចាប់ខ្លួន ឬប្រហារជីវិត ។

[94] ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម, កថាខណ្ឌទី ១៩ ។

[95] ឧទាហរណ៍ ចម្លើយសារភាពដែលនិយាយថា *"ខ្ញុំជាភ្នាក់ងារ សេអ៊ីអា"* និងជាការពិតដែលត្រូវបានអះអាងជាចចាមអារ៉ាម ដែល មាត្រា ១៥ ត្រូវបានបង្កើតដើម្បីរារាំងមិនឱ្យប្រើជាភស្តុតាង ។

00388459



អនុញ្ញាតឱ្យទទួលយកចម្លើយសារភាពនានា "ជាភស្តុតាងអំពីចម្លើយត្រូវបានធ្វើឡើង" ពិតជាធ្វើឱ្យភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម ត្រូវទទួលយកបានដើម្បីបង្ហាញពីគោលបំណងមិនមែនចចាមអារ៉ាម ដែលចម្លើយសារភាពនោះត្រូវបានធ្វើឡើង ដូចដែលបានយល់ព្រមនៅក្នុងបណ្តឹងឧទ្ធរណ៍នោះ[96] ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គហេតុតាមកាលៈទេសៈ និងអង្គហេតុតាមការពិចារណា ដែលកើតចេញពីការទទួលស្គាល់នូវឯកសារដែលត្រូវគេជំទាស់ ដើម្បីបង្ហាញថា "ចម្លើយសារភាពត្រូវបានធ្វើឡើង" ក៏អាចទទួលយកបានដែរ[97] ។

៤៥. សហព្រះរាជអាជ្ញា សន្និដ្ឋានបន្ថែមទៀតថា គោលបំណងមិនមែនចចាមអារ៉ាមដទៃទៀតសម្រាប់ភស្តុតាងដែលត្រូវគេជំទាស់ ក៏អាចទទួលយកបានដែរ ។ គោលបំណងមិនមែនចចាមអារ៉ាម គឺជា"គោលបំណងមួយក្រៅពីភស្តុតាងនៃការពិតដែលត្រូវបានគេអះអាង"[98] ។ មេធាវីការពារក្តីមិនធ្វើការតវ៉ាជំទាស់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា នេះគឺជាការប្រើប្រាស់មួយដ៏ត្រឹមត្រូវនៃចម្លើយសារភាពរបស់មន្ទីរស-២១ ទេ ហើយថែមទាំងលើកសំអាងរបស់អ្នកជំនាញ អំពីភស្តុតាងនៃការធ្វើទារុណកម្ម គឺសាស្ត្រាចារ្យ Pattenden ដែលបានបញ្ជាក់ថា ភស្តុតាងដែលទទួលបានមកដោយការធ្វើទារុណកម្ម អាចត្រូវបានប្រើប្រាស់ប្រឆាំងទៅលើអ្នកប្រព្រឹត្តអំពើទារុណកម្មសម្រាប់គោលបំណង "មិនមែនចចាមអារ៉ាម"[99] ។

៤៦. ក្នុងករណីនេះ ចម្លើយសារភាពនានានៃមន្ទីរស-២១ ត្រូវបានធ្វើជូនទៅឱ្យជនត្រូវចោទទាំងឡាយដែលបានពិនិត្យឯកសារឡើងវិញ និងផ្អែកលើឯកសារទាំងនេះដើម្បីធ្វើការចាប់ខ្លួន

---

[96] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ៦១ ។

[97] សូមអានខាងលើ កថាខ័ណ្ឌទី ៣៣ ។ ឧទាហរណ៍ ការទទួលស្គាល់ចម្លើយសារភាពធ្វើឡើងនៅមន្ទីរ ស-២១ របស់ជនរងគ្រោះពីការធ្វើទារុណកម្ម ដាក់ពួកគេនៅមន្ទីរស-២១ ដែលអាចបង្ហាញថាជនរងគ្រោះត្រូវបានចាប់ខ្លួន ត្រូវបានឃុំឃាំងនៅក្នុងលក្ខណៈអមនុស្សធម៌ដោយខុសច្បាប់ និងត្រូវបានប្រហារជីវិត ។ គ្រួសាររបស់ជនរងគ្រោះនោះក៏ទំនងជាត្រូវបាននាំខ្លួនផងដែរទៅកាន់ មន្ទីរស-២១ និងទទួលរងនូវជោគវាសនាស្រដៀងគ្នានោះដែរ ។ ដោយផ្អែកទៅលើកាលបរិច្ឆេទនៃ ការឃុំខ្លួន ការដឹងតែអំពី អត្តសញ្ញាណរបស់ជនរងគ្រោះនោះ ដូចជាទាហានកម្ពុជាប្រជាធិបតេយ្យភូមិភាគបូព៌ាម្នាក់ អាចត្រូវបានសន្និដ្ឋានផងដែរ ។ សេចក្តីសន្និដ្ឋានទាំងនេះ និងសេចក្តីសន្និដ្ឋានផ្សេងទៀត អាចត្រូវបានធ្វើឡើងដោយពិចារណាទៅលើភស្តុតាងដែលបានមកពីការមិន ធ្វើទារុណកម្ម ដោយឯករាជ្យដែលមិនស្ថិតនៅក្រោមអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មឡើយ ដូចជា ចម្លើយរបស់សាក្សី និង ការវិភាគរបស់អ្នកជំនាញ ។

[98] *ច្បាប់ស្តីពីភស្តុតាង ឆ្នាំ២០០៨* (ច្បាប់របស់សហព័ន្ធ របស់អូស្ត្រាលី), ផ្នែក ៦០.១ ។

[99] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ៦១ ។

មនុស្សបន្ថែមទៀតដែលមានឈ្មោះក្នុងចម្លើយសារភាព[100] ។ ព្រោះតែចម្លើយសារភាពទាំងនេះដែលបានពិនិត្យឡើងវិញដោយជនត្រូវចោទទាំងនោះ ទើបធ្វើឱ្យចម្លើយសារភាពទាំងនោះមានការជាប់ពាក់ព័ន្ធ សម្រាប់បង្ហាញសក្ខីកម្មអំពីការដឹងរបស់ជនត្រូវចោទទាំងនោះ ពីអង្គហេតុដែលថា មនុស្សជាច្រើនកំពុងត្រូវបានឃុំខ្លួន និងដាក់ឱ្យស្ថិតនៅក្រោមការសួរចម្លើយដោយបង្ខំនៅមន្ទីរសន្តិសុខស-២១ ដើម្បីបង្ហាញអត្តសញ្ញាណអំពីអ្នកដែលគេគិតថា ជាខ្មាំងនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ការប្រើប្រាស់ចម្លើយសារភាពទាំងនេះ គឺជាគោលបំណងដែលមិនមែនចាចាមអារ៉ាម ពីព្រោះវាមិនផ្អែកការពិតនៃចម្លើយដែលធ្វើឡើងដោយការបង្ខំទេ - ឧទាហរណ៍ដូចជាថា មនុស្សដែលមានឈ្មោះនិងដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពនានា តាមពិតគឺជាសុទ្ធតែជាគិញរបស់ សេអ៊ីអា ឬកាសេបេ ។ ជាជំនួសមកវិញចម្លើយទាំងនេះ គួរត្រូវបានប្រើប្រាស់បង្ហាញសក្ខីកម្មអំពីអង្គហេតុពាក់ព័ន្ធផ្សេងទៀត ជាពិសេសអំពីការដឹងអំពីស្ថានភាពផ្លូវចិត្ត និងអំពីមូលហេតុ និងចេតនា ទាំងរបស់អ្នកសួរចម្លើយដែលបានត្រៀមរៀបចំឯកសារទាំងនេះ និងទាំងមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលបានទទួល និងអានចម្លើយទាំងនេះ[101]។ ក្នុងកាលៈទេសៈនេះ ដូចដែលសហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានហើយថា "ព័ត៌មានដែលមាននៅក្នុងចម្លើយសារភាព គឺមិនត្រូវបានប្រើប្រាស់សម្រាប់ការពិតអំពីខ្លឹមសារនៃព័ត៌មាននោះទេ (បានន័យថាដើម្បីបង្ហាញសក្ខីកម្មថាជនទាំងឡាយដែលពាក់ព័ន្ធជាក់ស្តែងគឺជាពួកក្បត់) ប៉ុន្តែផ្ទុយទៅវិញ គឺដើម្បីបង្ហាញឱ្យឃើញអំពីថាតើចម្លើយសារភាព ត្រូវបានប្រើប្រាស់យ៉ាងដូម្តេច (ឧទាហរណ៍ដូចជា ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ ប្រឆាំងនឹងជនទាំងឡាយដែលមានឈ្មោះក្នុងចម្លើយសារភាព")[102] ។

---

[100] ឧទាហរណ៍ ចម្លើយសារភាពនៅមន្ទីរស-២១ មួយដែលបានឆ្លើយដាក់ពួកកម្មាភិបាល មកពីក្រសួងការបរទេសត្រូវបាន ផ្ញើទៅឱ្យ អៀង សារី ។ រីឯចម្លើយសារភាពមួយដែល មានឈ្មោះពួកកម្មាភិបាលមកពីក្រសួងការបរទេស ត្រូវបានផ្ញើ ទៅឱ្យ អៀង ធីរិទ្ធ ។ បន្ទាប់មកទៀត ពួកនោះត្រូវទទួលខុសត្រូវក្នុងការសួរយោបល់ទៅគណៈអចិន្ត្រៃយ៍បកក ថាតើ សកម្មភាពណាមួយដែលត្រូវចាត់ការទៅលើពួកកម្មាភិបាលដែលត្រូវបានគេឆ្លើយដាក់នោះ ។ នៅក្នុងករណីមួយចំនួន ពួកកម្មាភិបាលទាំងនោះ គ្រាន់តែត្រូវបានតាមដានឃ្លាំមើលដោយបក្ស ហើយតម្រូវឱ្យសរសេរប្រវត្តិរូបផ្ទាល់ខ្លួន ។ នៅក្នុងករណីផ្សេងទៀត ពួកនោះត្រូវបានចាប់ខ្លួនយកទៅមន្ទីរស-២១, ត្រូវបានសួរចម្លើយ និងត្រូវបានធ្វើទារុណកម្ម រហូតទាល់តែពួកទាំងនោះបានឆ្លើយសារភាព ហើយបានប្រាប់ឈ្មោះបុគ្គលដទៃទៀតដែលជា "ខ្មាំង" របស់អង្គការ ផងដែរ ។

[101] សូមអានករណីរឿង សហរដ្ឋអាមេរិក ទល់នឹង Horton, សំណុំរឿងលេខ 847 F.2d 313, សាលាឧទ្ធរណ៍ជុំទី៦ នៃសហរដ្ឋអាមេរិក (ឆ្នាំ១៩៨៨) ត្រង់លេខ៣២៤ ។ Colin Ying, ភស្តុតាងសំខាន់នៃប្រទេសអូស្ត្រាលី 3/e (ឆ្នាំ២០០៥) ទំព័រ៤៧-៨ ។

[102] ដីកាសម្រេចលើភស្តុតាងនៃការធ្វើទារុណកម្ម, កថាខ័ណ្ឌទី២៧ ។

00388461



៤៧. អង្គហេតុពាក់ព័ន្ធមួយផ្សេងទៀតទៅនឹងមិនមែនពាក្យចចាមអារ៉ាម ដែលថាអាចត្រូវបានបង្ហាញសក្ខីកម្មពីចម្លើយសារភាពផ្ទាល់ នោះគឺគោលបំណងនៃការធ្វើទារុណកម្ម និង ប្រភេទនៃជនដែលត្រូវបានគេចាត់ទុកថាជា "ខ្មាំង" ដោយមេដឹកនាំនានានិងបក្សកុម្មុយនីស្តកម្ពុជាដែលទទួលខុសត្រូវចំពោះការធ្វើទារុណកម្មបែបនេះ ។ និយាយឲ្យចំ ប្រការដែលថាមនុស្សរាប់ពាន់នាក់ ត្រូវបានគេសួរចម្លើយអំពីថាតើពួកគេគឺជាគិញរបស់ សេអ៊ីអា, កាសេប វៀតណាម អតីតអ្នកស្មោះត្រង់នឹងលន់ នល់ ឬ ជាសមាជិកនៃក្រុមដទៃទៀត ដែលបង្ហាញសក្ខីកម្មអំពីគោលបំណងនៃការសួរចម្លើយ និងការធ្វើទារុណកម្មជាប្រព័ន្ធត្រូវបានអនុវត្តដោយជនត្រូវចោទទាំងនេះដែរឬទេ ។ ជាថ្មីម្តងទៀត ភស្តុតាងទាំងនេះមិនត្រូវបានផ្តល់ឲ្យដើម្បីបង្ហាញសក្ខីកម្មពីការពិតនៃចម្លើយទាំងនេះទេ - ឧទាហរណ៍ដូចជាជនដែលត្រូវគេធ្វើទារុណកម្ម តាមពិតគឺជាគិញរបស់សេអ៊ីអា - ប៉ុន្តែផ្ទុយទៅវិញគឺដើម្បីបង្ហាញសក្ខីកម្មអំពីស្ថានភាពផ្លូវចិត្ត និងចេតនារបស់ជនទាំងឡាយដែលទទួលខុសត្រូវចំពោះការធ្វើទារុណកម្មទៅវិញ[103] ។

## គ. តម្រុយក្នុងការស៊ើបសួរ

៤៨. ចម្លើយសារភាពនៅក្នុងឯកសារសារភាព គួរត្រូវទទួលដាក់បញ្ចូលទៅក្នុងសំណុំរឿងជាតម្រុយក្នុងការស៊ើបសួរ នាំទៅរកប្រភពព័ត៌មានផ្សេងៗទៀត ។ មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ ដែលមានចែងស្រដៀងគ្នានៅក្នុងវិធានផ្ទៃក្នុង ៥៥(៥) ចែងថាសហចៅក្រមស៊ើបអង្កេត "ត្រូវដឹកនាំកិច្ចស៊ើបសួរដោយផ្អែកទៅលើមូលដ្ឋាននៃព័ត៌មានដែលទទួលបានពីស្ថាប័ននានា រួមមាន រដ្ឋាភិបាល ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ឬអង្គការក្រៅរដ្ឋាភិបាលជាដើម" ។ មាត្រានេះចែងបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេត "ត្រូវមានអំណាចក្នុងការសួរចម្លើយជនសង្ស័យ និងជនរងគ្រោះ ស្តាប់ចម្លើយសាក្សី និងប្រមូលភស្តុតាងដោយអនុវត្តតាមនីតិវិធីជាធរមាន" ។

[103] ដូចឧទាហរណ៍មួយតទៅនេះ ចម្លើយសារភាពនានាបានឆ្លុះបញ្ចាំងថា ពួកអ្នកជាប់ឃុំត្រូវបានសួរចម្លើយតាមរបៀបមួយដូចដែលថាតើពួកទាំងនោធ្វើតាមសារាចរណែនាំ និងគោលនយោបាយដ៏ជាក់លាក់មួយចំនួនរបស់ បកក ដែរឬទេ។ នៅពេលដែលចម្លើយសារភាពមិនត្រូវបានទទួលយក ដើម្បីបញ្ជាក់ការពិតលើចម្លើយដែលត្រូវបានបង្ខិតបង្ខំទេ (ឧទាហរណ៍ថា អ្នកជាប់ឃុំបានក្បត់នឹងអង្គការដោយការខកខានមិនបានធ្វើតាមសារាចរណែនាំថា ពួកអតីតទាហាន លន់ នល់ ទាំងអស់ត្រូវតែកំទេចចោល), អង្គហេតុពិតដែលពួកអ្នកសួរចម្លើយបានសួរពួកអ្នកជាប់ឃុំពីប្រធានបទទាំងនេះ គឺមានការពាក់ព័ន្ធ និងបានជួយនៅក្នុងការបង្កើតសារាចរណែនាំរបស់ បកក ដែលគេរំពឹងថាពួកកម្មាភិបាលទាំងនោះត្រូវអនុវត្តតាម ។

៤៩. វិធានផ្ទៃក្នុង ៥៥(៥) ចែងថា “ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត”។ ដើម្បីបំពេញបានកិច្ចស៊ើបសួរនេះ សហចៅក្រមស៊ើបអង្កេត ក្នុងចំណោមប្រការផ្សេងទៀត អាច “កោះហៅ និងសួរចម្លើយជនសង្ស័យ និងជនត្រូវចោទ ស្តាប់ចម្លើយជនរងគ្រោះនិងសាក្សី និងកត់ត្រាទុកនូវចម្លើយរបស់ពួកគេប្រមូលវត្ថុតាងស្វែងរកមតិយោបល់ពីអ្នកជំនាញ និងដឹកនាំការស៊ើបសួរចុះដល់ទីកន្លែងកើតហេតុ” ។ ដោយមានការបញ្ជាក់ដ៏ជាក់លាក់ថា សហចៅក្រមស៊ើបអង្កេត ត្រូវមានអនាគតិនៅពេលប្រមូលភស្តុតាង ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ មិនមានបទបញ្ញត្តិណានៅក្នុងវិធានផ្ទៃក្នុង ឬនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ ដែលរារាំងសហចៅក្រមស៊ើបអង្កេតមិនឲ្យផ្អែកទៅលើព័ត៌មានដែលខ្លួនមានទាក់ទិនទៅនឹងមន្ទីរ ស-២១ ឬក៏មន្ទីរសន្តិសុខដទៃទៀត និងកន្លែងដែលការធ្វើទារុណកម្ម ត្រូវបានអនុវត្តក្នុងគោលបំណងស៊ើបសួររកតម្រុយផ្សេងទៀតក្នុងការស្វែងរកការពិត ។

៥០. នៅដំណាក់កាលនេះ ភស្តុតាងនេះអាចត្រូវបានគេប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការស៊ើបសួរបន្ថែមទៀត ហើយថាតើ ភស្តុតាងនេះគ្រប់គ្រាន់ជាភស្តុតាងតាមផ្លូវតុលាការ ឬយ៉ាងណានោះអាចត្រូវបានសម្រេចទៅលើអង្គសេចក្តីនៃករណីពិសេសនីមួយៗ ។ ការហាមឃាត់មិនឲ្យប្រើប្រាស់ភស្តុតាងនេះនៅដំណាក់កាលដំបូង នឹងរារាំងសមត្ថភាពរបស់រដ្ឋ ដែលនៅទីនេះជាប្រទេសកម្ពុជានិងអ.វ.ត.ក មិនឲ្យធ្វើការស៊ើបអង្កេត និងផ្តន្ទាទោសទៅលើអំពើធ្វើទារុណកម្មទាំងឡាយ ដូចដែលតម្រូវឲ្យមាននៅក្នុងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម មាត្រា ១២[104] ។

៥១. មេធាវីការពារក្តីលើកទឡ្ហីករណ៍ថា ទ្រឹស្តីនៃ “ផ្លែផ្កាដែលបានមកពីដើមដែលមានជាតិពុល” គួរតែរារាំងមិនឲ្យមានការប្រើប្រាស់ភស្តុតាងដែលត្រូវគេជំទាស់ ធ្វើជាភស្តុតាងតម្រុយ[105] ។ ដោយការដកស្រង់នូវទ្រឹស្តីនេះ សហមេធាវីការពារក្តី ភ័ន្តច្រឡំភស្តុតាង តម្រុយជាមួយនឹងភស្តុតាងដែលបានមកដោយខុសច្បាប់ ដែលបង្ហាញឲ្យឃើញនូវការយល់ច្រឡំអំពីនិយមន័យនៃភស្តុតាងតម្រុយ ។ ទ្រឹស្តី “ផ្លែផ្កា” ពាក់ព័ន្ធជាមួយនឹងអនីត្យានុកូលនីតិវិធី ដែលឈានទៅរកការរឹបអូសយកភស្តុតាងដាក់បន្ទុកភ្លាមៗ ដូចជា ការចូលក្នុងផ្ទះដោយគ្មានដីកាឆែកឆេរ

---

[104] អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មាត្រា ១២ ចែងថា *“[ភាគីនីមួយៗ] ត្រូវធានា...នូវការស៊ើបអង្កេតដោយអនាគតិ និងឲ្យបានឆាប់រហ័ស នៅពេលណាដែលមានហេតុផលត្រឹមត្រូវដែលជឿជាក់ថា អំពើធ្វើទារុណកម្មត្រូវបានប្រព្រឹត្តនៅក្នុងដែន សមត្ថកិច្ចនៃយុត្តាធិការរបស់ខ្លួន” ។*

[105] បណ្តឹងឧទ្ធរណ៍, មូលហេតុទី៧, ទ្រឹស្តីនៃភស្តុតាងដែលបានមកដោយអំពើទុច្ចរិត, កថាខ័ណ្ឌទី ៧៨-៨៦ ។

និងការរកឃើញគ្រឿងញៀនខុសច្បាប់ ឬក៏ការទទួលបាន ចម្លើយសារភាពនៅខាងក្នុង ។ នៅក្នុងការកំណត់និយមន័យទ្រឹស្តីនោះ តុលាការកំពូលរបស់សហរដ្ឋអាមេរិកបានបញ្ជាក់យ៉ាងច្បាស់ថា “យើងមិនចាំបាច់អះអាងថា ភស្តុតាងទាំងអស់គឺជា ‘ផ្លែផ្កានៃដើមដែលមានជាតិពុល’ ឡើយ ពីព្រោះវានឹងមិនបានបង្ហាញឲ្យឃើញឡើយ ប៉ុន្តែសម្រាប់សកម្មភាពខុសច្បាប់របស់នគរបាល”[106] ។

៥២. ផ្ទុយទៅវិញ ភស្តុតាងបង្ហាញតម្រុយ គឺការប្រើប្រាស់សម្តីផ្ទាល់មាត់ ឬឯកសារលាយលក្ខណ៍អក្សរ ដើម្បីកំណត់កិច្ចស៊ើបសួរបន្ថែម ដូចជាអំពីមនុស្សដែលត្រូវសាកសួរ ទីកន្លែងប្រមូលឯកសារ ឬសំណួរសម្រាប់សួរសាក្សី ។ លើសពីនេះ កិច្ចស៊ើបសួរនេះខុសគ្នាពីតម្រុយផ្ទាល់ត្រង់ពេលវេលា និងទីកន្លែង ។ វាពុំដូចជាភស្តុតាងដែលបានមកដោយខុសច្បាប់ដែលបានភ្លាមៗ ឬក្រោយពីការកើតមានអំពើខុសច្បាប់ និងនៅកន្លែងកើតអំពើខុសច្បាប់នោះឡើយ ។ ដោយយកគោលការណ៍នេះមកអនុវត្ត សហចៅក្រមស៊ើបអង្កេត អាចប្រើប្រាស់ឯកសារនៅក្នុងភស្តុតាងដែលត្រូវគេជំទាស់ ដើម្បីនាំទៅដល់ផ្នែកខុសគ្នាផ្សេងៗនៃភស្តុតាង “បើទោះបីជាទីបំផុតគេចាត់ទុកព័ត៌មាននៅក្នុងចម្លើយសារភាព ថាពុំ គួរឲ្យជឿជាក់បានក្តី[107]” ។

## ឃ. ការប្រើប្រាស់ដោយអ្នកជំនាញ

៥៣. របាយការណ៍អ្នកជំនាញ និងមតិទាំងឡាយណាដែលពឹងផ្អែកលើភស្តុតាងដែលត្រូវគេជំទាស់តាមធម្មតាគឺអាចទទួលយកបានដែរ ប្រសិនបើភស្តុតាងដែលជាមូលដ្ឋាននោះត្រូវបានគេយល់ឃើញថាអាចទទួលយកបាន ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើភស្តុតាងដែលត្រូវគេជំទាស់ពុំអាចទទួលយកបានទេនោះ ការណ៍នេះក៏មិនត្រូវច្រានចោលជាស្វ័យប្រវត្តិ នូវភស្តុតាងអ្នកជំនាញដែរ។ ក្រុមមេធាវីការពារក្តីខកខានពុំបានផ្តល់មូលដ្ឋានមួយក្នុងច្បាប់អ.វ.ត.ក សម្រាប់រារាំងភស្តុតាងអ្នកជំនាញដែលសំអាងដោយផ្អែកទៅលើភស្តុតាងដែលត្រូវគេជំទាស់ ។ បន្ថែមពីលើនេះ ក្រុមមេធាវីការពារក្តីពុំបានពន្យល់អំពីមូលហេតុអ្វីបានជាការសួរសាក្សីរបស់ភាគីបដិ

---

[106] *Wong Sun ទល់នឹង សហរដ្ឋអាមេរិក*, 71 U.S. 471, តុលាការកំពូលសហរដ្ឋអាមេរិក (១៩៦៣) ទំព័រទី៤៨៧-៨៨ [បញ្ជាក់បន្ថែម]។

[107] ដីកាស្តីពីភស្តុតាងនៃការធ្វើទារុណកម្ម, កថាខ័ណ្ឌទី ២៦ ។ ក្នុងកិច្ចស៊ើបសួរក្នុងស្រុកធម្មតា រឿងដដែលនេះយកមកអនុវត្ត ពេលអ្នកស៊ើបអង្កេត ឬចៅក្រមស៊ើបអង្កេត យកព័ត៌មានដែលអាចពុំគួរឲ្យជឿទុកចិត្តបាន និងព័ត៌មានដែលពុំត្រូវបានផ្ទៀងផ្ទាត់ជាក់លាក់ មកប្រើប្រាស់ធ្វើជាតម្រុយនៃកិច្ចស៊ើបសួរ ដូចជាព័ត៌មានអំពីអ្នកផ្តល់ព័ត៌មាន ។ ការពុំទៅតាមតម្រុយទាំងនេះនឹងរារាំងអ្នកស៊ើបអង្កេតមិនឲ្យស្វែងរកបទល្មើស និងជនល្មើសតាមពេលវេលាជាក់លាក់ ។

បក្ខ ឬការហៅអ្នកជំនាញបន្ថែមទៀត ក្រោមវិធាន៨៤នៃវិធានផ្ទៃក្នុងវាពុំមែនជាមូលដ្ឋានគ្រប់គ្រាន់ដើម្បីចោទសួរអំពីប្រភេទនៃរបាយការណ៍ និងគំនិតទាំងនេះ ។

៥៤. ច្បាប់អន្តរជាតិស្តីពីភស្តុតាងមានការណែនាំអំពីប្រធានបទនេះ ។ តុលាការពិសេសគាំទ្រដល់ការអនុញ្ញាតឱ្យអ្នកជំនាញប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ទាក់ទិននឹងប្រភពដែលត្រូវ ពិគ្រោះយោបល់ ដែលអនុញ្ញាតឱ្យអាចទទួលយកនូវភស្តុតាងអ្នកជំនាញបាន និងបន្ទាប់ មកទៀតធ្វើការវិភាគវាយតម្លៃឆន្ទានុសិទ្ធិនេះនៅសវនាការតាមរយៈការសួរដេញដោលសាក្សី ។ *ក្នុងរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Bagosora* មេធាវីការពារក្តីបានតវ៉ា ជំទាស់នឹងការយល់ព្រមទទួលយកចម្លើយសាក្សីដែលជាអ្នកជំនាញ ដោយប្រឆាំងជំទាស់ នឹងភាពគួរឱ្យទុកចិត្តបាននៃឯកសារ ដែលជាមូលដ្ឋានសំអាងនៃចម្លើយនោះ ។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានសម្រេចថា "មេធាវីការពារក្តីអាចចោទសួរបានអំពីមូលដ្ឋានសំអាងនៃគំនិតដែលជាភស្តុតាងក្នុងអំឡុងពេលការធ្វើសក្ខីកម្មរបស់សាក្សី ។ អង្គជំនុំជម្រះ ពិចារណាឃើញថាការសួរសាក្សីរបស់ភាគីបដិបក្ខ គឺជាយន្តការសមស្របសម្រាប់ជម្រះកង្វល់ របស់មេធាវីការពារក្តី ។ អង្គជំនុំជម្រះមានចិត្តសោមនស្សក្នុងការយកបញ្ហាដែលត្រូវគេជំទាស់ អំពីភាពគួរឱ្យជឿទុកចិត្តបាន មកធ្វើការដោះស្រាយក្នុងពេលពិចារណាអំពីអង្គសេចក្តីនៃសំណុំរឿងនេះ បន្ទាប់ពីបានទទួលស្តាប់ភស្តុតាងទាំងអស់[108]" ។

៥៥. ស្រដៀងគ្នានេះដែរ តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី នាពេលថ្មីៗបានសម្រេចថា "បើទោះបីជាយ៉ាងណាក្តី កង្វល់អំពីភាពគួរឱ្យជឿទុកចិត្តបាននៃប្រភពទាំងឡាយដែលអ្នកជំនាញបានយកមកប្រើប្រាស់ វាពុំប៉ះពាល់ដល់ភាពអាចទទួលយកបាននៃរបាយការណ៍នេះទេប៉ុន្តែអាចប៉ះពាល់ដល់ការផ្តល់ទម្ងន់ទៅដល់ភស្តុតាងរបស់អ្នកជំនាញ[109]"។ យុត្តាធិការផ្សេងៗទៀតដូចជា សហរដ្ឋអាមេរិក និងកាណាដា អនុញ្ញាតឱ្យមានការទទួលយក

---

[108] *ករណីរឿងរបស់ រដ្ឋអាជ្ញា ទល់នឹង Bagosora* សំណុំរឿងលេខ ICTR-98-41-T សេចក្តីសម្រេចស្តីពីពាក្យសុំឱ្យច្រានចោលនូវចម្លើយរបស់សាក្សីអ្នកជំនាញឈ្មោះ Filip Reyntjens ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៤ (អង្គជំនុំជម្រះសាលាដំបូង) ត្រង់កថាខណ្ឌ៩ ។

[109] *សូមមើល រដ្ឋអាជ្ញា ទល់នឹង Perisic* សំណុំរឿងលេខ IT-04-81-IT សេចក្តីសម្រេចស្តីពីរបាយការណ៍អ្នកជំនាញ ដោយ Richard Phillips ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ (អង្គជំនុំជម្រះសាលាដំបូង) ត្រង់កថាខណ្ឌ១៨ ។

00388465



សក្ខីកម្មរបស់អ្នកជំនាញដែលក្នុងនោះភាគីជំទាស់អាចសួរដេញដោលបាន ហើយសក្ខីកម្មនោះត្រូវបានយកមកធ្វើការវិភាគថ្លឹងថ្លែង ដោយអ្នកវិភាគអង្គហេតុរបស់តុលាការ[110] ។ ដូច្នេះអង្គហេតុ ឬទិន្នន័យណាមួយក៏ដោយ ក៏គេអាចយកមកប្រើប្រាស់ធ្វើជាមូលដ្ឋានសំអាងសម្រាប់សក្ខីកម្មរបស់អ្នកជំនាញបានដែរ ។ សហព្រះរាជអាជ្ញា ពុំឃើញមានមូលហេតុណាមួយដែល អ.វ.ត.ក ត្រូវអើពើធ្វើពុំដឹងពុំឮ អំពីយន្តការនេះដែលត្រូវបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិឡើយ ដោយតុលាការអន្តរជាតិ ឬអន្តរជាតូបនីយកម្មផ្សេងៗ បានដោះស្រាយសំណុំរឿង ដែលមានភាពស្មុគស្មាញ និងធ្ងន់ធ្ងរស្រដៀងគ្នានឹងសំណុំរឿងនេះ ។

## ង. ភស្តុតាងបញ្ជាក់អះអាងបន្ថែម

៥៦. សេចក្តីផ្ទុយដែលទំនងជាភស្តុតាងបង្ហាញតម្រុយ គឺជាការបញ្ជាក់អះអាងបន្ថែមហើយសហចៅក្រមស៊ើបអង្កេត គួរតែមានលទ្ធភាពយកភស្តុតាងដែលត្រូវគេជំទាស់ មកធ្វើជាប្រភពបន្ថែម ដើម្បីបញ្ជាក់អះអាងបន្ថែមអំពីភស្តុតាង ដែលកិច្ចស៊ើបសួរបានរកឃើញដោយឯករាជ្យរួចហើយ (ប្រភពចម្បង) ។ ដូចដែលបានគូសបញ្ជាក់រួចមកហើយ សហចៅក្រមស៊ើបអង្កេត មានសិទ្ធិអំណាចលើការស៊ើបសួរយ៉ាងធំទូលំទូលាយ ក្នុងការណាតត្រដាងការពិត ។ ដូច្នេះ ប្រសិនបើសហចៅក្រមស៊ើបអង្កេតបានរកឃើញនូវអង្គហេតុណាមួយជាក់លាក់ ជាពិសេសពីការសាកសួរ ឬឯកសារនានា និងបានធ្វើការវិភាគវាយតម្លៃផ្ទៀងផ្ទាត់អង្គហេតុទាំង

[110] វិធានសហព័ន្ធស្តីពីភស្តុតាងនៃសហរដ្ឋអាមេរិក ត្រង់វិធាន៧០៣ ចែងថា "អង្គហេតុ ឬទិន្នន័យ [ដែលជាមូលដ្ឋានសម្អាងរបស់គំនិតនេះ] ពុំចាំបាច់ត្រូវទទួលយកជាភស្តុតាង ដើម្បីឲ្យគំនិត ឬការសន្និដ្ឋាននោះត្រូវបាន គេទទួលយកឡើយ ។ អង្គហេតុ ឬទិន្នន័យដែលពុំត្រូវទទួលយក ពុំត្រូវបង្ហាញឲ្យគណៈវិនិច្ឆ័យដឹងឡើយ លើកលែងតែតុលាការកំណត់ថាតម្លៃខាងភស្តុតាងរបស់វាក្នុងការជំនួយដល់គណៈវិនិច្ឆ័យក្នុងការវាយតម្លៃទស្សនៈអ្នកជំនាញ វាមានទម្ងន់ធ្ងន់ជាផលប៉ះពាល់របស់វា" ។ ប្រទេសកាណាក៏ប្រកាន់យកវិធីសាស្ត្រស្រដៀងគ្នានេះដែរ។ រឿងក្តី R ទល់នឹង Zundel (១៩៨៧) 35 DLR (4th) 338 កថាខណ្ឌ១៣២ ១៤១ អនុញ្ញាតឲ្យអ្នកជំនាញពឹងផ្អែកលើឯកសារដែលមាន អាយុកាលស្រដៀងគ្នា ដែលប្រវត្តិវិទូធ្លាប់តែងតែពឹងផ្អែកលើ ដើម្បីបង្ហាញអំពីអត្ថិភាពនៃ the Holocaust។ ក្រោមច្បាប់កាណាដា បញ្ហាដែលអ្នកជំនាញសំអាងទស្សនៈរបស់គាត់ដោយផ្អែក ឬទាំងស្រុង ទៅលើចម្លើយដែលពុំត្រូវអនុញ្ញាតជាភស្តុតាង ត្រូវមានទម្ងន់ត្រឹមត្រូវសមល្មមនឹងឯកភាពតាមទស្សនៈរបស់គាត់ ពុំមែនជាភាពអាចទទួលយកបានរបស់វាទេ។ សូមមើលឧទាហរណ៍ City of St. John v. Irving Oil. Ltd. (1966) 58 DLR (2d) 404, ទំព័រ១២ ។

នោះជាមួយឯកសារដែលមានអាយុស្រដៀងគ្នានោះការប្រើប្រាស់ភស្តុតាងដែលត្រូវគេជំទាស់សម្រាប់គោលបំណងនេះ គួរតែត្រូវបានអនុញ្ញាត ។

៥៧. តាមរយៈការយកឯកសារដែលពុំត្រូវគេជំទាស់ មកវិភាគវាយតម្លៃជាមួយនឹងឯកសារដែលត្រូវគេជំទាស់ ជាពិសេសត្រង់ចំណុចគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានគេលើកយកមកពិភាក្សាក្នុងចម្លើយសារភាពជាច្រើននោះ សហចៅក្រមស៊ើបអង្កេតនឹងអាចមានលទ្ធភាពវិនិច្ឆ័យការពិតអំពីប្រភពនៃឯកសារទាំងនោះ ហើយនឹងកាន់តែខិតទៅជិតដល់ការពិត ។ បន្ថែមពីលើចំណុចនេះ ការប្រើប្រាស់ភស្តុតាងដែលត្រូវគេជំទាស់ក្នុងលក្ខណៈបែបនេះ វាពុំជម្រុញឲ្យមានការធ្វើទារុណកម្ម ឬប៉ះពាល់ដោយមិនយុត្តិធម៌ដល់ភាគីណាមួយឡើយ ប៉ុន្តែការប្រើប្រាស់ភស្តុតាងដែលត្រូវគេជំទាស់នេះ វាគឺជាអ្នកកំណត់ថាតើភស្តុតាងដែលបានរកឃើញនោះ វាស្របទៅតាមឯកសារដែលមានអាយុស្រដៀងគ្នា ហើយចេញជាលទ្ធផលគួរឲ្យទុកចិត្តបានដែរឬយ៉ាងណា ។

៥៨. វិស័យជាសក្តានុពលមួយចំនួនដែលធ្វើឲ្យភស្តុតាង ដែលមានការតវ៉ាជំទាស់អាចត្រូវបានប្រើប្រាស់ដើម្បី គោលបំណងដែលមានភាពស្របគ្នា ដោយមិនមានការរំលោភទៅលើស្មារតីនៃអនុសញ្ញា CAT និង មាត្រា១៥ គឺមានច្រើន ។ ជនរងគ្រោះជាច្រើនបានផ្តល់ចម្លើយទាក់ទិននឹងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ការទំនាក់ទំនងនិងការអនុវត្តគោលនយោបាយ[111] ដោយអនុញ្ញាតឲ្យមានការអះអាងបញ្ជាក់ឆ្លងប្រភពនានា ព្រមទាំងបូករួមជាមួយភស្តុតាងដែលមិននិយាយអំពីការធ្វើទារុណកម្មនានានៅក្នុងសំណុំរឿង។ ចំណុចបញ្ជាក់អះអាងបន្ថែមទាំងនេះមិនមែនជាចំណុចនៃការធ្វើពិរុទ្ធកម្មឡើយ ប៉ុន្តែជាឯកសារបន្ថែមដែលមិនមែនជាកម្មវត្ថុនៃការសួរចម្លើយ ។ ក្នុងក្រសែភ្នែករបស់បក្សកុម្មុយនីស្តកម្ពុជា គោលបំណងស្នូលនៃការ

[111] ឧទាហរណ៍ល្អមួយ គឺចម្លើយពីចម្លើយសារភាពដែលបង្កើតបានជាគោលនយោបាយ "ការធ្វើវិសុទ្ធកម្មជាបន្តបន្ទាប់" ដែលបានអនុវត្តនៅមន្ទីរ ស-២១ និងដែលជនត្រូវចោទមានឥទ្ធិពលទៅលើចម្លើយ ។ ជាក់ស្តែង ប្រសិនបើក្នុងចម្លើយសារភាពមួយ ជនរងគ្រោះដោយការធ្វើទារុណកម្មឈ្មោះ "ក" បានកំណត់អត្តសញ្ញាណឈ្មោះ "ខ" ថាជាជនក្បត់ដែលក្រោយ មកត្រូវបានបញ្ជូនមកកាន់មន្ទីរ ស-២១ ដូច្នេះចម្លើយសារភាពទាំងនេះគួរត្រូវបានទទួលយកធ្វើជាភស្តុតាងដែលបង្ហាញអំពីគោលនយោបាយវិសុទ្ធកម្មកម្ពុជាប្រជាធិបតេយ្យដែលកំពុងត្រូវបានអនុវត្តនៅឯមន្ទីរ ស-២១ ។

00388467



សួរចម្លើយគឺដើម្បីបង្ហាញថាជនក្បត់ ឬគិញដែលត្រូវបានគេចោទប្រកាន់ គឺពិតជាអ្នកដែលទទួលខុសត្រូវចំពោះ "ការបរាជ័យនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា[112]" ។ ទង្វើនេះចង្អុលបង្ហាញដោយភាពសមហេតុផលថា គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា បានចែងយ៉ាងត្រឹមត្រូវនៅក្នុងភស្តុតាងដែលត្រូវគេជំទាស់ដើម្បីបង្ហាញពីអ្វីដែល "ជនក្បត់" បានរំលោភបំពាន ។ ដូច្នេះឯកសារនៅក្នុងភស្តុតាង ដែលត្រូវគេជំទាស់ដែលអាចយកមកប្រើប្រាស់ដើម្បីធ្វើការបញ្ជាក់អះអាងបន្ថែមនោះ គឺវាពុំមែនជាការពិតដែលមានមូលដ្ឋានមកពីពាក្យចចាមអារ៉ាម ដែលត្រូវគេពោលអះអាងនោះទេ ។

## ច. ភាពអាចទទួលយកបាននៅក្រមគោលការណ៍ស្តីពីភាពបត់បែន

៥៩. សហព្រះរាជអាជ្ញាជឿជាក់ថា ភស្តុតាងដែលត្រូវគេជំទាស់នេះ គឺអាចទទួលយកបានដូចដែលបានរៀបរាប់ពីខាងលើដោយហេតុថា គេត្រូវបកស្រាយមាត្រា១៥ ឱ្យស្របជាមួយនឹងកម្មវត្ថុនិងគោលបំណងរួមរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មនិងគោលបំណងដែលអនុញ្ញាតបានសម្រាប់ភស្តុតាងនេះ ដែលមានស្រោប់មិនបំពានមាត្រា ១៥ ឬករណី លើកលែងរបស់វាឡើយ។ ថ្វីបើយ៉ាងដូច្នេះក្តី សហព្រះរាជអាជ្ញាសូមលើកអំណះអំណាងក្នុងជម្រើសនេះ និងដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទឡ្ហីករណ៍មុនៗដែលថា បណ្តឹងឧទ្ធរណ៍មានលក្ខណៈពុំច្បាស់លាស់និងពុំពេញលេញ[113] ដែលថាអ.វ.ត.ក គួរអនុវត្តតាមគោលការណ៍បត់បែនដែលគេបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

៦០. របបគ្រប់គ្រងភស្តុតាងនៅតាមបណ្តាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឬអន្តរជាតូបនីយកម្មផ្សេងៗ គឺមានលក្ខណៈបត់បែនពីធម្មជាតិ ដោយហេតុថា តុលាការទាំងអស់នេះមានសមាសភាពចៅក្រមវិជ្ជាជីវៈដែលពុំត្រូវបានរារាំងដោយវិធានដាក់កំហិត នៃភស្តុតាងសមស្រប

---

[112] S. Heder និង B. Tittemore, *សេក្តីផ្តើមនៃចំនួនជនរងគ្រោះ...* ។ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានារបស់ខ្មែរក្រហម, ក្រុងភ្នំពេញ, មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៤, ត្រង់ទំព័រ២៩ ។

[113] សូមមើលខាងលើ កថាខណ្ឌទី១៤-១៥ ។

សម្រាប់ការជំនុំជម្រះដោយមានគណៈវិនិច្ឆ័យ[114] ។ ដូច្នេះ តាមវិធាន៨៧(១) "រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក" លើកលែងតែមានបទប្បញ្ញត្តិផ្សេងនៅក្នុងវិធាននេះ ។ វិធានរួម ៨៩ នៃវិធាននៃនីតិវិធី និងភស្តុតាង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី រ៉្វាន់ដា និងសេរ៉ាឡេអូន ក៏មានលក្ខណៈស្រដៀងគ្នាគួរឱ្យកត់សម្គាល់ដែរ ។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់ប្រទេស សេរ៉ាឡេអូន ដែលគ្រប់គ្រងដោយវិធានភស្តុតាងស្រដៀងគ្នាទៅនឹង អ.វ.ត.ក[115] គូសបញ្ជាក់ថា"ភស្តុតាងត្រូវទទួលយកក្នុងពេលគេបង្ហាញឱ្យឃើញថា មានភាពពាក់ព័ន្ធនោះ ចំណោទនៃភាពគួរឱ្យទុកចិត្តបានរបស់វានឹងត្រូវបានគេកំណត់ក្នុងពេលក្រោយហើយពុំមែនជាលក្ខខណ្ឌសម្រាប់ទទួលយកភស្តុតាងនោះទេ"។

៦១. ដូច្នេះ ការបញ្ចប់កិច្ចស៊ើបសួរ[116] និង/ឬ សវនាការជំនុំជម្រះបន្តមកទៀត គឺជាវេទិកាសម្រាប់ពិភាក្សាដេញដោលអំពីភាពគួរឱ្យទុកចិត្តបាននៃភស្តុតាង ។ ក្នុងពេលជាមួយគ្នានេះ ភស្តុតាងដែលត្រូវគេជំទាស់នៅតែស្ថិតនៅក្នុងសំណុំរឿង ដែលជាភស្តុតាងត្រូវទទួលយកសម្រាប់គោលបំណងបច្ចុប្បន្ន ដោយហេតុថាវាមានភាពពាក់ព័ន្ធច្បាស់លាស់និងមានតម្លៃខាងភស្តុតាង ។ ប្រសិនបើភាគីមួយជំទាស់ទៅនឹងភស្តុតាង ត្រូវគេយល់ថាមានលក្ខណៈគួរឱ្យជឿជាក់ ពេលនោះសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះសាលាដំបូងអាចថ្លឹង ថ្លែងអំពីទម្ងន់នៃការជំទាស់នោះឱ្យបានសមស្រប ក្នុងពេលស្ថាប័ននីមួយៗពិចារណាអំពីភស្តុតាង[117]

---

[114] របាយការណ៍ប្រចាំឆ្នាំរបស់ ICTY A/49/342 ថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៩៤ ទំព័រ២៤។ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា វិធានផ្ទៃក្នុង អ.វ.ត.ក មានភាពបត់បែនជាងវិធាននានារបស់សាលាក្តីផ្សេងៗ ។ ខណៈពេល ICTY និង ICTR កំណត់ត្រឹមតែធ្វើការពិចារណាភស្តុតាងដែលពាក់ព័ន្ធ និងមានលក្ខណៈជាភស្តុតាង អ.វ.ត.ក អាចពិចារណាអំពី "ភស្តុតាងទាំងឡាយណា...ដែលមានប្រយោជន៍ដល់ការលាតត្រដាងការពិត" ដូចជាភស្តុតាងពាក់ព័ន្ធឡើយ (វិធានផ្ទៃក្នុង ៨៧.៤) ។

[115] *សូមមើល* វិធាននីតិវិធី និងភស្តុតាងរបស់តុលាការពិសេស សម្រាប់សៀរ៉ាឡេអូន ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ វិធាន ៨៩(គ) ។

[116] វិធានផ្ទៃក្នុង៦៦-៦៧ ។

[117] *រដ្ឋអាជ្ញា ទល់នឹង Brdjanin* សេចក្តីសម្រេចស្តីពីសេចក្តីសន្និដ្ឋានរបស់រដ្ឋអាជ្ញាអំពីចម្លើយរបស់សាក្សីអ្នកជំនាញ Ewan Brown, ICTY, សំណុំរឿងលេខ IT-99-36-T ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៣ ទំព័រ៣ ។

ឬដូចដែលអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តក្នុងសំណុំរឿង០០១[118] នោះគឺពុំយកភស្តុតាងនេះមកពិចារណារួមគ្នាក្នុងពេលគេបង្ហាញថា វាមិនត្រូវបានគេយកមកធ្វើជាសំអាងជាមូលដ្ឋានដោយត្រឹមត្រូវ អនុលោមតាមវិធាន៨៧នៃវិធានផ្ទៃក្នុង ។ បន្ថែមពីលើ ចំណុចនេះការទទួលយកឯកសារទាំងនេះ និងការដាក់ឯកសារទាំងនេះទៅក្នុងសំណុំរឿង ពុំមែនមានន័យថាសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះ ឬអង្គជំនុំជម្រះសាលាដំបូង ព្រមទទួលស្គាល់ឯកសារទាំងនោះថាជាការពិតឡើយ ។

៦២. ជាទីបញ្ចប់ មិនមានសមត្ថកិច្ចតុលាការណាមួយរបស់តុលាការនេះសម្រេចថា ខ្លួនបានសំអាងទៅលើភស្តុតាងដែលត្រូវគេជំទាស់នេះដើម្បីគោលបំណងមួយដែលផ្ទុយនឹងមាត្រា១៥ឡើយ ។ តាមការពិត សំណើរបស់មេធាវីការពារក្តីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតមានលក្ខណៈទូទៅ និងពុំទាន់គ្រប់ជ្រុងជ្រោយ ដោយពុំបានធ្វើការកំណត់មូលដ្ឋាននៃការជំទាស់របស់ខ្លួន និងការអះអាងអង្គហេតុទាក់ទិននឹងភាពគួរឱ្យទុកចិត្តបានចំពោះរាល់ឯកសារនីមួយៗ ដែលអង្គបុរេជំនុំជម្រះគួរតែបដិសេធចោល ដោយសារតែសំណើមួយនេះពុំមានលក្ខណៈច្បាស់លាស់ និងខ្វះមូលដ្ឋានអង្គហេតុ ។ ក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាក្នុងដំណាក់កាលនេះ ពុំគួរមានការរាំងស្ទះណាមួយដល់ការបន្តរក្សាទុកឯកសារទាំងអស់នេះនៅក្នុងសំណុំរឿងឡើយ ។ ភាគីទាំងឡាយអាចធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ទាក់ទិននឹងការគួរធ្វើការថ្លឹងថ្លែងអំពីទម្ងន់នៃឯកសារទាំងអស់នេះ ដែលធ្វើឡើងដោយអង្គភាពណាមួយនៃ អ.វ.ត.ក ក្នុងពេលវេលានៃនីតិវិធីសមស្រប ឬក៏ពួកគាត់អាចធ្វើសេចក្តីសន្និដ្ឋានទាក់ទិននឹង ថាតើសហចៅក្រមស៊ើបអង្កេតនៅពេលបញ្ចប់កិច្ចស៊ើបសួរ ឬអង្គជំនុំជម្រះសាលាដំបូង នាដំណាក់កាលជំនុំជម្រះ គួរពិចារណាទៅលើឯកសារទាំងអស់នោះដែរឬយ៉ាងណា ។

## ៦. សេចក្តីសន្និដ្ឋាន

៦៣. សហព្រះរាជអាជ្ញា សូមស្នើអង្គបុរេជំនុំជម្រះ បដិសេធចោលបណ្តឹងឧទ្ធរណ៍ទាំងនេះ ។

[118] *ករណីរបស់ ឌុច,* សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿង ធ្វើជាភស្តុតាង, អង្គជំនុំជម្រះសាលាដំបូងនៃ អវតក, ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧, E43/4, ERN 00332849-57 (ភាសាអង់គ្លេស), កថាខណ្ឌទី១៨-២០ ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ | លោក យ៉េត ចរិយា<br>**សហព្រះរាជអាជ្ញារង** | ភ្នំពេញ | |
| | លោក William SMITH<br>**សហព្រះរាជអាជ្ញាស្តីទី** | ភ្នំពេញ | |